ក្រសួងអប់រំ យុវជន និងកីឡា

ភាសាខ្មែរ

7

សៀវភៅកិច្ចការផ្ទះ

ភាគ១

ខ្លឹមសារក្នុងសៀវភៅនេះរួមមាន៖

- សំណួរពហុជ្រើសរើស
- សំណួរផ្គូផ្គង
- សំណួរត្រិះរិះ
- សំណួរស្រាវជ្រាវ
- សំណេរកថាខណ្ឌ



ស្របតាមកម្មវិធីសិក្សាថ្មី

លំហាត់តាសាខ្មែរថ្នាក់ទី៧

លំហាត់អនុវត្តដែលជួយលើកកម្ពស់សមត្ថភាពភាសាខ្មែររបស់អ្នកសិក្សា

គណៈកម្មការនិពន្ធ លោកស្រី ម៉ែន សូឡាណែត លោកស្រី ទ្រី រ៉ុច

កញ្ញា ជុន សុជាតិ

អ្នកនាយអត្ថបទ លោកស្រី ម៉ែន សូឡាណែត

អ្នករៀបរៀង លោកស្រី ម៉ែន សូឡាណែត

រចនាចំណុះ លោកស្រី ម៉ែន សូឡាណែត

រចនារូបភាព លោកស្រី ម៉ែន សូឡាណែត

រចនាក្រប លោក សៀក ចិន

គណៈកម្មការពិនិត្យ លោកស្រី ទ្រី រ៉ុច លោក សាន់ ប៊ុនណាត

លោក ហ៊ិន សុផល កញ្ញា វណ្ណ ធារ៉ា

រក្សាសិទ្ធិ ©

ហាមឃាតចម្លងគ្រប់រូបភាពដោយគ្មានការអនុញ្ញាត

បោះពុម្ពលើកទី១ ឆ្នាំ២០២២

ភាសាខ្មែរ ថ្នាក់ទី៧



សៀវភៅកិច្ចការផ្ទះ

បង្រៀនដោយ :.....

ឈ្មោះសិស្ស :.....

ភេទ :.....

ថ្នាក់ទី :.....

អត្តលេខ :.....

ទំនាក់ទំនង :.....

ឆ្នាំសិក្សា:.....~.....

អារម្ភកថា

ការរីកចម្រើនលើគ្រប់វិស័យនៅក្នុងសកលលោកយើងនេះគឺ អាស្រ័យទៅនឹងកត្តាវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលកើតមកពីការសិក្សាស្រាវជ្រាវរបស់មនុស្សលោក។ មុខវិជ្ជាភាសាខ្មែរ ជាមុខវិជ្ជាសំខាន់មួយនៅក្នុងប្រទេសកម្ពុជា ក៏ជាភាសាជាតិព្រមទាំងមានការចូលរួមចំណែកផ្នែកវិទ្យាសាស្ត្រផងដែរ ។

សៀវភៅសំណួរជ្រើសរើស និងលំហាត់នេះ ត្រូវបានដកស្រង់ចេញពីកម្មវិធីសិក្សាគោលភាសាខ្មែរ ថ្នាក់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងគោលបំណងបំពេញបន្ថែមនូវចំណេះដឹងផ្នែកភាសាខ្មែរ ដល់សិស្សានុសិស្សនៃសាលាចំណេះទូទៅ ខាងអនុវិទ្យាល័យ ដើម្បីឱ្យប្អូនៗមានមូលដ្ឋានគ្រឹះរឹងមាំ ។

ខ្លឹមសាររបស់សំណួរជ្រើសរើស និងលំហាត់នីមួយៗនៅក្នុងសៀវភៅនេះ ស្របតាមកម្រិតចំណេះដឹងរបស់សិស្សដើម្បីជួយសម្រួលដល់ការសិក្សារបស់ពួកគេ ។ គ្រប់សំណួរជ្រើសរើស សំណួរបំពេញចន្លោះ លំហាត់អនុវត្តនិងសំណេរ គឺត្រូវបានរៀបចំតាមលំដាប់មេរៀនយ៉ាងក្បោះក្បាយ ។

ក្នុងនាមខ្ញុំជាអ្នករៀបរៀងសង្ឃឹមយ៉ាងមុតមាំថា សៀវភៅសំណួរជ្រើសរើស និងលំហាត់នានាសម្រាប់សិស្សថ្នាក់ទី៧នេះ នឹងក្លាយជាមធ្យោបាយដ៏មានសារប្រយោជន៍សម្រាប់សិស្ស នៅសាលាចំណេះទូទៅខាងអនុវិទ្យាល័យជាក់ជាមិនខាន ។

ទោះបីជាខ្ញុំខិតខំសម្រិតសម្រាំងយ៉ាងណាក៏ដោយ ក៏គង់នៅមានកំហុសដោយអចេតនាណាមួយជាក់ជាពុំខានឡើយ ។ ខ្ញុំរីករាយនឹងទទួលការរិះគន់ ដើម្បីស្ថាបនាកែលម្អសៀវភៅនេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងប្រសើរឡើងថែមទៀត ។

ជាចុងក្រោយនេះ ខ្ញុំសូមជូនពរដល់ប្អូនៗដែលជាអ្នកសិក្សាទាំងអស់គ្នាទទួលបាននូវពុទ្ធពរទាំងបួនប្រការ ព្រមទាំងទទួលបានជោគជ័យក្នុងការសិក្សារបស់ប្អូន ។

លោកស្រី **ម៉ែន សុឡាណែត** គ្រូបង្រៀនភាសាខ្មែរកម្រិតឧត្តមសិក្សា

ទូរស័ព្ទលេខ ០៨៩ ៩៣៩ ៦៩០

អ៊ីម៉ែល mensolaneth@preahsisowath.edu.kh

កន្លែងការងារ វិទ្យាល័យព្រះស៊ីសុវត្ថិ កម្មវិធីសាលារៀនជំនាន់ថ្មី NGS

ភ្នំពេញ ថ្ងៃចន្ទ ៤កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្រូវនឹង ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២

មាតិកា

១. មេរៀនទី១៖ សេចក្តីស្រឡាញ់

១.១.បំណិន៖ ព្រេងកថា.....ទំព័រ២-៥

១.២.វេយ្យាករណ៍៖ចំណុចរាយ.....ទំព័រ៦-៧

១.៣.អំណាន៖ប្រាសាទស្វាយអង្គ.....ទំព័រ៨-១០

១.៤.បំណិន៖តម្លៃអប់រំនៅក្នុងរឿង.....ទំព័រ១១-១៣

១.៥.វេយ្យាករណ៍៖ល្បះបញ្ហាក់.....ទំព័រ១៤

១.៦.អំណាន៖យើងត្រូវគោរពទង់ជាតិ.....ទំព័រ១៥-១៦

១.៧.ការស្តាប់៖រឿងបងប្អូនពីរនាក់.....ទំព័រ១៦

១.៨.អំណាន៖រឿងកុកនិងក្អែក.....ទំព័រ១៨-១៩

១.៩. តែងសេចក្តី៖ សំណេរអត្ថបទព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍.....ទំព័រ២១-២២

២. ការជួយគ្នាទៅវិញទៅមក

២.១.បំណិន៖ ទេវកថា.....ទំព័រ២៤-២៧

២.២.អំណាន៖ រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម.....ទំព័រ២៨-៣១

២.៣.វេយ្យាករណ៍៖ ល្បះសំណួរ.....ទំព័រ៣១-៣៣

២.៤.បំណិន៖ តួអង្គឯក តួអង្គរង.....ទំព័រ៣៤-៣៥

២.៥.អំណាន៖ រឿងចចក.....ទំព័រ៣៦-៣៨

២.៦.អំណាន៖ រឿង ដៃ ជើង ក្រពះ.....ទំព័រ៣៩-៤១

២.៧.វេយ្យាករណ៍៖ សញ្ញាសម្ព័ន្ធ វង់ក្រចក តង្កៀប.....ទំព័រ៤២-៤៤

២.៨.ការស្តាប់៖ រឿង ស្រូវ.....ទំព័រ៤៦-៤៧

២.៩.តែងសេចក្តី៖ សំណេរព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍.....ទំព័រ៤៧-៤៨

៣. កេរដំណែលរបស់ជាតិ

៣.១. បំណិន៖ កាព្យមាត្រ ឬរង្វាស់កាព្យ.....ទំព័រ៥០-៥១

៣.២.បំណិន៖ ចំណាប់ចួន ផ្ទួន រណ្តំ.....ទំព័រ៥២-៥៤

៣.៣.អំណាន៖ សោភណភាពប្រាសាទបាយ័ន.....ទំព័រ៥៥-៥៦

៣.៤.វេយ្យាករណ៍៖ សព្វនាមចង្អុល.....ទំព័រ៥៧

៣.៥.បំណិន៖ និមិត្តរូប.....ទំព័រ៥៨-៥៩

៣.៦.អំណាន៖ ប្រាសាទសិលាខ្មែរ.....ទំព័រ៦០-៦១

៣.៧.អំណាន៖ រថាំត្រុដិ.....ទំព័រ៦២-៦៣

៣.៨.ការស្តាប់៖ ច្បាប់ស្រី.....ទំព័រ៦៤

៣.៩.តែងសេចក្តី៖ តែងកំណាព្យ.....ទំព័រ៦៧-៦៨

៤. សេចក្តីថ្លៃថ្នូរ

៤.១. វេយ្យាករណ៍៖ នាមករណ៍ឬករណនាម.....ទំព័រ៧០

៤.២. វេយ្យាករណ៍៖ ការប្រើប្រាស់រាជសព្ទ សង្ឃសព្ទ.....ទំព័រ៧១-៧៣

៤.៣. អំណាន៖ រឿងក្មេងកំព្រានិងព្រះចៅផែនដី.....ទំព័រ៧៤-៧៥

៤.៤. វេយ្យាករណ៍៖ នាមការក៍ឬការកនាម.....ទំព័រ៧៦

៤.៥. បំណិន៖ កាលអាកាស.....ទំព័រ៧៧-៧៩

៤.៦. អំណាន៖ រឿងកុំត្រាប់តាមបង.....ទំព័រ៨០-៨៣

៤.៧. អំណាន៖ រឿងព្រះរាជកុមារ៤អង្គត្រូវជ្រើសយកមួយអង្គសោយរាជ្យ.....ទំព័រ៦៤-៨៦

៤.៨. ការស្តាប់៖ រឿងស្តេចព្រហ្មទត្តនិងស្តេចស្រមោចខ្មៅ.....ទំព័រ៨៦-៨៧

៤.៩. តែងសេចក្តី៖ សំណេរអត្ថបទដោយប្រើរាជសព្ទ.....ទំព័រ៨៩-៩០

៥. ពលរដ្ឋល្អ

៥.១. អំណាន៖ យុវជនកម្ពុជា.....ទំព័រ៩២-៩៣

៥.២. វេយ្យាករណ៍៖ សញ្ញាជើងក្រែក(+).....ទំព័រ៩៤-៩៦

៥.៣. វេយ្យាករណ៍៖ កិរិយាសុទ្ធ កិរិយាហេតុ.....ទំព័រ៩៧-៩៨

៥.៤. អំណាន៖ រឿងគង់ហ៊ាន.....ទំព័រ៩៩-១០២

៥.៥. ការស្តាប់៖ រឿងខ្ញុំខុសហើយ.....ទំព័រ១០៥-១០៦

៥.៦. តែងសេចក្តី៖ បំពេញទម្រង់បែបបទប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ.....ទំព័រ១០៦-១១០

មេរៀនទី១៖ សេចក្តីស្រឡាញ់

១.១.បំណិន៖ ព្រេងកថា

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ហេតុអ្វីបានជាមនុស្សត្រូវតែមានសេចក្តីស្រឡាញ់?

ក. ព្រោះមនុស្សមានមនោសញ្ចេតនា **☑ខ. ព្រោះមនុស្សមិនអាចរស់តែម្នាក់ឯងបានទេ**

គ. ព្រោះវាជាច្បាប់ធម្មជាតិ **ឃ. ព្រោះវាជាតថភាពនៃសង្គម**

១. សេចក្តីស្រឡាញ់មាន....៖

ក. ស្រឡាញ់ឪពុកម្តាយ ខ. ស្រឡាញ់បងប្អូន

គ. ស្រឡាញ់ប្រទេសជាតិ ឃ. ចម្លើយទាំងបីខាងលើ

២. រឿងដែលទាក់ទងប្រវត្តិភូមិ ស្រុក ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ តួអង្គជាបុគ្គលអស្ចារ្យជា.....៖

ក. និទានកថា ខ. ទេវកថា គ. ព្រេងកថា ឃ. ប្រលោមកថា

៣. រឿង"កំណើតទីក្រុងភ្នំពេញ" ជាប្រភេទរឿងបែប....<u>លើកលែងតែ៖</u>

ក. និទានកថា ខ. ទេវកថា គ. ព្រេងកថា ឃ. ល្បើកកថា

៤. តើរឿង"ភ្នំសុពណ៌កាលី" ជាប្រភេទរឿងបែបអ្វី?

ក. និទានកថា ខ. ទេវកថា គ. ព្រេងកថា ឃ. ល្បើកកថា

៥. តើចំណុចត្រង់ណាដែលបញ្ជាក់ថារឿង"ភ្នំសុពណ៌កាលី" ជារឿងបែបព្រេងកថា?

ក. បង្ហាញពីប្រភពកំណើតភ្នំសុពណ៌កាលី ខ. បង្ហាញពីទីតាំងភូមិសាស្ត្រភ្នំ

គ. បង្ហាញពីទីកន្លែងនិងឈ្មោះពិតរបស់ភ្នំ ឃ. ចម្លើយទាំងបីខាងលើ

៦. តើរឿងប្រាសាទបាយ័ង់កោរ ជារឿងបែបអ្វី?

ក. និទានកថា ខ. ទេវកថា គ. ព្រេងកថា ឃ. ល្បើកកថា

ខ. សំណួរផ្គូផ្គង

ចូរប្អូនផ្គូផ្គងចំណងជើងរឿងនៅតារាង(ក)ទៅតារាង(ខ)រួចបំពេញចម្លើយនៅតារាង(គ)

ក	ខ	គ
១. រឿងប្រាសាទតាព្រហ្មក្នុងខេត្តតាកែវ	ក.និទានកថា	១. ⟶ ខ
២. រឿងអ្នកតាទឹកអ្នកតាភ្នំ	ខ.ព្រេងកថា	២. ⟶
៣.រឿងល្បើកជុចនិងត្រី	គ.ប្រលោមកថា	៣. ⟶
៤. រឿងសូជាត	ឃ.ទេវកថា	៤. ⟶
៥. រឿងចចក	ង.ល្បើកកថា	៥. ⟶
៦. រឿងឆ្កែមើលឃើញខ្មោច		៦. ⟶
៧. រឿងទន្សាយនិងខ្យង		៧. ⟶
៨. រឿងប្រាសាទអង្គរវត្ត		៨. ⟶

១.២.វេយ្យាករណ៍៖ ចំណុចរាយ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ហេតុអ្វីបានជាអ្នកត្រូវរៀនពីចំណុចរាយ?

ក. ងាយស្រួលដឹងពីរបៀបប្រើ **ខ. ព្រោះគេតែងប្រើវាញឹកញាប់**

☑គ. ចៀសវាងប្រើខុសក្បួនវេយ្យាករណ៍ **ឃ. ចម្លើយទាំងបីខាងលើ**

១. ចំណុចតូចៗដែលគេប្រើសម្រាប់ចង់ឱ្យបន្ថែមឬបង្ហាញអ្វីមួយ ជានិយមន័យរបស់...៖

ក. ចំណុចរាយ ខ. បំពេញចន្លោះ គ. ពាក្យត្រូវបន្ថែម ឃ. កន្លែងត្រូវដកចេញ

២. “គោត្តនាម នាម.....ភេទ.....ជាតិ.....សញ្ជាតិ”គេប្រើចំណុចរាយដើម្បី.....៖

ក. បង្ហាញកន្លែងដែលត្រូវបំពេញ ខ. បង្ហាញភាពភ័យតក់ស្លុត

គ. បង្ហាញសម្តីមិនទាន់ចប់ត្រូវគេនិយាយកាត់ ឃ. ខាងដើមនិងខាងចុងមិនលើកយកមកនិយាយ

៣. “នៅផ្ទះខ្ញុំមានដាំរុក្ខជាតិហូបផ្លែមួយចំនួនដូចជា ដើមស្វាយ ចេក មៀន ក្រូច.....។” គេប្រើចំណុចរាយដើម្បីបង្ហាញ....៖

ក.កន្លែងត្រូវបំពេញ ខ. នៅមានតទៀត គ. កន្លែងត្រូវបំពេញ ឃ. កន្លែងត្រូវដកចេញ

៤. កាលដើមឡើយ មានបងប្អូនពីរនាក់ ម្នាក់ឈ្មោះពញាជ័យនិងម្នាក់ទៀតឈ្មោះពញាសួស។ ពួកគាត់បានទីលំនៅប៉ែកខាងនិរតីភ្នំប្រសិទ្ធ៏។ ពួកគាត់ប្រកបរបរដាំត្រសក់លក់។[...] គេប្រើចំណុចរាយដើម្បី...៖

ក. បង្ហាញសម្តីមិនទាន់ចប់ត្រូវគេនិយាយកាត់ ខ. បង្ហាញភាពភ័យតក់ស្លុត

គ. បង្ហាញពីអ្វីដែលគេលើកយកនិយាយតែត្រឹមនេះ ឃ. បង្ហាញកន្លែងដែលត្រូវបំពេញ

៥. ខ្យល់បក់វូៗ ! ភ្លៀងធ្លាក់ស្រិបៗ។ តារាដើរទ្រេតទ្រោត ព្រោះទប់នឹងកម្លាំងខ្យល់បក់បោកនឹងភាពងងឹតមើលអ្វីមិនយល់។ គ្រាន់តែដើរហួសរបងវត្តបន្តិចត្រង់ដើមពោធិ៍ស្រាប់តែឮដូចសំឡេងថ្ងូរ។តារាងាកក្រោយស្រាប់តែឃើញស្រមោលស្នងៗនៅជិតបង្គើយ ! ពុទ្ធោ !..... ស្អីគេ ?គេប្រើចំណុចរាយដើម្បី....៖

ក. បង្ហាញសម្តីមិនទាន់ចប់ត្រូវគេនិយាយកាត់ ខ. បង្ហាញភាពភ័យតក់ស្លុត

គ. បង្ហាញពីអ្វីដែលគេលើកយកនិយាយតែត្រឹមនេះ ឃ. បង្ហាញកន្លែងដែលត្រូវបំពេញ

៦. សុភាពលឿនឡើង ទៅថ្នាក់ ព្រោះថ្ងៃនេះយើងត្រូវ.....។ ត្រូវធ្វើអ្វី ?ខ្ញុំមិនបានដឹងទេ! ឯងប្រាប់គ្នាផង ! គេប្រើចំណុចរាយដើម្បី...៖

ក. បង្ហាញសម្តីមិនទាន់ចប់ត្រូវគេនិយាយកាត់ ខ. បង្ហាញភាពភ័យតក់ស្លុត

គ. បង្ហាញពីអ្វីដែលគេលើកយកនិយាយតែត្រឹមនេះ ឃ. បង្ហាញកន្លែងដែលត្រូវបំពេញ

ខ. សំណួរបំពេញចន្លោះ

ចូរប្អូនយកពាក្យក្នុងប្រអប់ខាងក្រោមទៅបំពេញចន្លោះត្រង់ចំណុចរាយខាងក្រោមឱ្យបានត្រឹមត្រូវ៖

មជ្ឈដ្ឋាន	បង្កើន	យើងគប្បី	**រស់នៅ**	ប្រយោជន៍	ចែករំលែក

មនុស្សម្នាក់ៗមិនអាច..**រស់នៅ**.....ឯកឯងបានទេ គឺត្រូវប្រាស្រ័យទាក់ទងជាមួយ.....ជុំវិញ ជាពិសេស.....និងសង្គម។ ការជួយគ្នាទៅវិញទៅមកកាន់តែ.....សេចក្តីស្រឡាញ់និងសាមគ្គីភាព។ .....ថែរក្សាស្មារតីចែករំលែក ក្នុងន័យជួយ.....បទពិសោធនិងផ្តល់ផល.....គ្នាទៅវិញទៅមក។

១.៣.អំណាន៖ ប្រាសាទស្វាយអង្គ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើប្រាសាទស្វាយអង្គស្ថិតក្នុងខេត្តណា?

ក. ព្រៃវែង ខ. កណ្តាល គ. កំពង់ចាម ☑ឃ. ស្វាយរៀង

១. តើរឿងប្រាសាទស្វាយអង្គដកស្រង់ចេញពីណា?

ក. សៀវភៅភាសាខ្មែរថ្នាក់ទី៧ ខ. សៀវភៅប្រជុំរឿងព្រេងខ្មែរ

គ. សៀវភៅទាក់ទងនឹងប្រាសាទ ឃ. សៀវភៅប្រជុំរឿងព្រេងខ្មែរទាក់ទងនឹងប្រាសាទ

២. តើរឿង"ប្រាសាទស្វាយអង្គ"មានទំនាក់ទំនងអ្វីជាមួយក្រសួងវប្បធម៌ វិចិត្រសិល្បៈ?

ក. ព្រោះប្រាសាទត្រូវស្ថិតនៅក្នុងក្រសួងវប្បធម៌ ខ. ព្រោះប្រាសាទខាងក្រសួងវប្បធម៌ជាអ្នកស្រាវជ្រាវ

គ. ព្រោះប្រាសាទជាសម្បត្តិបេតិកភណ្ឌ ឃ. ព្រោះប្រាសាទជាកេរដំណែលរបស់ខ្មែរ

៣. រឿងប្រាសាទស្វាយអង្គជាប្រភេទរឿងបែប.....៖

ក. និទានកថា ខ. ល្បើកកថា គ. ព្រេងកថា ឃ. ទេវកថា

៤. ហេតុអ្វីបានជារឿង"ប្រាសាទស្វាយអង្គ"ស្ថិតក្នុងប្រភេទរឿងបែបព្រេងកថា?

ក. ទាក់ទងនឹងភូមិសាស្ត្រប្រទេសកម្ពុជា ខ. ព្រោះមានតួអង្គអស្ចារ្យ

គ. ព្រោះមានព្រឹត្តិការណ៍ទាក់ទងនឹងប្រវត្តិសាស្ត្រ ឃ. ចម្លើយទាំងបីខាងលើ

៥. តើរឿងនេះមានតួអង្គប៉ុន្មាន?

ក. ៥នាក់ ខ. ៦នាក់ គ.៧នាក់ ឃ. ៨នាក់

៦. ការស្ម័គ្រចិត្តចូលបម្រើកងទ័ពរបស់តួអង្គបុរសសំរឹទ្ធក្នុងរឿង"ប្រាសាទស្វាយអង្គ"បានបង្ហាញពីទឹកចិត្តរបស់បុរសសំរឹទ្ធដូចម្តេច?

ក. ជាអ្នកស្នេហាជាតិ ទឹកដី ខ. ជាអ្នកមានឆន្ទៈខ្ពស់ក្នុងការងារ

គ. ជាអ្នកគោរពកាតព្វកិច្ច ឃ. ជាអ្នកស្មោះត្រង់ ស្រឡាញ់ប្រជារាស្ត្រនិងទឹកដី

៧. ហេតុអ្វីបានជាបុរសសំរឹទ្ធក្នុងរឿង"ប្រាសាទស្វាយអង្គ"ច្រឡំសម្លាយនៅអង្គរ?

ក. ព្រោះចូលសម្រាកនៅអង្គរ ខ. ព្រោះងងឹតពេកមើលមិនច្បាស់

គ. ព្រោះសម្លាយមានលក្ខណៈដូចគ្នា ឃ. ព្រោះប្រញាប់ត្រឡប់មកផ្ទះវិញ

៨. អបិយជំនឿដែលទាក់ទងនឹងរឿង"ប្រាសាទស្វាយអង្គ"ត្រង់.....<u>លើកលែងតែ</u>៖

ក. ព្រះចៅអធិការចូលទីវង្គត ខ. ដើមស្វាយកាប់រលំហើយនៅតែលាស់ស្លឹក

គ. ឮសំឡេងភ្លេងពិណពាទ្យរាល់យប់ ឃ. ឃើញខ្មោចលងរាល់យប់

៩. បច្ចុប្បន្ន ប្រាសាទស្វាយអង្គក្លាយជា.....<u>លើកលែងតែ</u>៖

ក. កន្លែងសក្ការៈបូជា ខ. រមណីយដ្ឋានវប្បធម៌

គ. ភូមិអ្នកស្រុករស់នៅ ឃ. ជាកន្លែងដែលត្រូវគេបោះបង់ចោល

១០. តើកូនខ្មែរគ្រប់រូបត្រូវធ្វើដូចម្តេច ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់សម្បត្តិបេតិកភណ្ឌជាតិ?

ក. ចូលរួមកសាងប្រាសាទឡើងវិញ ខ. ចូលរួមថែរក្សា ការពារប្រាសាទ

គ. ចូលរួមផ្សព្វផ្សាយពីប្រាសាទ គ. ចូលរួមស្រាវជ្រាវបន្ថែមពីប្រាសាទ

ខ. សំណួរស្រាវជ្រាវ

១. ចូរប្អូនគូរផែនទីប្រាសាទស្វាយអង្គឱ្យបានត្រឹមត្រូវ តាមផែនទីក្នុងយូធូប?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

២. ចូរប្រៀបធៀបជំនឿអរូបិយនៅសម័យមុនដោយផ្អែកលើរឿងប្រាសាទស្វាយអង្គ និងសម័យបច្ចុប្បន្ន។

សម័យមុន	**សម័យបច្ចុប្បន្ន**
ឧ. ជំនឿលើបារមីនៅក្នុងទីវត្តអារាម។	**ជំនឿលើបារមីព្រះសង្ឃដែលចេះប្រស់ព្រំសិរីសួស្តី។**

៣. ហេតុអ្វីបានជារឿង"ប្រាសាទស្វាយអង្គ"គ្មានឈ្មោះអ្នកនិពន្ធ? ចូរបកស្រាយឱ្យបានត្រឹមត្រូវ។

.....

.....

.....

.....។

គ. សំណួរផ្គូផ្គង

ចូរប្អូនផ្គូផ្គងន័យក្នុងតារាង(ក)ទៅនឹងមេពាក្យក្នុងតារាង(ខ)រួចសរសេរចម្លើយនៅតារាង(គ)៖

ក	ខ	គ
១.(ន.)ភាពនៃសេចក្តីអង់អាច ហ៊ាន សេចក្តីមោះមុត។	ក.សន្ទត	១. ⟶ ង
២.(កិ.) ស្រុះស្រួលជានានឹងគ្នាដើម្បីធ្វើអ្វីមួយ។	ខ.លន្លង់លន្លោច	២. ⟶
៣.(ន.) បង្វែចដែលវែចស្តាយ។	គ.ស៊ុបទ្រុប	៣. ⟶
៤.(គុ.) ដែលស្រងេះស្រងោច។	ឃ.ស្មោះស្ម័គ្រ	៤. ⟶
៥.(គុ.) ដែលទ្រុបទ្រុល ស្លុប។	ង.សមត្ថភាព	៥. ⟶
៦.(កិ.) ប្តេជ្ញា សន្យា អនុម័ត យល់ព្រមជាមួយ។	ច.រាតត្បាត	៦. ⟶
៧.(កិ.) រុករានយករបស់អំពីអ្នកនេះខ្លះអ្នកនោះខ្លះដោយ	ឆ. សម្តាយ	៧. ⟶
ទទូចឱ្យខានតែបាន។	ជ. សេនាសន:	៨. ⟶
៨. (ន.) ស្ត្រីដែលជាអ្នកមើលថែទាំផ្ទះសម្បែងប្តីនិងកូន។	ឈ. ប្រពន្ធ	៩. ⟶
៩. (ន.) កន្លែងគោរពបូជា។		

១.៤.បំណិន៖ តម្លៃអប់រំនៅក្នុងរឿង

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើពាក្យថា"អប់រំ"មានន័យដូចម្តេច?

ក. ដាស់តឿន ប្រៀនប្រដៅ **ខ. ណែនាំ ឱ្យដំបូន្មាន**

គ. ទូន្មាន ឱ្យឱវាទ **☑ឃ. ចម្លើយទាំងបីខាងលើ**

១. គំនិតទូន្មាន ប្រៀនប្រដៅរបស់អ្នកនិពន្ធតាមរយៈស្នាដៃខ្លួនៗ ជានិយមន័យរបស់.....៖

ក. ទេវកថា ខ. ព្រឹត្តិការណ៍ក្នុងរឿង

គ. តម្លៃអប់រំនៅក្នុងរឿង ឃ. ព្រេងកថា

២. រឿង"កុកនិងក្អែក"បានបង្ហាញចំណុចល្អដើម្បីឱ្យសិក្សាយកតម្រាប់តាមត្រង់.....<u>លើកលែងតែ</u>៖

ក. ការណែនាំដល់អ្នកជិតខាងឱ្យធ្វើអំពើល្អ ខ. ចេះជួយគ្នាក្នុងគ្រាមានអាសន្ន

គ. ត្រូវប្រកបរបរកសិតាមសម្មាអាជីវៈ ឃ. ណែនាំអ្នកជិតខាងឱ្យប្រកបរបរទុច្ចរិត

៣. រឿង"កុកនិងក្អែក"បានបង្ហាញចំណុចមិនល្អរបស់តួអង្គដើម្បីឱ្យអ្នកសិក្សាបោះបង់ចោលត្រង់៖

ក. ការប្រកបរបរទុច្ចរិត ខ. ការប្រកបរបរសុចរិត

គ. ការមិនចេះជួយគ្នាទៅវិញទៅមក ឃ. ការណែនាំមិត្តឱ្យដើរផ្លូខុស

៤. ហេតុអ្វីបានជានៅក្នុងរឿងនីមួយៗអ្នកនិពន្ធបង្កប់នូវតម្លៃអប់រំ?

ក. ព្រោះចង់ឱ្យអ្នកសិក្សាត្រិះរិះពិចារណា ខ. ព្រោះចង់ឱ្យអ្នកសិក្សាយល់ពីខ្លឹមសាររឿង

គ. ព្រោះធ្វើឱ្យដំណើររឿងមានស្ថានភាពតឹងតែង ឃ. ព្រោះធ្វើឱ្យដំណើររឿងមានភាពទាក់ទាញ

៥. តម្លៃអប់រំនៅក្នុងរឿងដើមកំណើតរន្ធៈចង់បង្ហាញពី៖

ក. សេចក្តីព្យាយាមនិងប្រាជ្ញាឈ្លាសវៃ ខ. ភាពក្រៃវក្រោធតែងបរាជ័យ

គ. ការគោរពតាមពាក្យសន្យា ឃ. ចម្លើយទាំងបីខាងលើ

៦. តម្លៃអប់រំនៅក្នុងរឿងមានសារៈសំខាន់ណាស់សម្រាប់.....<u>លើកលែងតែ</u>៖

ក. អ្នកអាន ខ. អ្នកសិក្សា គ. អ្នកធ្វើការ ឃ. អ្នកទស្សនា

ខ. លំហាត់

ចូរប្អូនរកតម្លៃអប់រំពីអត្ថបទដកស្រង់ខាងក្រោម៖

១.រឿងចង្កឹះមួយបាច់

យូរលង់ណាស់មកហើយ មានគ្រួសារមួយមានតែឪពុកចាស់ជារានិងកូនប្រុសបួននាក់។ បន្ទុកក្នុងការចិញ្ចឹមគ្រួសារ បានធ្លាក់ទៅលើឪពុកទាំងស្រុង។ ខ្លួនកាន់តែចាស់កម្លាំងទ្រុឌទ្រោម។ ណាមួយបញ្ហាជីវភាពលំបាក ណាមួយកូនទាំងបួននាក់មិនសូវចេះស្រឡាញ់គ្នា តែងតែឈ្លោះប្រកែកគ្នាស្ទើរវាល់ថ្ងៃ។ មិនយូរប៉ុន្មាន ឪពុកក៏ធ្លាក់ខ្លួនឈឺជាទម្ងន់។ ថ្ងៃមួយឪពុកបានហៅកូនទាំងអស់មកជិតគាត់ រួចគាត់ហុចចង្កឹះទៅឱ្យកូនម្នាក់មួយៗ។ គាត់បង្គាប់ឱ្យកូនទាំងបួនកាច់ចង្កឹះនោះ ចង្កឹះក៏បាក់ដោយងាយ។ បន្ទាប់មក គាត់ហុចចង្កឹះមួយបាច់ទៅឱ្យកូនគាត់កាច់ម្តងម្នាក់ តែកូនៗកាច់មិនបាក់ឡើយ។ ឃើញដូចនេះឪពុកនិយាយថា៖” កូនមើល ! ចង្កឹះមួយគេអាចកាច់បាក់យ៉ាងងាយ តែចង្កឹះច្រើនរួមគ្នា គេមិនអាចកាច់បាក់ទេ”។

ក្រោយមកឪពុកក៏លាចាកលោកនេះទៅ។ កូនទាំងបួននាក់យំសោកស្តាយឪពុក ហើយមានវិប្បដិសារីយ៉ាងខ្លាំងចំពោះកំហុសខ្លួន។ ចាប់ពីពេលនោះមក ពួកគេឈប់ឈ្លោះប្រកែកគ្នា ហើយស្រឡាញ់គ្នា មើលថែរក្សាគ្នា រួមកម្លាំងគ្នាកសាងជីវភាពសមតាមបំណងរបស់ឪពុក។

(ដកស្រង់ និងកែសម្រួលពីសៀវភៅរឿងនិទានក្រសួងអប់រំ ១៩៨២)

.....

.....

.....

.....។

២. រឿងខ្លានិងតេពីរ

មានថ្ងៃមួយ តេពីរចាប់បានត្រីមួយពីក្នុងបឹង។ វាចែកគ្នាមិនដាច់ស្រេចសោះ។ តេទាំងពីរសុទ្ធតែចង់បានចំណែកខាងក្បាលដូចគ្នា ព្រោះគេយល់ថា ខាងក្បាលមានសាច់ច្រើន។ ពេលនោះខ្លាមួយដើរមកដល់ ហើយសួរពីដំណើររឿងដែលតេទាំងពីរឈ្លោះគ្នា។ ពេលស្តាប់តេទាំងពីររៀបរាប់រឿងរ៉ាវនៃជម្លោះរួចហើយ ខ្លាធានាខ្លួនជាអ្នកចែកត្រី។ ខ្លាកាត់ត្រីជាបីចំណែក គឺក្បាល ខ្លួន និងកន្ទុយ។ កំណាត់ខាងខ្លួនមានសាច់យ៉ាងច្រើន។ ខ្លាហុចក្បាលទៅឱ្យតេទីមួយ ហុចកន្ទុយត្រីទៅឱ្យតេទីពីរ ហើយស្រដី៖” អ្នកខាងនេះបានខាងក្បាល ហើយអ្នកខាងនោះបានកន្ទុយ ចំណែកខ្ញុំយកកំណាត់ខ្លួននេះហើយ។ ពោលរួចខ្លាកាន់ចំណែកខ្លួនដើរចេញទៅបាត់។ តេទាំងពីរនឹកស្តាយក្រោយគ្រប់គ្នា។

(ដកស្រង់និងសម្រួលពីសៀវភៅអក្សរសិល្ប៍ថ្នាក់ទី៩ ក្រសួងអប់រំ ១៩៨៨)

.....

.....

.....។

៣. បឹងទន្លេសាបជាតំបន់ដីសើមមួយយ៉ាងសំខាន់

ដីប្រហែល ៧0% នៃតំបន់នេះជាព្រៃលិចទឹកមានរុក្ខជាតិដុះច្រើនប្រភេទ។ ស្ថានប្រព័ន្ធនេះជាសម្បុក និងជម្រកយ៉ាងសំខាន់សម្រាប់បក្សាបក្សីទឹកនិងត្រីគ្រប់ប្រភេទ។ ម្យ៉ាងទៀត ដោយស្ថានប្រព័ន្ធនេះសម្បូរព្រៃលិចទឹក ទើបធ្វើឱ្យតំបន់នេះអាចចៀសផុតពីព្យុះនានាព្រមទាំងអាចទប់ស្កាត់ ការហូរច្រោះដី។ ព្រៃលិចទឹកនៃបឹងទន្លេសាបមានសារៈសំខាន់ណាស់សម្រាប់កំណើតជីវចម្រុះ ដូចជាត្រី បក្សីទឹក និងផ្តល់ឈើសម្រាប់ប្រយោជន៍ច្រើនយ៉ាង។

(ដកស្រង់និងកែសម្រួលពីឯកសារណែនាំគ្រូបង្រៀន ស្តីពីការអប់រំបរិស្ថានបឹងទន្លេសាបឆ្នាំ ២00៦)

.....

.....

.....។

១.៥.វេយ្យាករណ៍៖ ល្បះបញ្ជាក់

ក.សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើល្បះដែលមនុស្សគ្រប់រូបប្រើរាល់ថ្ងៃ មានប៉ុន្មានបែប?

ក. ៣បែប **☑ខ. ៤បែប** **គ. ៥បែប** **ឃ. ៦បែប**

១. តើល្បះប្រាប់ព័ត៌មាន ឬព្រឹត្តិការណ៍ផ្សេងៗ ព្រមទាំងបញ្ចប់ដោយសញ្ញាខណ្ឌ ជាល្បះអ្វី?

ក. ល្បះឧទាន ខ. ល្បះបញ្ជាក់ គ. ល្បះសំណួរ ឃ. ល្បះបញ្ជា

២. តើល្បះណាដែលអ្នកតែងតែសួបញ្ជាក់ពីអ្វីមួយពីម៉ាក់ ប៉ាឬមិត្តភក្តិ?

ក. ល្បះឧទាន ខ. ល្បះបញ្ជាក់ គ. ល្បះសំណួរ ឃ. ល្បះបញ្ជា

៣.”សូមពាក់មួយសុវត្ថិភាពនៅពេកបើកបរ !” តើនេះជាល្បះអ្វី?

ក.ឧទាន ខ. បញ្ជាក់ គ. បញ្ជា ឃ. សំណួរ

៤.”ថ្ងៃចន្ទយើងត្រូវប្រឡងភាសាខ្មែរ។” តើនេះជាល្បះអ្វី?

ក. បញ្ជាក់ ខ. ឧទាន គ. បញ្ជា ឃ. ល្បះសំណួរ

៥. អូយ ! ហេតុអ្វីបានជាជាន់ជើងខ្ញុំ! តើនេះជាល្បះអ្វី?

ក. ល្បះសំណួរ ខ. ល្បះបញ្ជាក់ គ. ល្បះឧទាន ឃ. ល្បះបញ្ជា

ខ. លំហាត់អនុវត្ត

ក. តើល្បះណាខ្លះជាល្បះបញ្ជាក់? ចូរប្រើសញ្ញា(✓)ពីមុខល្បះបញ្ជាក់។

១. កុំលេងភ្លើងផ្តេសផ្តាសកូន ប្រយ័ត្នឆេះព្រៃ !

២. ដោយសារប្រឡាយនេះ ឆ្នាំក្រោយឃុំយើងនឹងមានទឹកធ្វើស្រែបរិបូណ៌។

៣. ហេតុអ្វីបានជាមីងមិនយកកូនទៅចាក់ថ្នាំ?

៤. យុវជនជាសសរទ្រូងនៃប្រទេសជាតិ។

៥. ស្អែកនេះ យើងនឹងធ្វើសំណួរសរសេរ។

៦. អូយ ! ម៉ែចបានជាជាន់ជើងខ្ញុំ !

៧. ខ្ញុំកំពុងធ្វើលំហាត់គណិតវិទ្យា។

ខ. ចូរតែងល្បះបញ្ជាក់ឱ្យបាន ៥ល្បះ។

ឧទាហរណ៍៖ នៅពេលបញ្ចប់ការសិក្សាពីវិទ្យាល័យ ខ្ញុំនឹងរៀនខាងវិស្វកម្ម។

.....

.....

.....

.....

.....

១.៦.អំណាន៖ យើងត្រូវគោរពទង់ជាតិ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើគេបង្កើតទង់ជាតិក្នុងគោលបំណងអ្វី?

☑ក. តំណាងឱ្យប្រទេសនីមួយៗ **ខ. តំណាងឱ្យបុព្វបុរស**

គ. ឱ្យស្គាល់ប្រទេស **ឃ. សម្រាប់គោរពជាតិសាសន៍ខ្លួន**

១. តើទង់ជាតិខ្មែរជានិមិត្តរូបអ្វី?

ក. ជនជាតិខ្មែរ ខ. បុព្វបុរសខ្មែរ

គ. ដួងវិញ្ញាណក្ខន្ធប្រជាជនខ្មែរ ឃ. ប្រទេសកម្ពុជា

២. តើអត្ថបទអំណាន"យើងត្រូវគោរពទង់ជាតិ" ដកស្រង់ចេញពីសៀវភៅអ្វី?

ក. សៀវភៅសរសេរតាមសូត្រខ្មែរ ខ. សៀវភៅវប្បធម៌ អរិយធម៌

គ. សៀវភៅភាសាខ្មែរថ្នាក់ទី៧ ឃ. ឯកសាររបស់ក្រសួងអប់រំ

៣. តើសៀវភៅអត្ថបទអំណាន"យើងត្រូវគោរពទង់ជាតិ" និពន្ធដោយអ្នកណា?

ក. សម្តេចសង្ឃរាជជួនណាត ខ. ហង្ស ធនហាក់

គ. ប៉ា វណ្ណា គ. នូ ហាច

៤. តើចំណុចក្នុងអត្ថបទអំណាន"យើងត្រូវគោរពទង់ជាតិ" ដែលទាក់ទងនឹងសេចក្តីស្រឡាញ់ត្រង់ណា?

ក. ទង់ជាតិខ្មែរ ខ. និមិត្តរូបទង់ជាតិខ្មែរ

គ. ប្រជាពលរដ្ឋចូលរួមគោរពទង់ជាតិខ្មែរ ឃ. ការផ្សព្វផ្សាយពីអត្ថន័យទង់ជាតិខ្មែរ

៥. តើទង់ជាតិខ្មែរមានរាងដូចម្តេច?

ក. រាងការេ ខ. រាងចតុកោណកែង

គ. រាងបួនជ្រុងទ្រវែង ឃ. រាងចតុកោណញាយ

៦. តើទង់ជាតិខ្មែរពណ៌ខៀវជានិមិត្តរូបអ្វី?

ក. ជានិមិត្តរូបទឹកដីដ៏ធំទូលាយ ខ. ជានិមិត្តរូបសម្បត្តិធម្មជាតិដ៏ស្តុកស្តម្ភ

គ. ជានិមិត្តរូបសម្បត្តិវប្បធម៌ ឃ. ចម្លើយទាំងបីខាងលើ

៧. តើទង់ជាតិខ្មែរពណ៌ក្រហមជានិមិត្តរូបអ្វី?

ក. ជានិមិត្តរូបនៃសេចក្តីអង់អាចក្លាហាន ខ. ជានិមិត្តរូបនៃព្រលឹងជាតិខ្មែរ

គ. ជានិមិត្តរូបវប្បធម៌ អរិយធម៌ខ្មែរ ឃ. ចម្លើយទាំងបីខាងលើ

៨. តើប្រាសាទកំពូលត្រីសូល៍ ជាប្រាសាទមានកំពូលប៉ុន្មាន?

ក. កំពូល២ ខ. កំពូល៣ គ. កំពូល៤ ឃ. កំពូល៥

៩. តើរូបប្រាសាទកំពូលត្រីសូល៍ពណ៌សជានិមិត្តរូបអ្វី?

ក. ជានិមិត្តរូបវប្បធម៌ ភាពល្បីល្បាញ ខ. ជានិមិត្តរូបនៃកេតនភណ្ឌជាតិ

គ. ជានិមិត្តរូបនៃភាពរុងរឿង ឃ. ជានិមិត្តរូបវប្បធម៌ កេតនភណ្ឌ ភាពល្បីល្បាញ

១០. តើបណ្តាំរបស់អ្នកនិពន្ធចំពោះខេមរបុត្រគ្រប់រូបត្រូវធ្វើដូចម្តេចចំពោះទង់ជាតិខ្មែរ?

ក. មិនត្រូវមើលស្រាលព្រលឹងជាតិខ្មែរ ខ. មិនត្រូវមើលស្រាលលើជាតិសាសន៍ខ្លួន

គ. មិនត្រូវមើលស្រាលលើបុព្វបុរសខ្មែរ ឃ. មិនត្រូវមើលស្រាលលើទង់ជាតិខ្មែរ

១១. ប្រសិនបើកូនខ្មែរគ្រប់រូប ចូលរួមគោរពទង់ជាតិតើអាចបង្ហាញពីទឹកចិត្តដូចម្តេច?

ក. បង្ហាញពីថាមពលរួមគ្នា ខ. បង្ហាញពីសាមគ្គីភាព

គ. បង្ហាញពីការស្រឡាញ់ជាតិ ឃ. បង្ហាញពីការការពារទង់ជាតិ

១២. តើចំណុចត្រង់ណានៅក្នុងមេរៀននេះ ដែលបង្ហាញពីសេចក្តីស្រឡាញ់?

ក. ការចូលរួមគោរពទង់ជាតិ ខ. ការណែនាំឱ្យគេគោរពទង់ជាតិ

គ. បង្ហាញពីតម្លៃនៃទង់ជាតិ ឃ. ចម្លើយទាំងបីខាងលើ

១៣. ដើម្បីផលិតទង់ជាតិមួយតំណាងជាតិ តើអ្នកកំណត់រូបទង់ជាតិនិងពណ៌ដូចម្តេច?

ក. កំណត់ពីអ្វីដែលប្រទេសនីមួយៗមាន ខ. កំណត់ពីពណ៌ដែលមានអត្ថន័យច្បាស់លាស់

គ. កំណត់រូបតំណាងដែលបង្ហាញពីវប្បធម៌ ឃ. ចម្លើយខនិងគជាចម្លើយត្រឹមត្រូវ

ខ. សំណួរផ្គូផ្គង

ចូរប្អូនផ្គូផ្គងន័យរបស់ពាក្យក្នុងតារាង(ក)ទៅមេពាក្យតារាង(ខ) ចម្លើយនៅតារាង(គ)៖

ក	ខ	គ
១. (ន). ធម្មជាតិដឹងច្បាស់ពីអារម្មណ៍។	ក. កេតនភណ្ឌ	១. → ឃ
២.(ន). រូបជាគ្រឿងសម្គាល់ឬវត្ថុតំណាងអ្វីមួយ។	ខ. សុភស្តម្ភ	២. →
៣.(គុ). ដែលរឹងមាំ ដែលសម្បើមដោយទ្រព្យសម្បត្តិ។	គ. រចនា	៣. →
៤.(កិ).ច្នៃលម្អ។	ឃ. វិញ្ញាណ	៤. →
៥.(ន). របស់ដែលទុកដូចជាទង់សម្រាប់ជាតិ ឬសម្រាប់ប្រទេស វត្ថុដ៏ឧត្តុង្គឧត្តម។	ង. និមិត្តរូប	៥. →

គ. សំណួរត្រិះរិះ

១. តើអ្នកបានចូលរួមគោរពទង់ជាតិដែរឬទេ? ព្រោះអ្វី?

.....

.....

.....

.....

.....។

២. ចូរអ្នកស្រាវជ្រាវក្នុងយូធូបរកូរបរាងទង់ជាតិខ្មែរតាមសម័យកាលនីមួយៗ ដោយសរសេររៀបរាប់ពីពណ៌ទ្រង់ទ្រាយ និងរូបភាពនៅក្នុងទង់ជាតិទាំងនោះផង។



ឧទាហរណ៍៖ ទង់ជាតិខ្មែរសម័យព្រះរាជាណាចក្រកម្ពុជា(បច្ចុប្បន្ន) មានរាងបួនជ្រុងទ្រវែង មានបីពណ៌ គឺពណ៌ខៀវ ពណ៌ក្រហមនិងរូបប្រាសាទកំពូលត្រីសូល៍ពណ៌សនៅចំកណ្តាល។

.....

.....

.....

.....

.....

១.៧.ការស្តាប់៖ រឿងបងប្អូនពីរនាក់

អត្ថបទស្តាប់៖ រឿងបងប្អូនពីរនាក់

កាលពីយូរលង់ណាស់មកហើយ មានបងប្អូនប្រុសពីរនាក់ស្រឡាញ់គ្នាណាស់ពុំដែលឈ្លោះទាស់ទែងគ្នាឡើយ។ កាលណាបងប្រព្រឹត្តខុសអ្វីមួយ ប្អូនរំឭកបង បងស្តាប់និងធ្វើតាមដោយរីករាយ។ ចំណែកប្អូនក៏ដូចនោះដែរ។

នៅពេលមួយនោះប្រទេសជាតិមានសង្គ្រាមនៅព្រំដែន។ បុរសបងក៏ត្រូវបំពេញកាតព្វកិច្ចការពារជាតិ។ ពេលបងចេញទៅមិនទាន់បានប៉ុន្មានថ្ងៃផង ដោយក្តីនឹករឭកបងខ្លាំងពេក បុរសប្អូនក៏លួចរត់ទៅរកបងនៅឯសមរភូមិ។ ទៅដល់សមរភូមិ បុរសប្អូនឃើញបងកំពុងគ្រវីដាវកាប់សត្រូវយ៉ាងអង់អាចជាមួយយុទ្ធជនដទៃទៀត។ ប៉ុន្តែដោយទ័ពសត្រូវមានគ្នាច្រើនក៏ឡោមព័ទ្ធបុរសបងនិងយុទ្ធជនដទៃទៀត។ ប៉ុន្តែ ដោយទ័ពសត្រូវមានគ្នាច្រើនក៏ឡោមព័ទ្ធបុរសបងនិងយុទ្ធជនដទៃទៀតជាប់។ បុរសឃើញគ្រោះអាសន្នដល់បងប្រុសក៏គិតក្នុងចិត្ត៖"ពេលនេះគ្រោះអាសន្នដល់ជីវិតបងប្រុសអញពុំខានឡើយ ! គាត់មានប្រពន្ធ មានកូនតូចៗច្រើននាក់ ! ប្រសិនបើគាត់ស្លាប់ទៅក្មួយៗរបស់អញនឹងកំព្រាគ្មានឪពុក។ ចំណែកអញខ្លួនមួយមិនអីទេ ស្លាប់ក៏ស្លាប់ទៅចុះ ហើយក៏ចាត់ទុកជាការលះបង់ ដើម្បីជនរួមជាឈាមនិងប្រទេសជាតិរបស់អញផងដែរ....”។ គិតដូចនេះហើយបុរសប្អូនក៏កន្ត្រាក់ដាវពីខ្មោចទ័ពសត្រូវស្ទុះចូលទៅជួយបងប្រុស ហើយស្រែក៖"សុំបងប្រុសរត់យកតែរួចខ្លួនសិនចុះ ទុកឱ្យខ្ញុំជាអ្នកទប់ទល់ជាមួយសត្រូវ។ បុរសបងមិនដាច់ចិត្តដកខ្លួនថយចោលប្អូនប្រុសនិងយុទ្ធជនដទៃទៀតឡើយ។ ជាភ័ព្វល្អទ័ពជំនួយក៏មកដល់ សត្រូវបាក់ទ័ពរត់ខ្ចាត់ខ្ចាយវិនាសអន្តរាយអស់ពីមាតុភូមិនាពេលនោះទៅ។

(ដកស្រង់ពីសៀវភៅរឿងនិទានរបស់ក្រសួងអប់រំឆ្នាំ១៩៨២)

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើក្នុងរឿង"បងប្អូនពីរនាក់"មានតួអង្គទាំងអស់ប៉ុន្មាន?

ក. ៣នាក់ ខ. ៤នាក់ ☑គ. ៥នាក់ ឃ. ៦នាក់

១. តើរឿងបងប្អូនពីរនាក់ តួអង្គណាជាតួអង្គសំខាន់នៅក្នុងរឿង?

ក. តួអង្គបង ខ. តួអង្គប្អូន គ. តួអង្គកងទ័ព ឃ. តួអង្គបងនិងប្អូន

២. តើតួអង្គប្អូនជាមនុស្សដូចម្តេច?

ក. ស្មោះត្រង់ ខ. ស្រឡាញ់បងប្អូន គ. លះបង់ជីវិតខ្លួន ឃ. ចម្លើយទាំងបី

២. ហេតុអ្វីបានជាបងប្អូនទាំងពីរអស់នៅជាមួយគ្នា?

ក. មកពីកំព្រាឪពុកម្តាយ ខ. មកពីប្អូនស្រឡាញ់បងខ្លាំង

គ. មកពីបងចង់សម្រួលបន្ទុកឪពុកម្តាយ គ. មកពីប្រទេសមានសង្គ្រាម

៣. ហេតុអ្វីបានជាបងត្រូវមានភារកិច្ចចេញច្បាំង?

ក. ព្រោះជាការចាត់តាំងរបស់ព្រះមហាក្សត្រ ខ. ព្រោះប្រទេសមានសង្គ្រាម

គ. ព្រោះចូលរួមការពារទឹកដី ឃ. ព្រោះជាមេទ័ពខ្លាំងពូកែ

៤. ហេតុអ្វីបានជាប្អូនរត់ទៅសមរភូមិ?

ក. ព្រោះជួយបងកំចាត់សត្រូវ ខ. ព្រោះជួយការពារបងពីគ្រោះថ្នាក់

គ. ព្រោះចង់ការពារទឹកដី ឃ. ព្រោះស្រឡាញ់បងខ្លាំងពេក

៥. តើសកម្មភាពរបស់ប្អូនបែបនេះ អ្នកនិពន្ធបានបង្ហាញពីសេចក្តីស្រឡាញ់ចំពោះអ្នកណា?

ក. ប្រទេសជាតិនិងទឹកដី ខ. គ្រួសារនិងប្រទេសជាតិ

គ. គ្រួសារនិងប្រជាជន ឃ. គ្រួសារ ទឹកដីនិងប្រជារាស្ត្រ

៦. តើរឿងនេះមានតម្លៃអប់រំដូចម្តេច?

ក. អប់រំឱ្យចេះស្រឡាញ់បងប្អូន ខ. អប់រំឱ្យចេះស្រឡាញ់ជាតិមាតុភូមិ

គ. អប់រំឱ្យចេះស្រឡាញ់គ្រួសារ ឃ. ចម្លើយទាំងបីខាងលើ

៧. តើរឿងបងប្អូនពីរនាក់ជាប្រភេទរឿងបែបអ្វី?

ក. ព្រេងកថា ខ. ទេវកថា គ. និទានកថា ឃ. ល្បើកកថា

ខ. សំណួរត្រិះរិះ

១. តើបងប្អូនទាំងពីរនាក់នោះរស់នៅក្នុងស្ថានភាពគ្រួសារយ៉ាងដូចម្តេច?

.....

.....

.....

.....

.....

.....

.....។

២. ក្រោយពីឃើញសកម្មភាពរបស់បងកំពុងប្រយុទ្ធជាមួយសត្រូវ តើប្អូនគិតអ្វីខ្លះ?

.....
.....
.....
.....
.....។

៣. ប្រសិនបើអ្នកជាតួអង្គប្អូន តើអ្នកហ៊ានចេញមុខជួយបង ដែលកំពុងប្រយុទ្ធជាមួយសត្រូវដែរឬទេ? ព្រោះអ្វី?

.....
.....
.....
.....
.....។

៤. តើប្អូនត្រូវមានកាតព្វកិច្ចអ្វីខ្លះ ដើម្បីបង្ហាញថាប្អូនជាអ្នកស្រឡាញ់ប្រទេសជាតិមាតុភូមិ? ចូរបកស្រាយតាមកាតព្វកិច្ចនីមួយៗ។

.....
.....
.....
.....
.....
.....
..... ។

៥. តើបងប្អូនទាំងពីរមានទឹកចិត្តរួមគ្នាតែមួយ អ្នកនិពន្ធចង់បង្ហាញពីអ្វី? ចូររកសុភាសិតទាក់ទងនឹងដំណើររឿង"បងប្អូនពីរនាក់"ព្រមទាំងបកស្រាយផង។

.....
.....
.....
.....
.....
.....
.....
.....។

គ. សំណួរផ្គូផ្គង

ចូរប្អូនមើលល្បះនីមួយៗនៃដំណើរឿងក្នុងតារាង(ក) បន្ទាប់មកប្រើពាក្យត្រូវឬខុសក្នុងតារាង(ខ) ឱ្យបានត្រឹមត្រូវ៖

ក	ខ
១. បងប្រៀបដូចជាម្តាយឪពុករបស់ប្អូននៅពេលកំព្រាឪពុកម្តាយ។	ត្រូវ
២. កាតព្វកិច្ចរបស់ប្រជាពលរដ្ឋត្រូវគេចវេះពីការបម្រើក្នុងជួរកងទ័ព។	
៣. បុរសប្អូនខ្លាចក្មួយកំព្រាឪពុកក៏រត់ចូលទៅជួយបងកំពុងប្រយុទ្ធជាមួយសត្រូវ។	
៤. បងប្អូនទាំងពីរស្រឡាញ់គ្នាដោយការគោរពគ្នាទៅវិញទៅមក។	
៥. បងមិនដែលណែនាំប្អូននៅពេលឃើញប្អូនធ្វើខុសឡើយ។	
៦. បងប្អូនទាំងពីរមានស្មារតីស្នេហាគ្រួសារ ជាតិ និងប្រជាជន។	
៧. ភរិយាបងបានចូលរួមប្រយុទ្ធជាមួយខ្មាំងជាមួយស្វាមីដែរ។	
៨. បងប្អូនទាំងពីរបរាជ័យដោយត្រូវស្លាប់ទាំងពីរនៅចុងបញ្ចប់រឿង។	

១.៨.អំណាន៖ រឿងកុកនិងក្អែក

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ហេតុអ្វីបានជាអ្នកនិពន្ធរើសយកតួអង្គសត្វមកតែងជារឿង?

☑ក. ព្រោះសត្វខ្លះមានចរិតដូចមនុស្ស **ខ. ព្រោះមិនចង់ប៉ះពាល់ដល់មនុស្ស**

គ. ព្រោះចង់អប់រំដល់មនុស្សគ្រប់រូប **ឃ. ចម្លើយទាំងបីខាងលើ**

១. តើរឿង"កុកនិងក្អែក"ស្ថិតនៅក្នុងរឿងបែបអ្វី?

ក. ព្រេងកថា ខ. និទានកថា គ. ទេវកថា ឃ. ល្បើកកថា

២. ហេតុអ្វីបានជាកុកនិងក្អែកបានស្គាល់គ្នា?

ក. រកចំណីជាមួយគ្នា ខ. ជួបដោយចៃដន្យ គ. ធ្វើសម្បុកក្បែរគ្នា ឃ. សន្យាជួបគ្នា

៣. ក្រោយពីដើររកចំណីត្រឡប់ចូលសម្បុកវិញ ក្អែកនិងកុកបានសួរគ្នាពីរឿងអ្វី?

ក. របៀបប្រកបរបររកស៊ី ខ. ភាពរស់ស្រួលលើដើមស្រឡៅ

គ. រឿងហេតុដែលបានជួបប្រទះ ឃ. ឧបសគ្គនានាក្នុងការរកស៊ី

៤. តើតួអង្គ"កុកនិងក្អែក"ជាសត្វមានគំនិតដូចម្តេច?

ក. ស្របគ្នា ខ. ផ្ទុយគ្នា គ. មិនស្រុះស្រួលគ្នា ឃ. មិនឯកភាពគ្នា

៥. តើការទូន្មានរបស់កុកចំពោះក្អែក ចង់ឱ្យក្អែកក្លាយជាសត្វដូចម្តេច?

ក. សត្វដែលគ្មានបញ្ហាក្នុងជីវិត ខ. សត្វដែលមនុស្សគ្រប់រូបពេញចិត្ត

គ. សត្វដែលចេះរកស៊ីដោយសុចរិត ឃ. សត្វដែលរស់នៅមានសេចក្តីសុខ

៦. តើក្អែកមានបញ្ហាអ្វីកើតឡើងក្រោយពីមិនព្រមអនុវត្តតាមការណែនាំរបស់កុក?

ក. រស់នៅដោយស្រួលគ្មានបញ្ហា ខ. ត្រូវមនុស្សគប់បំបាក់ជើង

គ. រស់នៅយ៉ាងលំបាកព្រោះការឈឺចាប់ ឃ. រងទុក្ខវេទនាដោយសារអំពើរបស់ខ្លួន

៧. ក្រោយពីជួបបញ្ហាដល់ជីវិតរបស់ខ្លួន តើក្អែកមានអារម្មណ៍ដូចម្តេច?

ក. មានចិត្តសប្បាយរីករាយ ខ. មានចិត្តចងគំនុំនឹងមនុស្ស

គ. មានវិប្បដិសារីក្នុងចិត្ត ឃ. មានចិត្តទោមនស្ស

៨. តើកុកមានអារម្មណ៍យ៉ាងណា នៅពេលឃើញក្អែកបាក់ជើង?

ក. អាណិតដល់ជីវិតរបស់ក្អែក ខ. មិនខ្វល់ពីក្អែកព្រោះមិនស្តាប់ការណែនាំ

គ. ខឹងនឹងក្អែកដែលធ្វេសប្រហែស ឃ. ចង់ឱ្យក្អែកទទួលមេរៀនជីវិត

៩. អំណាន"រឿងកុកនិងក្អែក"មានតម្លៃអប់រំ....<u>លើកលែងតែ</u>៖

ក. ត្រូវចេះពិចារណាលើសម្តីអ្នកដទៃ ខ. ត្រូវរកស៊ីតាមសម្មាអាជីវៈ

គ. ត្រូវធ្វើអ្វីតាមចិត្តរបស់ខ្លួន ឃ. ត្រូវប្រកបរបរសុចរិត ទៀងត្រង់

១០. តើអ្នកនិពន្ធបានបញ្ចប់រឿងដូចម្តេច?

ក. ឱ្យតួអង្គទាំងពីរគ្មានគ្រោះភ័យ ខ. ឱ្យតួអង្គទាំងពីរចេះសាមគ្គីគ្នា

គ. ឱ្យក្អែករស់នៅយ៉ាងលំបាកវេទនា ឃ. ឱ្យតួអង្គក្អែករស់នៅយ៉ាងសុខស្រួល

១១. ហេតុអ្វីបានជាអ្នកនិពន្ធបញ្ចប់រឿងកុកនិងក្អែកដោយមិនឱ្យតួអង្គក្អែកស្លាប់?

ក. ព្រោះជាសត្វមានជីវិតដូចមនុស្ស ខ. ព្រោះចង់បង្ហាញពីការកស៊ីរបរទុច្ចរិត

គ. ព្រោះចង់បង្ហាញពីភាពលំបាករបស់ក្អែក ឃ. ព្រោះគ្រាន់តែឱ្យអ្នកអានពិចារណា

ខ. សំណួរផ្គូផ្គង

ចូរប្អូនផ្គូផ្គងខ្លឹមសារតារាង(ក)ទៅមេពាក្យក្នុងតារាង(ខ)រួចបំពេញនៅតារាង(គ)៖

ក	ខ	គ
១. (ន). មិត្តល្អ មិត្តត្រឹមត្រូវ។	ក. វិញ្ញាណ	១ → គ
២. (ន). របស់ដែលទុកជាទង់សម្រាប់ជាតិ។	ខ. បេតិកភណ្ឌ	២ →
៣. (ន). សភាវៈ សភាពកើតឯង។	គ. កល្យាណមិត្ត	៣ →
៤. (ន). ទ្រព្យសម្បត្តិ ឬកេរមរតកមានជាប់តមកពីខាងឪពុក។	ឃ. សម្មាអាជីវៈ	៤ →
៥. (ន). សេចក្តីអំណត។	ង. ធម្មជាតិ	៥ →
៦. (ន). ធម្មជាតិដឹងច្បាស់នូវអារម្មណ៍។	ច. កេតនភណ្ឌ	៦ →
៧. (ន)ការប្រកបរបរចិញ្ចឹមជីវិតត្រឹមត្រូវ។	ឆ. មោទនភាព	៧ →

គ. សំណួរត្រិះរិះ

១. ចូររៀបរាប់ពីរបរអកស៊ីរបស់តួអង្គកុក និងក្អែកក្នុងរឿង"កុកនិងក្អែក"។

.....

.....

.....

.....

.....។

២. តើអត្ថបទអំណានរឿង"កុកនិងក្អែក"មានប្រើចំណុចរាយដែរឬទេ? ចូរស្រង់ចំណុចរាយក្នុងរឿងធ្វើជាអំណះអំណាង។

.....

.....

.....

.....។

៣. ប្រសិនបើអ្នកជាតួអង្គក្អែកវិញ ក្រោយពីឮសម្តីកុកជាដំបូន្មាន តើអ្នកនឹងធ្វើដូចម្តេច? ព្រោះអ្វី?

.....

.....

.....

.....។

៤. ចូរអ្នកសង្ខេបរឿង"កុកនិងក្អែក"ឱ្យបានត្រឹមត្រូវតាមគំនិតសំខាន់ក្នុងរឿង។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

១.៩.តែងសេចក្តី៖ សំណេរព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍(ក្នុងរឿង)

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើព្រឹត្តិការណ៍នៅក្នុងរឿងគេចាត់ទុកជាអ្វី?

☑ក. មូលបញ្ហា ខ. រឿងរ៉ាវ គ. ចំណោទបញ្ហា ឃ. ដំណោះស្រាយ

១. តើព័ត៌មាន មានន័យដូចម្តេច?

ក. ដំណឹងទូទៅ ខ. របាយការណ៍នានា

គ. បរិយាយហេតុការណ៍ ឃ. រៀបរាប់ពីរឿងរ៉ាងផ្សេងៗ

២. តើពណ៌នា មានន័យដូចម្តេច?

ក. និយាយ ខ. ជជែក គ. អធិប្បាយ ឃ. រៀបរាប់

៣. តើពាក្យព្រឹត្តិការណ៍ មានន័យដូចម្តេច?

ក. រឿងរ៉ាងផ្សេងៗ ខ. ហេតុការណ៍អ្វីមួយ

គ. បញ្ហាដែលកើតឡើង ឃ. ចម្លើយទាំងបី

៤. តើតែងសេចក្តីត្រូវមានប៉ុន្មានចំណុច?

ក. ២ចំណុច ខ. ៣ចំណុច គ. ៤ចំណុច ឃ. ៥ចំណុច

៥. តើតែងសេចក្តី អ្នកត្រូវសរសេរអ្វីមុនគេ?

ក. តួសេចក្តី ខ. សេចក្តីបញ្ចប់ គ. សេចក្តីផ្តើម ឃ. ការបកស្រាយ

៦. ប្រសិនបើអ្នកចង់សរសេរកថាខណ្ឌព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍ក្នុងរឿង តើសេចក្តីផ្តើមអ្នកត្រូវសរសេរពីអ្វី?

ក. ព្រឹត្តិការណ៍នៃរឿង ខ. ចំណាប់អារម្មណ៍អ្នកសរសេរ

គ. ប្រភេទរឿង តួអង្គ ឃ. ប្រភេទរឿង ចំណងជើងរឿង អ្នកនិពន្ធ

៧. តើតួសេចក្តីក្នុងសំណេរព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍ត្រូវសរសេរចំណុចអ្វីខ្លះ?

ក. មុនពេលព្រឹត្តិការណ៍ ខ. ពេលព្រឹត្តិការណ៍កើតឡើង

គ. ក្រោយពេលព្រឹត្តិការណ៍កើតឡើង ឃ. រកព្រឹត្តិការណ៍សំខាន់និងព្រឹត្តិការណ៍រង

៨. តើសេចក្តីបញ្ចប់ក្នុងសំណេរកថាខណ្ឌព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍រឿង ត្រូវសរសេរពីអ្វី?

ក. ចំណាប់អារម្មណ៍អ្នកសរសេរ ខ. ទស្សនៈរបស់អ្នកសរសេរ

គ. តម្លៃអប់រំនិងចំណាប់អារម្មណ៍អ្នកសរសេរ ឃ. តម្លៃអប់រំនៅក្នុងរឿង

៩. ដើម្បីឱ្យតែងសេចក្តីមួយបានល្អ តើអ្នកត្រូវគិតទៅលើអ្វីមុនគេ?

ក. ត្រូវគិតទៅលើខ្លឹមសារនៃរឿង ខ. ត្រូវគិតលើចំណុចសំខាន់ៗនៃរឿង

គ. ត្រូវគិតលើគម្រោងតែង ឃ. ត្រូវគិតលើមូលន័យនៃរឿង

ខ. គម្រោងតែងសេចក្តី

ក. សេចក្តីផ្តើម៖

-ប្រភេទរឿង ចំណងជើងរឿង ឈ្មោះអ្នកនិពន្ធ

ខ. តួសេចក្តី៖

-រកព្រឹត្តិការណ៍សំខាន់

-រកព្រឹត្តិការណ៍រងនៅក្នុងដំណើររឿង

-សរុបព្រឹត្តិការណ៍ទាំងអស់បញ្ចូលគ្នា

គ. សេចក្តីបញ្ចប់៖

-បង្ហាញតម្លៃអប់រំក្នុងរឿង -ចំណាប់អារម្មណ៍អ្នកសរសេរ

ឃ. លំហាត់អនុវត្ត



ប្រធានៈ ចូរប្អូនសរសេរសំណេរកថាខណ្ឌព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍ក្នុងរឿងសត្វកូនលោក។

សេចក្តីអធិប្បាយ

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

(បញ្ជាក់ៈប្អូនអាចរករឿងនេះអាន នៅសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ១ ឬស្រាវជ្រាវនៅក្នុងយូធូប)

មេរៀនទី២៖ ការជួយគ្នាទៅវិញទៅមក

២.១.បំណិន៖ ទេវកថា

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើនៅក្នុងអក្សរសិល្ប៍តំណាលកថាប្រជាប្រិយ មានរឿងបែបណាខ្លះ?

ក. ទេវកថា ព្រេងកថា **ខ. ព្រេងកថា ល្បើកកថា**

គ. និទានកថា ប្រលោមកថា **☑ឃ. ទេវកថា ព្រេងកថា និទានកថា ល្បើកកថា**

១. រឿងប្រឌិត ដែលដំណើររឿងនិយាយអំពីការយល់ដឹងដំបូងរបស់មនុស្ស ពីប្រភពកំណើតនៃអាទិទេព ទេវៈ អ្នកតា មនុស្ស សត្វ រុក្ខជាតិ បាតុភូតធម្មជាតិ និងប្រភពពិធីគោរពបូជាផ្សេងៗគឺជា....៖

ក. ទេវកថា ខ. ព្រេងកថា គ. និទានកថា ឃ. ល្បើកកថា

២. តើរឿងណាខ្លះស្ថិតក្នុងប្រភេទទេវកថា? ដើមកំណើតសត្វមូស រឿងកុក និងក្អែក រឿងដើមកំណើតរន្ធៈ រឿងទីក្រុងភ្នំពេញ ។

ក. ដើមកំណើតសត្វមូសនិងដើមកំណើតរន្ធៈ ខ. រឿងដើមកំណើតសត្វមូស រឿងកុកនិងក្អែក

គ. រឿងកុកនិងក្អែក រឿងដើមកំណើតរន្ធៈ ឃ. រឿងដើមកំណើតរន្ធៈ រឿងទីក្រុងភ្នំពេញ

៣. ហេតុអ្វីបានជាអ្នកនិពន្ធយករឿង"ដើមកំណើតរន្ធៈ"ដាក់ក្នុងរឿងបែបទេវកថា?

ក. ព្រោះមានតួអង្គជាអាទិទេព ខ. ព្រោះបង្ហាញពីដើមកំណើតរន្ធៈ

គ. ព្រោះបង្ហាញពីភាពលោភលន់រាមាសូរ គ. ចម្លើយកនិងខជាចម្លើយត្រឹមត្រូវ

៤. ហេតុអ្វីបានជារឿង"អ្នកតាទឹក អ្នកតាភ្នំ"ជាប្រភេទរឿងបែបណា?

ក. ទេវកថា ខ. ព្រេងកថា គ. និទានកថា ឃ. ល្បើកកថា

៥. តើចំណុចត្រង់ណានៅក្នុងរឿង"អ្នកតាទឹក អ្នកតាភ្នំ"ជារឿងបែបទេវកថា?

ក. លើតួអង្គជាអមនុស្ស ខ. ជាប្រភពកំណើតទឹកជំនន់

ខ. លើព្រឹត្តិការណ៍រឿង ឃ. លើតួអង្គ និងប្រភពទឹកជំនន់

ខ. សំណួរត្រិះរិះ

១. តើរឿងបែបព្រេងកថា និងរឿងបែបទេវកថាមានលក្ខណៈខុសគ្នាដូចម្តេច ?

រឿងព្រេងកថា	រឿងទេវកថា
ឧទាៈ ព្រឹត្តិការណ៍ទាក់ទងនឹងប្រវត្តិសាស្ត្រ។	ព្រឹត្តិការណ៍បង្ហាញពីប្រភពកំណើតផ្សេងៗ។

២. ចូរប្អូនអានអត្ថបទខាងក្រោម តើអត្ថបទនោះជាអត្ថបទបែបទេវកថាដែរឬទេ ? ព្រោះអ្វី ?

យុវជនទាំងអស់ ទាំងស្រីទាំងប្រុស ជាកម្លាំងយ៉ាងសំខាន់ក្នុងការរួមចំណែកកសាងជាតិ។ យុវជនត្រូវមានការភ្ញាក់រឭកជានិច្ច តាំងសតិអារម្មណ៍ឱ្យប្រសើរឧត្តុង្គឧត្តមមានការសន្តោសនិងសេចក្តីស្មោះត្រង់។ ការរក្សាសាមគ្គីភាព មិត្តភាពមិនប្រមាថមើលងាយអ្នកដទៃ មិនសេពគប់ជនពាល និងមិនប្រព្រឹត្តល្បែងស៊ីសងពាលាជាលក្ខណសម្បត្តិល្អរបស់យុវជនកម្ពុជា។[....]

ចម្លើយ

.....

.....

.....

.....

.....។

៣. ចូរប្អូនរកចំណងជើងរឿងបែបទេវកថាឱ្យបានពីររឿង ដោយបកស្រាយឱ្យបានច្បាស់លាស់ពីលក្ខណៈសម្គាល់ទេវកថាក្នុងរឿងនីមួយៗ។

.....

.....

.....

.....

.....។

២.២.អំណាន៖ រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ហេតុអ្វីបានជាអ្នកនិពន្ធយករឿង"សង្គ្រាមរវាងគីង្គក់និងតាព្រហ្ម"មកសិក្សា?

☑ក. ព្រោះទាក់ទងនឹងបំណិនទេវកថា **ខ. ព្រោះទាក់ទងនឹងតួអង្គសត្វ**

គ. ព្រោះទាក់ទងនឹងប្រភពពេលភ្លៀងធ្លាក់ **ឃ. ព្រោះទាក់ទងនឹងអភូតហេតុធម្មជាតិ**

១. តើរឿងសង្គ្រាមរវាងគីង្គក់ និងតាព្រហ្ម ស្ថិតក្នុងប្រភេទអក្សរសិល្ប៍អ្វី?

ក. ទេវកថា ខ. ព្រេកថា គ. និទានកថា ឃ. ល្បើកកថា

២. តើរឿង"សង្គ្រាមរវាងគីង្គក់និងតាព្រហ្ម" អ្នកនិពន្ធដកស្រង់ចេញពីណា?

ក. ពីប្រជុំរឿងព្រេងខ្មែរភាគ១ ខ. ពីប្រជុំរឿងព្រេងខ្មែរភាគ២

គ. ពីប្រជុំរឿងព្រេងខ្មែរភាគ៣ ឃ. ពីប្រជុំរឿងព្រេងខ្មែរភាគ៤

៤. តើតួអង្គគីង្គក់តំណាងឱ្យមនុស្សប្រភេទណា?

ក. មនុស្សមានការតស៊ូក្នុងជីវិត ខ. មនុស្សចេះសាមគ្គីជាមួយមនុស្សជុំវិញខ្លួន

គ. មនុស្សចេះជួយសង្គ្រោះអ្នកដទៃ ឃ. មនុស្សទុកអ្នកដទៃជាសាច់ញាតិ

៥. តើក្រុមគីង្គក់មានគោលបំណងចង់បានអ្វី?

ក. ចង់បានទឹកភ្លៀង ខ. ចង់បានប្រជាប្រិយភាព

គ. ចង់បង្ហាញពីសមត្ថភាព ឃ. ចង់ផ្លាស់អ្នកដឹកនាំ

៦. តួអង្គទាំងនេះមានវត្តមានក្នុងរឿងសង្គ្រាមរវាងគីង្គក់ និងតាព្រហ្ម ៖ គីង្គក់ តាព្រហ្ម ទន្សាយ ឃ្មុំ ឌីម៉ាល់ <u>លើកលែងតែ</u>៖

ក. ទន្សាយ ខ. គីង្គក់ គ. ឃ្មុំ ឃ. ឌីម៉ាល់

៧. តើកត្តាអ្វីខ្លះដែលបង្ហាញថាសត្វគីង្គក់ ជាអ្នកដឹងនាំដ៏ល្អម្នាក់?

ក. កត្តាសាមគ្គីភាព ខ. កត្តាជឿជាក់

គ. កត្តាអធ្យាស្រ័យអ្នកធ្វើខុស គ. កត្តារៀបចំផែនការ

៨. ហេតុអ្វីបានជាតាព្រហ្មសុខចិត្តចុះចាញ់ការសាមគ្គីរបស់គីង្គក់?

ក. ព្រោះតាព្រហ្មត្រូវបរាជ័យនៅពេលនោះ ខ. ព្រោះតាព្រហ្មត្រូវរងរបួសជាទម្ងន់

គ. ព្រោះតាព្រហ្មគោរពសម្តីរបស់ខ្លួន ឃ. ព្រោះតាព្រហ្មចុះចាញ់ចិត្តតស៊ូរបស់ពួកគេ

៩. តើតាព្រហ្មបង្អុរទឹកភ្លៀងឱ្យតាមការសន្យាជាមួយគីង្គក់នៅពេលណា?

ក. ពេលឮសំឡេងពួកមណ្ឌុកសត្វស្រែក ខ. ពេលរដូវវស្សាជារដូវភ្លៀងធ្លាក់

គ. ពេលនឹកឃើញភាពបរាជ័យរបស់ខ្លួន ឃ. ពេលរដូវធ្វើស្រែចម្ការ

១០. តើចំណុចត្រង់ណាដែលប្រជាជនខ្មែរបានចាត់ទុកថាជាជំនឿដូចនៅក្នុងរឿង?

ក. ពេលឮសំឡេងពួកមណ្ឌុកសត្វស្រែក ខ. ពេលរដូវវស្សាជារដូវភ្លៀងធ្លាក់

គ. ពេលនឹកឃើញភាពបរាជ័យរបស់ខ្លួន ឃ. ពេលរដូវធ្វើស្រែចម្ការ

១១. តើចំណុចត្រង់ណានៅក្នុងរឿង"សង្គ្រាមរវាងគិង្គក់និងតាព្រហ្ម"បង្ហាញពីការជួយគ្នាទៅវិញទៅមក?

ក. ត្រង់តាព្រហ្មព្រមបង្អុរភ្លៀង ខ. ត្រង់ហ្វូងសត្វនិងរុក្ខជាតិទាំងអស់ទៅធ្វើសង្គ្រាម

គ. ត្រង់គីង្គក់ធ្វើឱ្យតាព្រហ្មចាញ់ ឃ. ចម្លើយទាំងបីខាងលើ

ខ. សំណួរត្រិះរិះ

១. តើទំនាស់កើតឡើងពីកត្តាអ្វីខ្លះ? ចូរបកស្រាយកត្តានីមួយៗឱ្យបានច្បាស់លាស់។

.....

.....

.....

.....

.....។

២. តើក្រុមគីង្គក់ធ្វើការទទួលបានភាពជោគជ័យតាមគោលបំណងរបស់ខ្លួនដែរឬទេ? ព្រោះអ្វី?

.....

.....

.....

.....

.....។

៣. តើកត្តាសាមគ្គីភាព ឬការជួយគ្នាទៅវិញទៅមកមានសារប្រយោជន៍ដូចម្តេចខ្លះ?

.....

.....

.....

.....

.....

.....។

៤. តើសកម្មភាពទាំងអស់របស់តួអង្គនៅក្នុងរឿង"សង្គ្រាមរវាងគីង្គក់និងតាព្រហ្ម"បានបង្ហាញពីការអប់រំដូចម្តេចខ្លះ?

.....

.....

.....

.....

..... ។

គ. សំណួរផ្គូផ្គង

ចូរប្អូនផ្គូផ្គងអត្ថន័យពាក្យក្នុងតារាង(ក)ទៅមេពាក្យនៅតារាង(ខ)រួចបំពេញក្នុងតារាង(គ)៖

ក	ខ	គ
១.(ន). ការអត់ឃ្លានគ្មានអាហារបរិភោគ។	ក. ព្យុហយាត្រា	១. → ឃ
២. (កិ). ធ្លាក់ភ្លៀង។	ខ. ភមរជាតិ	២. →
៣.(គុ.កិ). ហេតុឬដំណើរ ប្រញឹកខ្លាំង មមាញឹក ទាន់ហន់។	គ. បាណកសត្វ	៣. →
៤. (ន).ប្រភេទសត្វលោតដូចកង្កែប គីង្គក់។	ឃ. ទុរភិក្ស	៤. →
៥. (ន). សត្វល្អិតពពួកកន្លង់ ឃ្មុំ ឱម៉ាល់។	ង. បង្អុរ	៥. →
៦.(ន). ដំណើរលើកជាក្បួនទ័ពហែចេញទៅដើម្បីគោលបំណងអ្វីមួយ។	ច. មណ្ឌកសត្វ	៦. →
៧.(ន). សត្វល្អិតផ្សេងៗដូចជាដង្កូវ កណ្តូប កំពោងជាដើម។	ឆ. អាសន្ន	៧. →
៨. (គុ). បុរាណ ដែលមានក្នុងកាលពីដើម។	ជ. បាវាយណ៍	៨. →
៩. (ន). មហានទី ផ្លូវទឹកធំហូរចុះពីភ្នំ និងផ្ទារទឹកផ្សេងៗ។	ឈ. អត់ធ្មត់	៩. →
១០. (កិ). ទ្រាំ ធន់ទ្រាំ ខំទប់ អត់កំហឹង។	ញ. កាលពីបុរាណ	១០. →

សំណួរបំពេញចន្លោះ

ចូរប្អូនយកពាក្យក្នុងប្រអប់ទៅបំពេញតាមចន្លោះនីមួយៗឱ្យបានត្រឹមត្រូវ៖

ទុរភិក្ស	អត់ធន់	ស្ងិតក្រញង់	បង្អុរ	មណ្តុកសត្វ	គរឆ្អឹង	បឹង	កង្កែប	វេលាមួយ

សម័យព្រេងនាយ មាន...**វេលា**...នោះពិភពលោកកើត.....ក្តៅហួតហែងគ្រប់ទិសទី។ ព្រះពិរុណមិន.....ភ្លៀងសោះ។ ស្ទឹង ត្រពាំង ..... ព្រៃក ទន្លេរីងស្ងួតទឹកអស់។ សត្វទាំងឡាយស្លាប់.....លើគ្នា។ រុក្ខជាតិនានាក្រៀម.....។ ពួក.....មានគីង្គក់ ហ៊ីង .....ជាដើម ដែលជាសត្វពូកែ.....ក៏ស្គមនៅតែស្បែកនិងឆ្អឹង។

២.៣.ទេយ្យាករណ៍៖ ល្បះសំណួរ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើល្បះដែលអ្នកធ្លាប់និយាយរាល់ថ្ងៃមានប៉ុន្មានបែប?

ក. ២បែប **ខ. ៣បែប** **☑គ. ៤បែប** **ឃ. ៥បែប**

១. ល្បះសម្រាប់សួរកដំណឹង ឬព័ត៌មានផ្សេងៗ ហើយបញ្ចប់ដោយសញ្ញាសួរហៅថាល្បះអ្វី?

ក. សំណួរ ខ. បញ្ជាក់ គ. បញ្ជា ឃ. ឧទាន

២. តើល្បះសំណួរមានប៉ុន្មានបែប?

ក. ១០បែប ខ. ១១បែប គ. ១២បែប ឃ. ១៣បែប

៣. ម៉ាក់ទៅផ្សារ? តើជាល្បះសំណួរបែបមួយណា?

ក. ល្បះសំណួរស្របខ. ល្បះសំណួរមិនស្រប

គ. ល្បះសំណួរដោយប្រើសំនៀងសួរ ឃ. ល្បះសំណួរប្រើសព្វនាមសំណួរ

៤. តើម៉ាក់ទៅផ្សារ? តើជាល្បះសំណួរបែបមួយណា?

ក. តើ+ល្បះបញ្ជាក់ ខ. តើ+ឃ្លាសំណួរ

គ. តើ+សព្វនាមសំណួរ ឃ. តើ+ឃ្លាស្រប

៥. ម៉ាក់ទៅផ្សារឬទេ? តើជាល្បះសំណួរបែបមួយណា?

ក. ឃ្លាបញ្ជាក់+ឬទេ ខ. ល្បះបញ្ជាក់+ឬទេ គ. ល្បះសំណួរស្រប ឃ. ល្បះសំណួរមិនស្រប

៦. វាមកពីណា? តើជាល្បះសំណួរបែបមួយណា?

ក. ល្បះសំណួរ ដោយប្រើសព្វនាមសំណួរ ខ. ល្បះសំណួរដោយប្រើគុណនាមសំណួរ

គ. ល្បះសំណួរដោយបើគុណកិរិយាសំណួរ ឃ. ល្បះសំណួរស្រប

៧. ម៉ាក់រកអ្នកណា? រកសុភាព ! តើជាល្បះសំណួរបែបមួយណា?

ក. ល្បះសំណួរស្រប ខ. ល្បះសំណួរបញ្ជាក់

គ. ល្បះសំណួរមិនស្រប ឃ. ល្បះសំណួរដណ្តឹង

៨. ហេតុអ្វីបានជាសុភាពមិនទៅរៀន? តើជាល្បះសំណួរបែបណា?

ក. ល្បះសំណួរប្រើគុណនាមសំណួរ ខ. ល្បះសំណួរប្រើគុណកិរិយាសំណួរ

គ. ល្បះសំណួរប្រើសព្វនាមសំណួរ ឃ. ល្បះសំណួរដោយប្រើសំនៀងសួរ

៩. ឯងទៅបរទេសថ្ងៃណា? តើជាល្បះសណួរបែបមួយណា?

ក. ល្បះសំណួរប្រើគុណនាមសំណួរ ខ. ល្បះសំណួរប្រើគុណកិរិយាសំណួរ

គ. ល្បះសំណួរប្រើសព្វនាមសំណួរ ឃ. ល្បះសំណួរដោយប្រើសំនៀងសួរ

១០. ថ្ងៃនេះប្រឡងភាសាខ្មែរមែនទេ? តើជាល្បះសំណួរបែបមួយណា?

ក. ល្បះសំណួរស្រប ខ. ល្បះសំណួរមិនស្រប

គ. ល្បះបញ្ជាក់+ឬទេ ឃ. ល្បះសំណួរដោយប្រើសំនៀងសួរ

១១. សុជាតាចូលរៀនហើយឬនៅ? តើជាល្បះសំណួរបែបមួយណា?

ក. ល្បះសំណួរស្រប ខ. ល្បះសំណួរមិនស្រប

គ. ល្បះបញ្ជាក់+ឬទេ ឃ. ល្បះសំណួរដោយប្រើសំនៀងសួរ

១២. តើសុជាតាទៅផ្ទះដែរឬទេ? តើជាល្បះសំណួរបែបណាមួយ?

ក. ល្បះសំណួរស្រប ខ. ល្បះសំណួរមិនស្រប

គ. ល្បះបញ្ជាក់+ឬទេ ឃ. ល្បះសំណួរដោយប្រើសំនៀងសួរ

១៣. ហេតុអ្វីបានជាល្បះសំណួរមានច្រើនប្រភេទម្ល៉ះ?

ក. ងាយស្រួលសួរ ខ. ជាក្បួនវេយ្យាករណ៍ គ. ជាភាសានិយាយ ឃ. ចម្លើយទាំងបី

ខ. លំហាត់អនុវត្ត

១. ចូរអ្នកឆ្លើយនឹងល្បះសំណួរដែលមានចម្លើយ"បាទ/ចាសនិងទេ"នៃល្បះខាងក្រោមឱ្យបានសមស្របៈ

-តាបសជប់ទឹកសន្សើមឱ្យទៅជាកែងមនោរាហ៍?(.....)

-នាងអក្ខរទេវីលើកកែវមនោរាហ៍ឡើងគ្រវីតែមិនអាចហោះបាន?(.....)

-តើរាមាសូរខឹងនឹងនាងអក្ខរទេវីខ្លាំងឬទេ?(.....)

-តើរាមាសូរតាមយកត្បូងកែវមនោរាហ៍ពីនាងអក្ខរទេវី?(.....)

-រឿងដើមកំណើតរន្ទះ បង្ហាញមូលហេតុដែលនាំឱ្យកោះតមានផ្លេកបន្ទោរ ផ្គរលាន់និងរន្ទះមែនឬទេ?(.....)

២. ចូរប្អូនតែងល្បះសំណួរទាំង១១បែបឱ្យបានត្រឹមត្រូវ ១បែបតែងមួយល្បះ។

-ល្បះបញ្ជាក់ដោយប្រើសំនៀងសួរ

-តើ+ល្បះបញ្ជាក់

-ល្បះបញ្ជាក់+មែនទេ

-ប្រើសព្វនាមសំណួរ

-ប្រើគុណនាមសំណួរ

-ប្រើគុណកិរិយាសំណួរ

-ល្បះសំណួរបែប"បញ្ជាក់"

-ល្បះសំណួរបែប"ដណ្តឹង"

-ល្បះសំណួរស្របៈ

-ល្បះសំណួរមិនស្របៈ

-ល្បះបញ្ជាក់+មែនទេ

<u>ចម្លើយ</u>

ឧទាហរណ៍ៈ គ្រូបង្រៀនវេយ្យាករណ៍?(ល្បះសំណួរដោយប្រើសំនៀងសួរ)

.....

.....

.....

.....

.....

.....

.....

.....

.....។

៣. ចូរប្អូនរៀបល្បះខាងក្រោមឱ្យទៅជាល្បះសំណួរ៖

-តារាលេងបាល់ទាត់ជាមួយមិត្តភក្តិ។

-គ្រួសាររបស់ខ្ញុំបានទៅចូលរួមបុណ្យកឋិនទាននៅវត្ត។

-ចាស ! សុភាពសុខចិត្តទទួលកំហុសចំពោះរឿងនេះ។

.....

.....

.....។

២.៤.បំណិន៖ តួអង្គឯកតួអង្គរង

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើតួអង្គនៅក្នុងរឿងនីមួយៗ មានប៉ុន្មានប្រភេទ?

ក. ២ប្រភេទ **ខ. ៣ប្រភេទ** **☑គ. ៤ប្រភេទ** **ឃ. ៥ប្រភេទ**

១. តួអង្គដែលមានសកម្មភាពច្រើនប្រឈមនឹងបញ្ហាស្មុគស្មាញក្នុងដំណើររឿងគឺជាតួអង្គ.....៖

ក. ឯក ខ. រង គ. បន្ទាប់បន្សំ ឃ. រំឭក

២. តួអង្គដែលធ្វើសកម្មភាពដោយអន្លើៗហើយសកម្មភាពទាំងនោះជួយបំពេញដំណើររឿង និងលក្ខណៈសម្បត្តិតួអង្គឯកគឺជាតួអង្គ.....៖

ក. រង ខ. ឯក គ. បន្ទាប់បន្សំ ឃ. រំឭក

៣. តួអង្គដែលធ្វើសកម្មភាពហែហមដំណើររឿងឱ្យមានភាពរលូនគឺជាតួអង្គ....។

ក. បន្ទាប់បន្សំ ខ. ឯក គ. រង ឃ. រំឭក

៤. តួអង្គដែលមិនមានសកម្មភាព ឬវត្តមានក្នុងដំណើររឿង តែអ្នកនិពន្ធបានលើកឈ្មោះមកបង្ហាញក្នុងដំណើររឿងហៅថាតួអង្គ...៖

ក. រំឭក ខ. បម្រុង គ. ជំនួយ ឃ. វាយរង

៥. ហេតុអ្វីបានជាក្នុងរឿងនីមួយៗ អ្នកនិពន្ធត្រូវឱ្យមានតួអង្គឯក តួអង្គរង តួអង្គបន្ទាប់បន្សំ?

ក. ព្រោះធ្វើឱ្យដំណើររឿងមានភាពរលូន ខ. ព្រោះចង់ចែកដំណើររឿងជាដំណាក់ៗ

គ. ព្រោះចង់ឱ្យដំណើររឿងមានភាពទាក់ទាញ ឃ. ព្រោះនេះជាមនោគតិរបស់អ្នកនិពន្ធ

៦. ក្នុងរឿងសង្គ្រាមរវាងគីង្គក់ និងតាព្រហ្ម មានតួអង្គ គីង្គក់ តាព្រហ្ម ត្រីក្រាញ់ ឃ្មុំ ឌីម៉ាល់។ តើក្នុងចំណោមតួអង្គទាំងនេះតួអង្គណាជាតួអង្គឯក?

ក. គីង្គក់ ខ. តាព្រហ្ម គ. ត្រីក្រាញ់ ឃ. ឌីម៉ាល់

៧. ក្នុងរឿងអ្នកតាទឹកអ្នកតាភ្នំ តើតួអង្គណាជាតួអង្គឯក?

ក. អ្នកតាភ្នំ ខ. អ្នកតាទឹក គ. តាយាយ ឃ. កូនក្រមុំ

ខ. សំណួរផ្គូផ្គង

ចូរប្អូនអានរឿង"កុំត្រាប់តាមបង"ក្នុងសៀវភៅថ្នាក់ទី៧ ទំព័រទី៨០ដល់៨៣ រួចប្រើសញ្ញាព្រួញធ្វើការផ្គូផ្គងតួអង្គពីតារាង(ក)ទៅតួអង្គតារាង(ខ)បង្ហាញពីតួនាទីតួអង្គនីមួយៗឱ្យបានត្រឹមត្រូវ៖

ក	ខ
លោកសេដ្ឋី	តួអង្គឯក
ពេជ្រ	
ធឿន	តួអង្គរង
សមត្ថកិច្ច	
មិត្តភក្តិ	តួអង្គបន្ទាប់បន្សំ
ប្រពន្ធធឿន	
ប្រពន្ធពេជ្រ	តួអង្គរំឭក

២.៥.អំណានៈ រឿងចចក

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវៈ

ឧទាហរណ៍ៈ ហេតុអ្វីបានជារឿងចចកស្ថិតនៅក្នុងចលនាអក្សរសិល្ប៍អ្វី?

ក. ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម **ខ. ចលនាអក្សរសិល្ប៍ពុទ្ធនិយម**

☑គ. ចលនាអក្សរសិល្ប៍តំណាលកថាប្រជាប្រិយ **ឃ. ចលនាអក្សរសិល្ប៍បរទេស**

១. តើរឿងចចកអ្នកនិពន្ធដកស្រង់ចេញពីសៀវភៅណា?

ក. ពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ១ ខ. សៀវភៅប្រជុំរឿងព្រេងខ្មែរភាគ២

គ. សៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៣ ឃ. សៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៤

២. ហេតុអ្វីបានជាចចកនាំសត្វធំសត្វតូចមកធ្វើជាទំនប់បាចទឹក?

ក. ព្រោះចង់ស៊ីហ្វូងមច្ឆជាតិ ខ. ព្រោះខឹងនឹងការចាញ់បោកកំពិស

គ. ព្រោះចង់ឱ្យសត្វដទៃបានចំណីដូចគ្នា ឃ. ព្រោះចង់ឃើញសេចក្តីវេទនារបស់ហ្វូងមច្ឆជាតិ

៣. តើសកម្មភាពរបស់ចចកនិងហ្វូងសត្វផ្សេងទៀត ចាត់ទុកជាសកម្មភាពបែបណា?

ក. សកម្មភាពលោភលន់ ខ. សកម្មភាពចងកំហឹង

គ. សកម្មភាពព្រមព្រៀងដើម្បីប្រយោជន៍ ឃ. សកម្មភាពសាមគ្គីភាព

៤. តើការសាមគ្គីរបស់ហ្វូងចចក អាចចាត់ទុកជាការសាមគ្គីដូចម្តេច?

ក. ជាការសាមគ្គីដើម្បីប្រយោជន៍រួម ខ. ជាការសាមគ្គីដើម្បីសងសឹក

គ. ជាការសាមគ្គីដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ឃ. ជាការសាមគ្គីដើម្បីភាពជោគជ័យ

៥. តើតួអង្គមួយណា ដែលហ៊ានលះបង់ជីវិត ដើម្បីសមាជិករបស់ខ្លួនបានរស់នៅស្រួល?

ក. ទន្សាយ ខ. ត្រីក្រាញ់ គ. កំពិស ឃ. ចចក

៦. ក្នុងរឿងចចកតើតួអង្គណាដែលជួយកាត់ក្តី និងដោះស្រាយវិបត្តិរបស់ពួកមច្ឆាជាតិ?

ក. ទន្សាយ ខ. ត្រីក្រាញ់ គ. កំពីស ឃ.ព្រះឥន្ទ្រ

៧. តើតួអង្គទន្សាយប្រើវិធីអ្វីដែលអាចជួយហ្វូងមច្ឆជាតិឱ្យរួចផុតពីសេចក្តីស្លាប់។

ក. ប្រើប្រាជ្ញារបស់ខ្លួនក្នុងការដោះស្រាយបញ្ហា ខ. ក្លែងសំបុត្រព្រះឥន្ទ្រដោះស្រាយបញ្ហា

គ. ប្រើសន្តិវិធីក្នុងការដើស្រាយបញ្ហា គ. ប្រើគ្រប់មធ្យាបាយដោះស្រាយបញ្ហា

៨. ក្នុងរឿងចចក តើតួអង្គណាជាតួអង្គរំឭក?

ក. ព្រះឥន្ទ្រ ខ. ចចក គ. សុភាទន្សាយ ឃ. ត្រីក្រាញ់

៩. ក្នុងរឿងចចកតើកត្តាសំខាន់ដែលធ្វើឱ្យពួកមច្ឆាជាតិទទួលបានជ័យជម្នះគឺអ្វី?

ក. សាមគ្គីគ្នា ខ. ស្រឡាញ់គ្នា គ. សំណាង ឃ. អធ្យាស្រ័យ

១០. តើតួអង្គទន្សាយប្រសិនបើប្រៀបធៀបមកមនុស្សវិញ ជាមនុស្សបែបណា?

ក. ស្រឡាញ់អំពើយុត្តិធម៌ ខ. ស្រឡាញ់ភាពស្មោះត្រង់និងការតស៊ូ

គ. ស្រឡាញ់អ្នកមានហាន:តូចតាច ឃ. ស្រឡាញ់កក្តីភាពរបស់អ្នកនៅជុំវិញខ្លួន

ខ. សំណួរផ្គូផ្គង

ចូរប្អូនផ្គូផ្គងមេពាក្យ និងន័យពាក្យនៅតារាង(ក) ជាមួយតារាង(ខ)សរសេរចម្លើយក្នុងតារាង(គ)ឱ្យបានត្រឹមត្រូវ៖

ក	ខ	គ
១.(គុ). ដែលកំពុងពេញទំហំ ពេញកម្លាំង ឬដែលកំពុងឡើងក ទ្រើសឃ្នងអង់អាច។ ២. (ន). ក្រហូងតូចៗ ដែលដក់ទឹកប្រឡង់។ ៣. (កិ). ប្រមៀលខ្លួនឯងនៅលើទីផ្ទៃ។ ៤.(គុ). ដែលមានលោភច្រើន ដែលមានសេចក្តីត្រូវការច្រើនឥតអៀនខ្មាស។ ៥.(កិ). ធ្វើឱ្យឆោត ឱ្យលង់គំនិតជឿ។ ៦.(ន). ឈ្មោះសត្វស្លាប មានចំពុះវែងកោងឱបតែរកស៊ីក្នុងវាលស្រែ ក្នុងបឹងស្រែ។ ៧.(ន).ជលបក្សីមួយប្រភេទ ពួកក្អែកទឹក សម្បុរខ្មៅ កវែងចំពុះវែងជើងជាប់ដូចប្រវឹក ប៉ិនមុជទឹក ប៉ិនចាប់ត្រី។	ក.ល្មោភ ខ.បញ្ឆោត គ.ត្រោស ឃ.ស្មោញ ង.ចង្កៀលខ្សែង ច.ប្រឡង់ ឆ.ននៀល	១ → គ ២ → ៣ → ៤ → ៥ → ៦ → ៧ →

គ. សំណួរត្រិះរិះ

១. ចូរអ្នកវិភាគតួអង្គ"ទន្សាយ ចចក កំពឹស ត្រីក្រាញ់"ឱ្យបានក្បោះក្បាយ។(គុណសម្បត្តិ និងគុណវិបត្តិ)

ឧទាហរណ៍៖ តួអង្គ"ពស់ថ្លាន់"

គុណសម្បត្តិ៖ ជាសត្វមានសាមគ្គីភាពជាមួយចចកនិងហ្វូងសត្វដទៃ ចេះជួយមិត្តភក្តិដែលរស់នៅក្នុងព្រៃជាមួយគ្នា។

គុណវិបត្តិ៖ ជាសត្វល្ងង់ដោយមិនគិតពីហេតុផល ទីបំផុតត្រូវអន្តរាយដល់ជីវិត។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

២. ហេតុអ្វីបានជាសុភាទន្សាយសុខចិត្តជួយហ្វូងមច្ឆជាតិតាមការអង្វររបស់ត្រីក្រាញ់?

.....

.....

.....

.....

.....

.....។

៣. ចូរសង្ខេបអត្ថបទអំណានរឿង"ចចក"ឱ្យបានត្រឹមត្រូវ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

២.៦.អំណាន៖ ជើង ដៃ ក្រពះ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើរឿង"ជើង ដៃ ក្រពះ" ស្ថិតនៅក្នុងរឿងបែបនា?

☑ក.និទានកថា ខ. ព្រេងកថា គ. ទេវកថា ឃ. ល្បើកកថា

១. តើរឿង"ជើង ដៃ ក្រពះ" ដកស្រង់និងកែសម្រួលចេញពីណា?

ក. ដកស្រង់និងកែសម្រួលពីគតិលោកភាគ៤ ខ. ដកស្រង់និងកែសម្រួលពីគតិលោកភាគ៥

គ. ដកស្រង់និងកែសម្រួលពីគតិលោកភាគ៦ ឃ.ដកស្រង់និងកែសម្រួលពីគតិលោកភាគ៧

២. តើរឿង"ជើង ដៃ ក្រពះ" អ្នកនិពន្ធចង់បង្ហាញពីអ្វី?

ក. ការមិនសាមគ្គីគ្នា ខ. ការច្រណែនឈ្នានីសគ្នា

គ. ការមិនព្រមស្រុះស្រួលគ្នា ឃ. ការប្រចាំគ្នាទៅវិញទៅមក

៣. តើតួអង្គមួយណាដែលផ្តើមការច្រណែនមុនគេ?

ក. ដៃ ខ. ជើង គ. មាត់ ឃ. ក្រពះ

៤. បន្ទាប់មកតួអង្គណាជាអ្នកបន្តការច្រណែន?

ក. ដៃ ខ. ជើង គ. មាត់ ឃ. ក្រពះ

៥. តើតួអង្គណាជាអ្នកអរអ៊ូក្រោយគេ ព្រោះតែភាពហត់នឿយ?

ក. ដៃ ខ. ជើង គ. មាត់ ឃ. ក្រពះ

៦. តើលទ្ធផលដែលមិនព្រមស្រុះស្រួលគ្នារបស់ជើង ដៃ ក្រពះមានបញ្ហាអ្វីកើតឡើង?

ក. រាងកាយស្គមរីងរៃ ខ. រាងកាយទាំងមូលមានរោគា

គ. រាងកាយទាំងមូលគ្មានបញ្ហាកើតឡើង ឃ. រាងកាយស្គមរីងរៃនិងមានរោគា

៧. នៅពេលដែលឃើញសភាពបែបនេះនៃរាងកាយ តើជើង ដៃ ក្រពះបានយល់ពីអ្វី?

ក. ការសាមគ្គីភាព ខ. តួនាទីរបស់ខ្លួន

គ. តួនាទីនិងភារកិច្ចបានច្បាស់លាស់ ឃ. កាតព្វកិច្ចដែលត្រូវធ្វើ

៨. តើរឿង"ជើង ដៃ ក្រពះ"បានអប់រំអ្នកសិក្សាឱ្យស្គាល់ពីអ្វី?

ក. ស្គាល់ពីតួនាទីនិងកាតព្វកិច្ចរបស់ខ្លួន ខ. ស្គាល់ពីតម្លៃនៃការសាមគ្គី

គ. ស្គាល់ពីភារកិច្ចដែលត្រូវធ្វើ ឃ. ស្គាល់ពីបញ្ហាដែលត្រូវដោះស្រាយ

ខ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចន្លោះនីមួយៗឱ្យត្រូវន័យពាក្យបានត្រឹមត្រូវ៖

១. ឧទាហរណ៍៖(ន.) រូបរាង អង្គ រូបអង្គ សព៌ាង្គ ខ្លួនប្រាណ។ ចម្លើយ៖ <u>អវយវៈ</u>

២. (កិ.) លើកលែង តម ឈប់ខាន អត់មិនធ្វើ។ ចម្លើយ៖.....

៣. (គុ.) ដែលជើយ កន្តើយ ដែលតាំងចិត្តជាកណ្តាល សោះអង្គើយ។ ចម្លើយ៖.....

៤. (គុ.) សួតស្រាំង ស្វិតក្រញង់។ ចម្លើយ៖.....

៥. (ន.) បង្អែកការងារ អ្នកព្រនាក់ការងារ អ្នកជាជំនួយការអធិបតី។ ចម្លើយ៖.....

៦. (ន.) សេចក្តីប្រែប្រួល ដំណើរថ្លោះធ្លាក់ សេចក្តីវិនាស។ ចម្លើយ៖.....

៧. (កិ). ផ្សាយដោយការប៉ះពាល់ត្រូវ ផ្សាយសព្វ ជ្រួតជ្រាបសព្វអន្លើ។ ចម្លើយ៖.....

៨. (កិ.) ស្រុត ស្រុតចុះ លិចចុះ ផតខ្លួងចុះ។ ចម្លើយ៖.....

៩.

គ. សំណួរត្រិះរិះ

១. ចូរប្រៀបធៀបសកម្មភាពរបស់តួអង្គ"ជើង ដៃ ក្រពះ"ទៅនឹងការសិក្សារបស់អ្នកឱ្យបានត្រឹមត្រូវ។

ឧទាហរណ៍៖ ការសិក្សាត្រូវបរាជ័យ ដោយសារមិនខ្វល់ពីពេលវេលា។(ជើង ដៃ មាត់ត្រណែននឹងក្រពះ)

.....

.....

.....

.....

.....

.....។

២. ចូរអ្នកបង្ហាញផលវិជ្ជមានពីការបំពេញភារកិច្ចតាមតួនាទី។

.....

.....

.....

.....

.....

.....។

៣. តើចំណុចត្រង់ណានៅក្នុងរឿង ដែលបង្ហាញពីការជួយគ្នាទៅវិញទៅមក? ចូរបញ្ជាក់ឱ្យបានច្បាស់លាស់។

.....

.....

.....

.....

.....

.....។

ឃ. សំណួរតស៊ូមតិ

ទស្សន:មួយថា"ការបំពេញភារកិច្ចតាមតួនាទី ធ្វើឱ្យមនុស្សមានភាពថ្លៃថ្នូរ"។ ចូរបកស្រាយដោយប្រើមតិស្រប និងមតិបដិសេធ។

ចូរអ្នករកមតិស្រប និងមតិបដិសេធទៅបំពេញក្នុងតារាងខាងក្រោមដោយភ្ជាប់ឧទាហរណ៍ផងដោយសរសេរជាលក្ខណៈគម្រោងខ្លីៗ។

ឧទាហរណ៍៖

មតិស្រប	**មតិបដិសេធ**
-ពន្យល់ពាក្យ៖ ភារកិច្ច តួនាទី ថ្លៃថ្នូរ -សិស្ស និស្សិត មន្ត្រីរាជការ អ្នករកស៊ីត្រូវតែគោរពតាមតួនាទីរបស់ខ្លួន។ ជាក់ស្តែងសិស្សត្រូវខិតខំរៀនសូត្រ គោរពពេលម៉ោងចូលរៀន គោរពតាមបទបញ្ជាផ្ទៃក្នុងសាលា ប្រឹងរៀននៅផ្ទះបន្ថែម....។	-ពន្យល់ពាក្យៈភារកិច្ច តួនាទី ថ្លៃថ្នូរ -ភាពថ្លៃថ្នូររបស់មនុស្សមិនមែនកើតឡើងពីការគោរពតួនាទី បំពេញភារកិច្ចនោះទេ វាអាស្រ័យលើមនុស្សមានសីលធម៌ សុជីវធម៌។ ជាក់ស្តែង៖ អ្នកបើកបររថយន្តមិនគោរពច្បាប់ចរាចរណ៍ ក៏គេអាចចាត់ទុកថាជាមនុស្សគ្មានសេចក្តីថ្លៃថ្នូរដែរ (ឡានថ្លៃ តែមនុស្សថោក)។

(ប្អូនអាចមើលពីរបៀបតស៊ូមតិពីក្នុងយូធូប ឬហ្វេសប៊ុកតាមសាលាផ្សេងៗ ដើម្បីធ្វើជាគំនិតក្នុងការរកខ្លឹមសារ)

២.៨.ការស្តាប់៖ រឿងស្រូវ

ចូរប្អូនអានអត្ថបទស្តាប់ខាងក្រោមដោយយកចិត្តទុកដាក់មុននឹងជ្រើសរើសសំណួរខាងក្រោម៖

អត្ថបទ

កាលពីព្រេងនាយ មនុស្សយើងមិនចាំបាច់ត្រូវការដាំ ច្រូតកាត់ដឹកជញ្ជូនស្រូវទេ គឺស្រូវដុះពាសវាលពាសកាល ហើយវាចូលមកជង្រុកដោយខ្លួនឯងទាំងគ្មានសម្បកទៀតផង។ ប៉ុន្តែមានថ្ងៃមួយ ស្ត្រីកំណាចម្នាក់បានវាយស្រូវនឹងបន្ទះក្តារ ដោយមកពីនាងនោះថ្លងនឹងស្នូរស្រូវហោះចូលផ្ទះនាង។ ស្រូវក៏រត់ទៅពួននៅកន្លៀតថ្មភ្នំយ៉ាងជ្រៅ។

មនុស្សម្នាកើតក្តីខ្វល់ខ្វាយគ្រប់ៗគ្នាដោយមិនដឹងរកអ្នកណាឱ្យស្ទង់គ្រចិត្តបំពេញនាទីនេះ។ ក្នុងពេលនោះត្រីស្លាត ដោយអាណិតមនុស្សបានស្ទង់គ្រយកអាសារឿងនេះ។ វាខំប្រឹងហែលលូនត្បុលតាមកន្លៀតថ្ម ហើយក៏បានជួបនឹងមេស្រូវ។ ត្រីស្លាតសុំអង្វរករមេស្រូវ ឱ្យវិលត្រឡប់ទៅជួយសង្គ្រោះមនុស្សលោកវិញ។ ប៉ុន្តែមេស្រូវយល់ស្របតាម សេចក្តីអង្វរកររបស់ត្រីស្លាតទាំងនិយាយ៖ អំណឹះតទៅស្រូវមិនហោះចូលជង្រុកដូចមុនៗទៀតទេ បើចង់បានស្រូវត្រូវ ភ្ជួររាស់ ដកស្មូងនឹងដុះតែរដូវភ្លៀងតែប៉ុណ្ណោះ។

(ដកស្រង់ពីសៀវភៅអក្សរសិល្ប៍ខ្មែរ បរទេសនៅគរុកោសល្យភ្នំពេញឆ្នាំ១៩៨៩)

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើការបង្ហាញថាស្រូវអាចហោះចូលក្នុងជង្រុកដោយខ្លួនឯងទាក់ទងនឹងអ្វីនៅក្នុងរឿង?

ក. ជំនឿមិនសមហេតុផល **ខ. ភាពអស្ចារ្យពីសម័យមុន**

☑គ. អបិយជំនឿរបស់ខ្មែរ **ឃ. ភាពអរូបិយនៅក្នុងរឿង**

១. ហេតុអ្វីបានជាអ្នកនិពន្ធលើករឿង"ស្រូវ" យកមកដាក់ក្នុងកម្មវិធីសិក្សា?

ក. ព្រោះប្រទេសកម្ពុជាជាប្រទេសកសិកម្ម ខ. ព្រោះសិស្សត្រូវតែស្គាល់ស្រូវ

គ. ព្រោះចង់បង្ហាញពីប្រភពស្រូវ ឃ. ព្រោះចង់ឱ្យសិស្សដឹងពីរបៀបធ្វើស្រែ

២. តើរឿង"ស្រូវ" ជារឿងបែបអ្វី?

ក. និទានកថា ខ. ព្រេងកថា គ. ទេវកថា ឃ. ល្បើកកថា

៣. តើកសិករតែងធ្វើស្រូវនៅរដូវណា?

ក. រដូវវស្សា ខ. រដូវប្រាំង គ. រដូវរំហើយ ឃ. រដូវស្លឹកឈើជ្រុះ

៤. ហេតុអ្វីបានជាស្ត្រីកំណាចយកបន្ទះក្តារតាមវាយស្រូវ?

ក. ព្រោះមិនចង់ឱ្យស្រូវហោះចូលក្នុងផ្ទះ ខ. ព្រោះថ្លង់នឹងស្នូរសំឡេងស្រូវចូលជង្រុក

គ. ព្រោះខឹងនឹងស្រូវមិនព្រមធ្វើតាមសន្យា ឃ. ព្រោះចរិតកាច មានៈរបស់ស្ត្រីនោះ

៥. តើអ្នកណាជាអ្នកទៅជួយអង្វរមេស្រូវឱ្យជួយមនុស្សវិញ?

ក. មនុស្សលោក ខ. ត្រីស្លាត គ. ហ្វូងមច្ឆជាតិ ឃ. ប្រជាជន

៦. តើមេស្រូវបានដាក់លក្ខខណ្ឌអ្វីដល់មនុស្ស មុននឹងព្រមជួយមនុស្សឱ្យមានស្រូវហូបវិញ?

ក. មនុស្សត្រូវចេះធ្វើការងារ ខ. មនុស្សត្រូវធ្វើស្រែបង្កើតស្រូវ

គ. មនុស្សត្រូវចេះធ្វើការងារកសិកម្ម ឃ. មនុស្សត្រូវធ្វើស្រែនៅរដូវវស្សា

៧. ហេតុអ្វីបានជាស្រូវឱ្យមនុស្សធ្វើការដើម្បីឱ្យបានស្រូវហូប?

ក. ខឹងនឹងមនុស្សធ្វើបាបស្រូវ ខ. ចង់ឱ្យមនុស្សចេះធ្វើពលកម្ម

គ. ធ្វើតាមការអង្វររបស់ត្រីស្លាត ឃ. ចង់ឱ្យមនុស្សយល់ពីតម្លៃនៃការងារ

៨. តើអត្ថបទស្តាប់រឿង"ស្រូវ" មានតម្លៃអប់រំដូចម្តេច?

ក. មនុស្សត្រូវចេះអត់ធ្មត់គ្រប់បញ្ហា ខ. មនុស្សត្រូវចេះធ្វើកិច្ចការងារផ្សេងៗ

គ. មនុស្សត្រូវស្គាល់ពីតម្លៃនៃការងារ ឃ. មនុស្សត្រូវចេះគោរពេលវេលា

ខ. សំណួរត្រិះរិះ

១. តើត្រីស្លាតបើប្រៀបធៀបមកមនុស្ស ជាមនុស្សប្រភេទណា?

.....

.....

.....

.....។

២. តើស្ត្រីកំណាចជាមនុស្សប្រភេទណា?

.....

.....

.....

.....។

៣. ចូរប្អូនធ្វើការប្រៀបធៀបរបរកសិកម្មពីសម័យបុរាណ និងសម័យបច្ចុប្បន្ន។(**ស្រាវជ្រាវតាមយូធូប**)

កសិកម្មសម័យបុរាណ	**កសិកម្មសម័យបច្ចុប្បន្ន**
ឧទា. កសិករធ្វើស្រែតែរដូវវស្សា(ពូជស្រូវធ្ងន់)	**កសិករអាចធ្វើស្រែគ្រប់រដូវកាល(ពូជស្រូវស្រាល)**

២.៩.តែងសេចក្តី៖ សំណេរអត្ថបទព័ត៌មាន ដែលពណ៌នាពីព្រឹត្តិការណ៍(ជាក់ស្តែង)

គម្រោងតែង

ក. សេចក្តីផ្តើម៖

-ពេលវេលាកើតព្រឹត្តិការណ៍.....

-ទីកន្លែងកើតព្រឹត្តិការណ៍.....

-ឈ្មោះព្រឹត្តិការណ៍.....

ខ. តួសេចក្តី៖

-មុនពេលកើតព្រឹត្តិការណ៍

+ទិដ្ឋភាពទូទៅ.....

+សកម្មភាពមុនពេលកើតព្រឹត្តិការណ៍.....

-ពេលព្រឹត្តិការណ៍កើតឡើង

+ទិដ្ឋភាពពេលព្រឹត្តិការណ៍ចាប់ផ្តើមកើតឡើង.....

+ទិដ្ឋភាពពេលព្រឹត្តិការណ៍កំពុងកើតឡើង.....

+ទិដ្ឋភាពចុងបញ្ចប់នៃព្រឹត្តិការណ៍.....

-ក្រោយពេលព្រឹត្តិការណ៍កើតឡើង

+ទិដ្ឋភាពនៃការខូចខាត.....

+សកម្មភាពអ្នកស្រុកក្រោយពេលកើតហេតុ.....

+ទិដ្ឋភាពចុងបញ្ចប់នៃព្រឹត្តិការណ៍.....

គ. សេចក្តីបញ្ចប់៖

-ចំណាប់អារម្មណ៍៖ បង្ហាញពីចំណាប់អារម្មណ៍ចំពោះព្រឹត្តិការណ៍.....។

-សំណូមពរ៖ សំណូមពរទៅតាមប្រធានបទឱ្យមនុស្សគ្រប់រូប....។

ប្រធាន៖ ចូរប្អូនសរសេរអត្ថបទព័ត៌មាន ពណ៌នាពីព្រឹត្តិការណ៍គ្រោះថ្នាក់ចរាចរណ៍រវាងរថយន្តនិងម៉ូតូតាមរូបភាពខាងក្រោមនេះឱ្យបានក្បោះក្បាយ។(**រូបភាពក្នុង Google**)

សេចក្តីអធិប្បាយ



.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

មេរៀនទី៣៖ កេរដំណែលរបស់ជាតិ

៣.១.បំណិន៖ កាព្យមាត្រ ឬរង្វាស់កាព្យ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើកំណាព្យខ្មែរមានប៉ុន្មានបទ?

ក. ៦បទ ខ. ៧បទ គ. ៨បទ ☑ឃ. ច្រើនបទ

១. ដូចម្តេចដែលហៅថា"កំណាព្យ"

ក. សិល្បអត្ថបទជាពាក្យចួន ខ. សិល្បៈតែងកាព្យ

គ. ចង្វាក់រណ្តំសូរសំឡេង ឃ. ពាក្យកាព្យពីរោះណែងណង

២. តើ"កំណាព្យ" ដំបូងគេត្រូវគិតទៅលើអ្វីដើម្បីដឹងបទនីមួយៗ?

ក. ចំណាប់ចួន ខ. ចួនក្នុងវគ្គ គ. ចួនឆ្លងវគ្គ ឃ. រង្វាស់កាព្យ

៣. តើការរាប់ចំនួនព្យាង្គក្នុងឃ្លា ចំនួនឃ្លាក្នុងវគ្គ គេហៅថាអ្វី?

ក. កាព្យមាត្រឬរង្វាស់កាព្យ ខ. ចំណាប់ចួន

គ. ចួនក្នុងវគ្គ ឃ. ចួនឆ្លងវគ្គ

៤. តើ"មួយវគ្គមាន៤ឃ្លា មួយឃ្លាមាន៧ព្យាង្គ" ជារង្វាស់កាព្យ ឬកាព្យមាត្របទអ្វី?

ក. បទបន្ទោលកាក ខ. បទពាក្យ៧ គ. បទព្រហ្មគីតិ ឃ. បទពាក្យ៨

៥. តើ"មួយវគ្គមាន៣ឃ្លា ឃ្លាទី១និងទី២ មាន៦ព្យាង្គ ឃ្លាទី២ មាន៤ព្យាង្គ" រង្វាស់កាព្យបទអ្វី?

ក. បទព្រហ្មគីតិ ខ. បទភុជង្គលីលា គ. បទពំនោល ឃ. បទបន្ទោលកាក

៦. តើ"មួយវគ្គមាន៤ឃ្លា ឃ្លាទី១និងទី៣ មាន៥ព្យាង្គ ឃ្លាទី២ និងទី៤ មាន៦ព្យាង្គ" ជារង្វាស់កាព្យបទអ្វី?

ក. បទបន្ទោលកាក ខ. បទភុជង្គលីលា គ. បទពំនោល ឃ. បទព្រហ្មគីតិ

៧. តើ"មួយវគ្គមាន៤ឃ្លា ឃ្លាទី១និងទី៣ មាន៤ព្យាង្គ ឃ្លាទី២និងទី៤ មាន៦ព្យាង្គ" ជារង្វាស់កាព្យបទអ្វី?

ក. បទពំនោល ខ. បទភុជង្គលីលា គ. បទបន្ទោលកាក ឃ. បទពាក្យ៤

ខ. សំណួរត្រិះរិះ

១. ចូររកវង្វាស់កាព្យ ឬកាព្យមាត្របទ"កាកគតិ ពាក្យ៨ ភុជង្គលីលា បទពាក្យ៩ បទពាក្យ៤" ឱ្យបានត្រឹមត្រូវ។

.....

.....

.....

.....

.....

.....

.....

.....

.....។

២. តើកំណាព្យខាងក្រោមជាបទអ្វី?ចូរអ្នកប្រាប់ពីវង្វាស់កាព្យនៃបទនេះ។

-មើលមានប្រាសាទ ប្រាំស្អាងប្រាង្គស្អាត ប្រសើរឆើតឆាយ

កម្ពស់កំពូល ត្រសូលត្រសាយ ត្រសែតពណ្ណរាយ

ពព្រោតគួរស្ញែង។

(**ហរិក្សរាមាអង្គឌួង កាកីទំព័រ៣**)

.....

.....

.....។

៣. តើកំណាព្យខាងក្រោមជាបទអ្វី? ចូរអ្នកប្រាប់ពីវង្វាស់កាព្យនៃបទនេះ។

-ស្តេចជ្រាបដូច្នេះហើយ ទ្រង់ព្រះក្រោធា ហាក់ដូចអគ្គីឆួលឆេះ។

-ថាអះវាទូចប៉ុណ្ណោះ ហ៊ានដូចដល់ម្ល៉េះ ពុំគិតជីវិតអន្តរាយ។

-ស្តេចបើកបន្ទូលហៅនាយ ពេជ្ឈឃាតទាំងឡាយ ថាអស់គ្នាយើងម្ចីម្ចា។

(**ក្រុងសុភមិត្រ ទំព័រ១០៣ ឆ្នាំ១៩៧0**)

.....

.....

.....

.....។

៤. តើកំណាព្យខាងក្រោមនេះជាបទអ្វី? ចូរអ្នកប្រាប់ពីរង្វាស់កាព្យនៃបទនេះ។

-បើស្រីស្លកុក ស្លនឹងទឹកថ្លា
ត្បិតកុកវាថា សាច់វាស្អាតណាស់។
-ទាំងរោមទាំងស្លាប ដុះរៀបក្រៃក្រាស់
មុខគួរស្អាតណាស់ កុំឱ្យមានហ្មង។
-វាបានជាឆ្លាយ មកជាប់ជង់បង
អាណិតវាផង ត្បិតវាអង្វរ។

(**វិជ្ជាខេមរភាសាបរិ ទំព័រ៤៧**)

.....

.....

.....

.....។

៥. តើកំណាព្យខាងក្រោមជាបទអ្វី? ចូរអ្នកប្រាប់ពីរង្វាស់កាព្យបទនេះ។

-ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា
ពើបនឹងជុចណា ត្រីស្រែកថារ៉ើយចៀសចេញ។
-ជុចថាអះអើ បុណ្យអ្នកនេះតើម្តេចមិញ
ក៏មកប្រើអញ ចៀសចេញឱ្យអ្នកជាល្បែង។

(**វិសេសដូង សាស្ត្រាជុច និងត្រី**)

.....

.....

.....

.....

.....។

៦. តើកំណាព្យខាងក្រោមជាបទអ្វី? ចូរអ្នកប្រាប់ពីរង្វាស់កាព្យបទនេះ។

[...] -នាគអើយនាគបានសានបុរាណសាង ពីដើមយ៉ាងល្អដូចម្តេចអេះ
ឥឡូវនាគងាកធ្លាក់បាក់របេះ ឃើញតែរាងយ៉ាងនេះអស់លម្អ។
-ខ្លួនក៏ឃ្លោតក្បាលក៏ឃ្លៀងទៅដោយខ្លួន ឃើញតែក្បួនជើងទៀនប្រចាំទ្រ
ស្តាយអើយស្តាយដៃលោកតែងមក៍ មិនតាំងតថាវរឱ្យវែងទៅ។
-អនិច្ចាសង្ខារនាគាថ្ម ហ្មាយតបិតបេរចេរកាលនៅ
នេះពុំទាន់ប៉ុន្មានមកហ្មងសៅ មករុះរោយធ្លាយទៅទីទៃផ្តាស់។

(**សុត្តន្តប្រឹជាឥន្ទ**)

.....
.....
.....
.....
.....។

៧. តើកំណាព្យខាងក្រោមនេះជាបទអ្វី? ចូរអ្នកប្រាប់ពីរង្វាស់កាព្យបទនេះ។

-ស្មៅចិញ្ចៀន រៀនដុះផុង ក្នុងវារី នៅសល់ពី ទីទឹកស្មាន បានពីរធ្លាប់
ខ្យល់បក់បោក ខោកឥតស្រាក ងាករេញាប់ នៅមិនងាប់ ជាប់រហូត លូតឡើងបាន។
-ជាតិបណ្ឌិត ពិតពីរោះ ឈ្មោះឥតអាក់ មានឧបសគ្គ ស្ទាក់រារាំង ទាំងប៉ុន្មាន
ប្រឹងរុករាន ឈានឥតខ្សោយ ដោយក្លាហាន ត្រាតែប្រាណ បានរួចទុក្ខ សុខដូចស្មៅ។

(**ឥន្ទមុនីសេកនាង**)

.....
.....
.....
.....
.....។

៣.២.បំណិនៈ ចួន ផ្ងួន រណ្តាំ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវៈ

ឧទាហរណ៍ៈ អ្វីទៅជាចួន ផ្ងួន រណ្តាំ?

☑ក. ពាក្យសម្រាប់ប្រើតែងកំណាព្យ **ខ. ពាក្យនិយាយឱ្យពីរោះស្តាប់**

គ. ពាក្យធ្វើឱ្យមានភាពណែងណង **ឃ. ពាក្យសាមញ្ញធម្មតា**

១. ព្យាង្គដែលកើតឡើងពីសូរស្រៈដូចគ្នា ឬព្យញ្ជនៈប្រកបដូចគ្នា ឬសូរស្រៈនិងព្យញ្ជនៈប្រកបដូចគ្នា។ តើគេហៅថាអ្វី?

ក. កាព្យមាត្រឬរង្វាស់កាព្យ ខ. ចំណាប់ចួន

គ. ចួន ឃ. ផ្ងួន រណ្តាំ

២. តើចួនមានប៉ុន្មានយ៉ាង?

ក. ២យ៉ាង ខ. ៣យ៉ាង គ. ៤យ៉ាង ឃ. ៥យ៉ាង

៣. តើចួនដែលមានសូរស្រៈដូចគ្នា និងសូរព្យញ្ជនៈប្រកបដូចគ្នា គេហៅថាចួនដូចម្តេច?

ក. ចួនល្អ ខ. ចួនមិនល្អ គ. ចួនឆ្លងវគ្គ ឃ. ចួនក្នុងវគ្គ

៤. តើចួនដែលមានសូស្រៈដូចគ្នា ស្ថិតក្នុងមូលភេទដូចគ្នា តែព្យញ្ជនៈប្រកបនៅក្នុងមូលភេទខុសគ្នា គេហៅថាចួនដូចម្តេច?

ក. ចួនល្អ ខ. ចួនឆ្លងវគ្គ គ. ចួនមិនល្អ ឃ. ចូនក្នុងវគ្គ

៥. តើព្យាង្គចួនឆ្លងពីឃ្លាមួយទៅឃ្លាមួយទៀត នៅក្នុងវគ្គតែមួយ គេហៅថាចួនដូចម្តេច?

ក. ចួនក្នុងវគ្គ ខ. ចួនល្អ គ. ចួនឆ្លងវគ្គ ឃ. ចួនមិនល្អ

៦. តើព្យាង្គចួនឆ្លងពីវគ្គមួយទៅវគ្គមួយ គេហៅថាចួនដូចម្តេច?

ក. ចួនល្អ ខ. ចួនឆ្លងវគ្គ គ. ចួនមិនល្អ ឃ. ចួនក្នុងវគ្គ

៧. ព្យាង្គតែមួយដែលកវីប្រើច្រើនដងក្នុងឃ្លាឬវគ្គនៃកំណាព្យ គេហៅថាអ្វី?

ក. រណ្តាំ ខ. ចួន គ. ផ្ងួន ឃ. រង្វាស់កាព្យ

៨. ព្យាង្គដែលកវីប្រើព្យញ្ជនៈឬស្រៈតែមួយច្រើនដងនៅក្នុងឃ្លា វគ្គនៃកំណាព្យ តើគេហៅថាអ្វី?

ក. រណ្តំ ខ. ចួន គ.ផ្ចួន ឃ. រង្វាស់កាព្យ

៩. ឃ្លា"ត្រីក្រាញ់លលេញដេញត្រីក្រុស....."តើពាក្យណាជាព្យាង្គផ្ចួន?

ក. ដេញ ខ. លលេញ គ. ត្រី ឃ. ក្រាញ់

១០. ឃ្លា"ត្រីក្រាញ់លលេញដេញត្រីក្រុស....."តើពាក្យណាជាព្យាង្គរណ្តំព្យញ្ជនៈ?

ក. ដេញ ខ. លលេញ គ. ត្រី ឃ. ក្រាញ់

លំហាត់អនុវត្ត

១. ចូរអានកំណាព្យខាងក្រោម រួចគូសសញ្ញាចួនក្នុងវគ្គនិងឆ្លងវគ្គឱ្យបានត្រឹមត្រូវ៖

ឧទាហរណ៍៖ ត្រីក្រាញ់លលេញដេញត្រីក្រុស ត្រីក្រឹមក្រាបចុះឈប់បង្អង់

ត្រីក្រាយហែលក្រោយបណ្តោយត្រង់ ត្រីក្រឹមវិលវង់ក្រោយត្រីក្រាយ។

-កំពឹសតោងឫសកំពឹងពួយ ក្រពាត់ស្ទុះស្ទួយស្ទាក់ពីឆ្ងាយ

ពើបពះពានលើកំពូលបាយ កំពុងវាត់វាយកំពឹសពង។

២. តើកំណាព្យនេះជាបទអ្វី? ចូរអ្នកគូសគំនូសតាងក្នុងវគ្គនិងឆ្លងវគ្គឱ្យបានត្រឹមត្រូវ។

-ខ្ញុំមានក្រចកនិងធ្មេញ បើខ្ញុំបញ្ចេញ សត្វផងរអែងខ្ញុំណា។

-រហ័សប្រៀបបាននឹងខ្លា ខ្ញុំស្រែកកាលណា សំរែកដូចជាខ្លាឃ្មុំ។

(ដកស្រង់ចេញពីសៀវភៅកំណាព្យខ្មែរ ដោយលោកលី សុមុនី)

៣. តើកំណាព្យនេះជាបទអ្វី? ចូរអ្នកគូសគំនូសតាងក្នុងវគ្គនិងឆ្លងវគ្គឱ្យបានត្រឹមត្រូវ។

-ខ្លួនស្បែកដណ្តប់ឆ្អឹង ធ្វើការប្រឹងខ្ទះអាហារ

ព្រោះឃ្លានឃ្លានផ្ទៃផ្សា បនឫស្សាមិនឱ្យធី។

-ធ្វើការគ្មានឱ្យឈប់ ក្តៅដូចគុកភ្លើងអវចី

កាប់គាស់រុករានដី មិនប្រណីទាំងថ្ងៃយប់។

(ដកស្រង់ចេញពីសៀវភៅកំណាព្យខ្មែរ ដោយលោកលី សុមុនី)

៤. តើកំណាព្យនេះជាបទអ្វី? ចូរអ្នកគូសគំនូសតាងក្នុងវគ្គនិងឆ្លងវគ្គឱ្យបានត្រឹមត្រូវ។

-ខ្លួនខ្ញុំធ្ងន់ណាស់ លោកម្ចាស់អាណិតមេត្តា

ដល់ខ្ញុំផងណា ធ្ងន់ត្រាខ្ញុំទ្រាំលែងបាន។

-នែឯងជាគ្រឹះ ជាឫសទ្រាំតាមកម្មប្រាណ

ទ្រអញឱ្យបាន ក្សេមក្សាន្តសង្ហាឈ្មោះល្បី។

(ដកស្រង់ចេញពីសៀវភៅកំណាព្យខ្មែរ ដោយលោកលី សុមុនី)

៥. ចូរប្អូនអានកំណាព្យខាងក្រោម រួចស្រង់ព្យាង្គផ្ងួននិងរណ្តំឱ្យអស់ពីក្នុងកំណាព្យនេះ។

-ទ្រង់ព្រះកន្សែងសោក សែនអមោក្សស្តាយពេកពន់

ព្រះផ្នូកព្រះប្អូនតន់ ទួញទន្ទឹងទន្ទេញថា។

-ឱមាសមិត្តកល្យាណ បងរកគ្មានស្រីឯណា

ឱ្យដូចកែវកន្ទិដ្ឋា ក្លិនក្រអូបក្រអែបឯង។

(ដកស្រង់ចេញពីសៀវភៅកំណាព្យខ្មែរ ដោយលោកលី សុមុនី)

ផ្ងួន	រណ្តំ
ឧទាហរណ៍៖ព្រះ(ព្រះកន្សែង ព្រះផ្នូក ព្រះប្អូនតន់)	**ពេកពន់(រណ្តំព្យញ្ជនៈ ព)**

៣.៣. អំណាន៖ សោតណតាពប្រាសាទបាយ័ន

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើអ្នកណាជាអ្នកកសាងប្រាសាទបាយ័ន?

ក. ព្រះបាទយសោវរ្ម័នទី២ **☑ ខ. ព្រះបាទជ័យវរ្ម័នទី៧**

គ. ព្រះបាទយសោវរ្ម័នទី១ **ឃ. ព្រះបាទនរោត្តម**

១. តើអត្ថបទអំណាន"សោភណភាពប្រាសាទបាយ័ន"ដកស្រង់ចេញពីសៀវភៅណា?

ក. សៀវភៅកំណាព្យខ្មែរ ខ. សៀវភៅអត្ថបទអក្សរសិល្ប៍ក្រសួងអប់រំ

គ. សៀវភៅរឿងព្រេងនិទានភាគ៩ ឃ. សៀវភៅភាសាខ្មែរទី៧

២. តើអំណាន"សោភណភាពប្រាសាទបាយ័ន" អ្នកនិពន្ធតែងជាបទអ្វី?

ក. បទភុជង្គលីលា ខ. បទកាកគតិ គ. បទពំនោល ឃ. បទពាក្យ៨

៣. "មួយវគ្គមាន៣ឃ្លា ឃ្លាទី១និងទី៣ មាន៦ព្យាង្គ ឃ្លាទី២ មាន៤ព្យាង្គ" តើជារង្វាស់កាព្យបទអ្វី?

ក. បទពំនោល ខ. បទភុជង្គលីលា

គ. បទកាកគតិ ឃ. បទព្រហ្មគីតិ

៤. "ព្យាង្គទី៦ ឃ្លាទី១ ចួននឹង ព្យាង្គទី៤ ឃ្លាទី២ វគ្គទី១" តើចំណាប់ចួនបទអ្វី? ចួនបែបណា?

ក. បទពំនោល ចួនឆ្លងវគ្គ ខ. បទភុជង្គលីលា ចួនក្នុងវគ្គ

គ. បទភុជង្គលីលា ចួនឆ្លងវគ្គ ឃ. បទពំនោល ចួនក្នុងវគ្គ

៥. "ព្យាង្គទី៦ ឃ្លាទី៣ វគ្គទី១ ចួននឹង ព្យាង្គទី៦ ឃ្លាទី១ វគ្គទី២" តើចំណាប់ចួនបទអ្វី? ចួនបែបណា?

ក. បទពំនោល ចួនឆ្លងវគ្គ ខ. បទភុជង្គលីលា ចួនក្នុងវគ្គ

គ. បទភុជង្គលីលា ចួនឆ្លងវគ្គ ឃ. បទពំនោល ចួនក្នុងវគ្គ

៦. ហេតុអ្វីបានជាប្រាសាទបាយ័ន ស្ថាបត្យករសាងរូបព្រហ្មមុខបួន?

ក. ព្រោះតំណាងព្រះព្រហ្ម ខ. ព្រោះតំណាងទិសធំទាំងបួន

គ. ព្រោះតំណាងគុណមាតាបិតា ឃ. ព្រោះជាតំណាក់របស់ស្តេច

៧. "អប្សរបវរទេពពិត ឆ្លាក់ជាប់នៅនិត្យ សសរសិលារាងរាយ។" តើកវីចង់បង្ហាញពីអ្វី?

ក. តំណាងរូបអប្សរា ខ. តំណាងស្រីសួគ៌

គ. តំណាងព្រះនាងឥន្ទ្រទេវី ឃ. តំណាងស្ត្រីខ្មែរសម័យមុន

៨. "ចម្លាក់សិល្បៈនានា ល្បែងខ្មែរកីឡា ប្រដាល់ចំបាប់គួរគន់"។ តើកវីចង់បង្ហាញពីអ្វី?

ក. មានល្បែងកីឡាគ្រប់ប្រភេទពីសម័យមុន ខ. មានក្បាច់គុនបោកចំបាប់

គ. មានកីឡាប្រដាល់តាំងពីបុរាណ ឃ. ចម្លើយក ខនិងគ

៩. តើអំណាន"សោភណភាពប្រាសាទបាយ័ន"អ្នកកវីចង់បង្ហាញពីអ្វី?

ក. បង្ហាញពីស្នាដៃស្ថាបត្យកររខ្មែរ ខ. បង្ហាញពីក្បាច់ចម្លាក់លើជញ្ជាំងប្រាសាទ

គ. បង្ហាញពីអត្ថន័យរូបចម្លាក់នីសម័យនោះ ឃ. ចង់បង្ហាញពីសម្រស់ប្រាសាទបាយ័ន

១០. តើ"សោភណភាពប្រាសាទបាយ័ន"ចង់បង្ហាញពីសម្បត្តិអ្វីរបស់ខ្មែរ?

ក. សម្បត្តិបេតិកភណ្ឌជាតិ ខ. កេតនភណ្ឌជាតិ

គ. សម្បត្តិដ៏មានតម្លៃរបស់ជាតិ ឃ. សម្បត្តិវប្បធម៌ជាតិ

១១. តើប្រាសាទបាយ័នស្ថិតនៅក្នុងខេត្តណា?

ក. ខេត្តសៀមរាប ខ. ខេត្តព្រះវិហារ គ. ខេត្តកំពង់ធំ ឃ. ខេត្តបាត់ដំបង

ខ. សំណួរត្រិះរិះ

១. ចូរប្អូនគូសគំនូសតាងបទ"ពំនោល"ជាលក្ខណៈពងត្រីចំនួនពីរវគ្គ រួចបង្ហាញពីចំណាប់ចួនផង។

.....

.....

.....។

២. ហេតុអ្វីបានជា រដ្ឋបញ្ជូលប្រាសាទនានាទៅក្នុងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ?

.....

.....

.....

.....

.....។

៣. តើប្រាសាបាយ័ន ព្រះបាទជ័យវរ្ម័នទី៧ កសាងឡើងសម្រាប់អ្នកណា? ព្រោះអ្វី?(**ស្រាវជ្រាវតាមយូធូប**)

.....

.....

.....

.....

.....

.....។

៤. តើប្អូនត្រូវមានភារកិច្ចអ្វីខ្លះក្នុងការរួមចំណែកជួយរក្សាកេរមរតករបស់ដូនតាឱ្យបានគង់វង្ស ពិសេសប្រាសាទបុរាណខ្មែរ?

.....

.....

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរើសពាក្យក្នុងប្រអប់ ដើម្បីតាមចន្លោះនីមួយៗនាំកំណាព្យខាងក្រោម៖

ចម្លាក់ នាមហានគរ មហាជន បរាជ័យ ចាក់ក្បាច់ ប្រពៃ ល្បែងខ្មែរ ឫទ្ធីចេស្តា ទំពៃខ្មែរ នានា ចាំឈរ ណីក្នុង

-ជញ្ជាំងរោងទងនោះណា .**ចម្លាក់**.យោធា ច្បាំងគ្នាប្រយុទ្ធជាញជ័យ ។

-.....សឹងមានថ្វីដៃ ខ្មាំង..... ចាលចាញ់.....។

-ចម្លាក់សិល្បៈ..... .....កីឡា ប្រដាល់ចំបាប់គួរគន់ ។

-.....គួរស្ញើចពេកពន់ មានពួក..... .....ទស្សនាច្រើនក្រៃ ។

-ចម្លាក់ពីរឿង..... .....សម័យ សេដ្ឋកិច្ច.....។

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចន្លោះនីមួយៗឱ្យត្រូវន័យពាក្យបានត្រឹមត្រូវ៖

១. ឧទា៖(**ន.**) **សសរដែលគេបណ្តុះភ្ជាប់លើធ្នឹមទាបត្រង់ល្វែងចាំងសាចវិហារ។ ចម្លើយ៖.<u>សសរស្គម្ភ</u>..**

២. (ន.) ស្ត្រីមានសម្បុរថ្លាស្រស់ ផូផង់ ឬស្ត្រីមានមុខថ្លាស្រស់បំព្រង។ ចម្លើយ៖.....

៣. (ន.) ឈូក ផ្កាឈូក។ ចម្លើយ៖.....

៤. (គុ.) មុខរបរដ៏ឧត្តម មុខការរបរដែលមានប្រយោជន៍ដ៏សំខាន់ក្នុងប្រទេសនីមួយៗ។ ចម្លើយ៖.....

៥. (គុ.) ដែលរុងរឿង ភ្លឺផ្លេក ពណ្ណរាយ។ ចម្លើយ៖.....

៦. (ន.) ធ្មេញ ភ្លុក ធ្មេញទាំងឡាយ។ ចម្លើយ៖.....

៧. (ន.) យសសក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង។ ចម្លើយ៖.....

៣.៤. វេយ្យាករណ៍៖ សព្វនាមចង្អុល

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើសព្វនាម មានប៉ុន្មានបែប?

ក. ៣បែប ខ. ៤បែប ☑គ. ៥បែប ឃ. ៦បែប

១. ពាក្យសម្រាប់ចង្អុលបង្ហាញអ្វីមួយ ដែលនៅចំពោះមុខនៅជិត និងនៅឆ្ងាយ។ តើន័យរបស់ពាក្យអ្វី?

ក. គុណនាមចង្អុល ខ. សព្វនាមចង្អុល គ. គុណកិរិយា ឃ. គុណនាម

២. តើសព្វនាមចង្អុលមានប៉ុន្មានយ៉ាង?

ក. ២យ៉ាង ខ. ៣យ៉ាង គ. ៤យ៉ាង ឃ. ៥យ៉ាង

៣. តើសព្វនាមចង្អុលមានពីរយ៉ាងប្រើសម្រាប់អ្វីខ្លះ?

ក. សម្រាប់ចង្អុលបង្ហាញ ខ. សម្រាប់បង្ហាញទីជិត

គ. សម្រាប់បង្ហាញទីជិតនិងឆ្ងាយ ឃ. សម្រាប់បង្ហាញទីឆ្ងាយ

៤. “សៀវភៅនេះជារបស់ខ្ញុំ។ នោះជារបស់ឯង។ តើឈ្មោះទាំងពីនេះ ពាក្យមួយណាជាសព្វនាមចង្អុល?

ក. នេះ ខ. នោះ គ. សៀវភៅនេះ ឃ. នោះជា

៥. “សៀវភៅនេះជារបស់ខ្ញុំ។ នោះជារបស់ឯង។ តើសព្វនាមចង្អុលបង្ហាញពីអ្វី?

ក. ទីជិត ខ. ទីឆ្ងាយ គ. ទីជិតនិងឆ្ងាយ ឃ. ចម្លើយទាំងបីខាងលើ

ខ. លំហាត់អនុវត្ត

១. ចូរប្អូនតែងឈ្មោះដោយប្រើសព្វនាមចង្អុល”នេះ នោះ អានេះ អានោះ”ឱ្យបាន ៨ឈ្មោះ។

ឧទាហរណ៍៖ យើងឃើញសៀវភៅពីរក្បាលនៅលើតុ។ អានេះជារបស់ខ្ញុំ អានោះជារបស់ប្អូនខ្ញុំ។

.....

.....

.....

.....

.....

.....

.....

.....។

២. ចូរតែងល្បះសព្ទនាមចង្អុលសម្រាប់ផ្លាស់កន្សោមនាម ឱ្យបាន២ល្បះ។

.....

.....

៣. ចូរតែងល្បះសព្ទនាមចង្អុលសម្រាប់ផ្លាស់នាមជាវត្ថុ ឱ្យបាន២ល្បះ។

.....

.....

៤. ចូរប្អូនប្រើសញ្ញាព្រួញគូសភ្ជាប់ពីតារាង(ក)ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
-នោះជាភ្នំឱ៉ាល់ដែលខ្ពស់ជាងគេនៅប្រទេសកម្ពុជា។ -នេះជានំរបស់ម៉ាក់។នោះជានំរបស់ខ្ញុំ។ -នេះជាកាតាបថ្មីរបស់សុភាព។ -តាសំមានគោច្រើន។ អានេះជាកូនកាត់។អានោះជាពូជធម្មតា។ -កូនខ្ញុំចង់បានកង់មួយ។ នេះជាកង់របសវា។ -នេះជារដូវវស្សា។ -នោះសត្វត្រសេក។ -សុភាពទិញកាតាបថ្មីពីរ។ អានេះជារបស់នាង។ អានោះជារបស់ប្អូននាង។	ទីជិត ទីឆ្ងាយ ទីជិតនិងឆ្ងាយ

៣.៥. បំណិន៖ និមិត្តរូប

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ហេតុអ្វីបានជាតាមមន្ទីរ ក្រសួងនីមួយៗ ត្រូវមានរូបតំណាង?

ក. ងាយស្រួលប្រជាជនបានដឹង **ខ. ងាយស្រួលនាយករដ្ឋមន្ត្រីស្គាល់**

គ. ងាយស្រួលក្នុងការធ្វើការងារ **☑ ឃ. ចម្លើយទាំងបីខាងលើ**

១. តើសញ្ញា ឬរូបតំណាង ដើម្បីសម្គាល់គំនិត ទំនាក់ទំនង ឬបកស្រាយព័ត៌មានផ្សេងៗ គេហៅថាអ្វី?

ក. រូបតំណាង ខ. រូបសម្គាល់ គ. និមិត្តរូប ឃ. រូបភាពផ្សេងៗ

២. តើរូបជញ្ជីង តំណាងឱ្យអ្វី?

ក. ក្រសួងយុត្តិធម៌ ខ. មេធាវី គ. ចៅក្រម ឃ. ភាពមិនលំអៀង

៣. តើរូបក្បាលខ្មោច តំណាងអ្វី?

ក. កន្លែងគ្រោះថ្នាក់ ខ. កន្លែងមានមីន គ. កន្លែងមានបញ្ហា ឃ. កន្លែងមានរឿងរ៉ាវ

៤. តើរូបចាប់ដៃគ្នាតំណាងឱ្យអ្វី?

ក. ការសាមគ្គី ខ. ការរួបរួម គ. មិត្តភាព ឃ. ការសហការ

៥. តើរូបសញ្ញាលេខបូក តំណាងឱ្យអ្វី?

ក. កាកបាទក្រហម ខ. សុខាភិបាល គ. ឱសថស្ថាន ឃ. ឡានពេទ្យ

ខ. សំណួរបំពេញចន្លោះ

ចូរអ្នកបំពេញន័យនិមិត្តរូបនៅចម្លើយតាមរូបភាពនីមួយៗឱ្យបានត្រឹមត្រូវ៖(**រូបភាពយកចេញពីយូធូប**)



១. តើរូបកណ្តៀរតំណាងអ្វី? ចម្លើយ៖...**សាមគ្គីភាព**...



២. តើរូបព្រាបស តំណាងអ្វី? ចម្លើយ៖.....



៣. តើរូបក្រពើតំណាងឱ្យអ្វី? ចម្លើយ៖.....



៤. តើរូបទន្សាយ តំណាងឱ្យអ្វី? ចម្លើយ៖.....



៥. តើរូបភ្លើង តំណាងឱ្យអ្វី? ចម្លើយ៖.....



៦. តើរូបប្រាសាទអង្គរវត្ត តំណាងឱ្យអ្វី? ចម្លើយ៖.....



៧. តើរូបឆ្កែ តំណាងឱ្យអ្វី? ចម្លើយ៖.....



៨. តើរូបក្បាលខ្មោច តំណាងឱ្យអ្វី? ចម្លើយ៖.....

៣.៦. អំណានៈ ប្រាសាទសិលាខ្មែរ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើប្រាង្គប្រាសាទខ្មែរភាគច្រើនស្ថិតនៅក្នុងខេត្តណា?

ក. កំពង់ចាម ☑ខ. សៀមរាប គ. បាត់ដំបង ឃ. កំពង់ធំ

១. តើអត្ថបទអំណាន"ប្រាសាទសិលាខ្មែរ"ដកស្រង់និងកែសម្រួលពីសៀវភៅណា?

ក. អត្ថបទអក្សរសិល្ប៍ក្រសួងអប់រំ ខ. វប្បធម៌ អរិយធម៌

គ. កំណត់ត្រាប្រាសាទបុរាណ ឃ. ភាសាខ្មែរថ្នាក់ទី៧

២. តើអត្ថបទអំណាន"ប្រាសាទសិលាខ្មែរ"អ្នកនិពន្ធតែងជាបទអ្វី?

ក. បទកាកគតិ ខ. បទពាក្យ៧ គ.បទពាក្យ៤ ឃ. បទព្រហ្មគីតិ

៣. "ក្នុង១វគ្គមាន៤ឃ្លា។ ក្នុង១ឃ្លា មាន៧ព្យាង្គ"។ តើជារង្វាស់កាព្យបទអ្វី? តើជារង្វាស់កាព្យបទអ្វី?

ក. បទព្រហ្មគីតិ ខ. បទពាក្យ៤ គ. បទពាក្យ៧ ឃ. បទកាកគតិ

៤. "ព្យាង្គទី៧ ឃ្លាទី១ ចួននឹង ព្យាង្គទី៤ ឃ្លាទី២។ ព្យាង្គទី៧ ឃ្លាទី២ ចួននឹង ព្យាង្គទី៧ ឃ្លាទី៣ ចួននឹង ព្យាង្គទី៤ ឃ្លាទី៤ វគ្គទី១"។ តើជាចំណាប់ចួនបទអ្វី? ចួនបែបណា?

ក. បទពាក្យពាក្យ៨ ចួនក្នុងវគ្គ ខ. បទព្រហ្មគីតិ ចួនក្នុងវគ្គ

គ. បទពាក្យ៤ ចួនក្នុងវគ្គ ឃ. បទពាក្យ៧ ចួនក្នុងវគ្គ

៥. "ព្យាង្គទី៧ ឃ្លាទី៤ វគ្គទី១ ចួននឹង ព្យាង្គទី៧ ឃ្លាទី២ វគ្គទី២"។ តើជាចំណាប់ចួនបទអ្វី? ចួនបែបណា?

ក. បទកាកគតិ ចួនឆ្លងវគ្គ ខ. បទព្រហ្មគីតិ ចួនឆ្លងវគ្គ

គ. បទពាក្យ៧ ចួនឆ្លងវគ្គ ឃ. បទពាក្យ៤ ចួនឆ្លងវគ្គ

៦. តើប្រាសាទមួយណាដែលជាទីស្ងប់ស្ងែងជននានា?

ក. ប្រាសាទវិមានអាកាស ខ. ប្រាសាទតាព្រហ្ម

គ. ប្រាសាទបក្សីចាំក្រុង ឃ. ប្រាសាទបាយ័ន

៧. តើប្រាសាទមួយណាដែលបានកសាងក្នុងគ្រាសម័យមានឫទ្ធី?

ក. ប្រាសាទវិមានអាកាស ខ. ប្រាសាទតាព្រហ្ម

គ. ប្រាសាទបក្សីចាំក្រុង ឃ. ប្រាសាទបាយ័ន

៨. តើអ្នកកវីបានធ្វើការប្រៀបធៀបប្រាសាទអ្វី ដែលមានកម្ពស់ខ្ពស់ស្ទឹមស្មៃ?

ក. ប្រាសាទបាពួន ខ. ប្រាសាទបាកាន

គ. ប្រាសាទបាយ័ន ឃ. ប្រាសាទបក្សីចាំក្រុង

៩. តើប្រាសាទមួយណា ដែលគេហៅថាយសោធគិរី?

ក. ប្រាសាទបាពួន ខ. ប្រាសាទបាកាន

គ. ប្រាសាទបាយ័ន ឃ. ប្រាសាទបក្សីចាំក្រុង

១០. តើបច្ចុប្បន្ន រាជរដ្ឋាភិបាលពិសេសក្រសួងទេសចរណ៍បានចាត់ទុកប្រាសាទបុរាណខ្មែរជាតំបន់អ្វី?

ក. តំបន់អច្ឆរិយៈ ខ. តំបន់ទេសចរណ៍

គ. តំបន់សម្បត្តិបេតិកភណ្ឌជាតិ ឃ. តំបន់រមណីយដ្ឋានទេសចរណ៍

ខ. សំណួរត្រិះរិះ

១. ចូររាប់ឈ្មោះប្រាសាទនៅក្នុងអត្ថបទកំណាព្យនេះឱ្យអស់។

.....

.....

.....។

២. ចូរពន្យល់អត្ថន័យកំណាព្យវគ្គ"គឺជាពូជពង្សស្ថាបនិក ទុកជាចារឹកក្នុងសាវតារ ជាគោលសំខាន់ក្នុងខេមរា ឥតមានជាតិណាប្រលោមបាន"។

.....

.....

.....

.....

.....។

៣. ដើម្បីរក្សាកេរដំណែលវប្បធម៌ខ្មែរបានគង់វង្ស តើប្អូនត្រូវធ្វើដូចម្តេច?

.....

.....

.....

.....។

៤. តើនៅក្នុងអត្ថបទទាំងមូល អ្នកកវីបង្ហាញពីកេរដំណែលរបស់ជាតិនៅត្រង់កន្លែងណា?ចូរបកស្រាយ។

.....

.....

.....

.....

.....

គ. សំណួរផ្គូផ្គង

១. ចូរប្អូនផ្គូផ្គងន័យរបស់មេពាក្យនៅតារាង(ក) ជាមួយមេពាក្យនៅតារាង(ខ) រួចបំពេញចម្លើយនៅតារាង(គ) ឱ្យបានត្រឹមត្រូវ៖

ក	ខ	គ
១.(ន). សមដោយអំណាច អំណាចស្មើគ្នា។	ក. សូគ៌ា	១. → ឃ
២. (ន). ទេវលោក លោកទិព្វ ឋានទេវតា។	ខ. អស្ចារ្យ	២. →
៣. (ន). ភ្នំខ្ពស់ជាងភ្នំទាំងអស់ក្នុងពិភពលោក។	គ.អនុស្សាវរីយ៍	៣. →
៤. (គុ). ធំខ្ពស់សម្បើម ធំធេងល្វឹងល្វើយ។	ឃ. សក្តិសម	៤. →
៥. (ន). ពាក្យសន្មតហៅចេតិយដ្ឋានដែលសាងទុកជាទីរឭកដល់ហេតុ ឬរឿងដែលមិនគួរបំភ្លេចចោល។	ង. ស្តឹមស្តែ	៥. →
	ច. សុមេរុ	៦. →
៦. (កិ). ពាក្យសច្ចាប្រកាសសេចក្តីពិតត្រង់លាងខ្លួនចំពោះមុខបុគ្គល។	ឆ. ស្បថ	៧. →
៧. (គុ). ដែលគួរស្ងើចក្រៃលែង ដែលគួរទះដៃស្ងើចសរសើរ។		

២. ចូរប្អូនរើសពាក្យក្នុងប្រអប់ទៅបំពេញកំណាព្យបទព្រហ្មគីតិឱ្យបានត្រឹមត្រូវ៖

ពេកពន់ កល្យាណ ក្រអែបឯង ប្អូនតន់ ឱស្តាយ ឯណា ឱមាស ហាក់ព្រះចន្ទ ស្តេចស្តែង ទូញទន្ទឹង កន្ទិដ្ឋា ដឹងសម រិះធ្យាន ស្តាយ

-ទ្រង់ព្រះកន្សែងសោក សែនអមោក្សស្តាយ...**ពេកពន់**..

ព្រះផ្លូកព្រះ..... .....ទន្ទេញថា ។

- .....មិត្រកល្យាណ បងរកគ្មានស្រី.....

ឱ្យដូចកែវ..... ក្លិនក្រអូប..... ។

-.....ភក្ត្រសោភ័ណ .....ត្រចះចែង

សួនសមជា..... ឯក្សត្រីស្រី..... ។

-.....ចេះចែងចរចា ស្តាយប្រាជ្ញាចេះ.....

ដឹងអត់ដឹងឱនប្រាណ .....គួរគាប់ការ ។ [....]

(**ហរិវង្សរាមា អង្គឌួង កាកីទំព័រ១៧**)

៣.៧. អំណាន៖ រចាំត្រុដិ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើរចាំត្រុដិគេបានចាត់ទុកជារចាំអ្វី?

ក. រចាំបុរាណ ខ. រចាំសម័យ គ. រចាំព្រះរាជទ្រព្យ ☑ឃ. រចាំប្រជាប្រិយ

១. តើអត្ថបទអំណាន"រចាំត្រុដិ" អ្នកនិពន្ធដកស្រង់និងកែសម្រួលពីសៀវភៅណា?

ក. ប្រវត្តិរចាំប្រជាប្រិយខ្មែរ ខ. វប្បធម៌ អរិយធម៌ខ្មែរ

គ. ភាសាខ្មែរថ្នាក់ទី៧ ឃ. អត្ថបទអក្សសិល្ប៍

២. តើគេលេង"រចាំត្រុដិ" នៅពេលណាខ្លះ?

ក. ពេលសុំទឹកភ្លៀង ខ. ពេលចូលឆ្នាំខ្មែរ

គ. ពេលចូលឆ្នាំខ្មែរ និងសុំទឹកភ្លៀង ឃ. គ្រប់ពិធីបុណ្យផ្សេងៗ

៣. តើ"របាំត្រុដិ"មានអត្ថន័យដូចម្តេច?

ក. សូមសិរីសួស្តីឆ្នាំថ្មី ខ. ប្រសិទ្ធិពរសព្វសាធុការពរ

គ. សូមឱ្យមានភ្លៀងតាមរដូវ ឃ. ផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី

៤. តើសម័យមុន គេលេង"របាំត្រុដិថ្វាយ" អ្នកណា?

ក. ថ្វាយព្រះរាជា ខ. ថ្វាយអរុក្ខរក្សទេវតា គ. ថ្វាយព្រះពុទ្ធ ឃ. ថ្វាយអ្នកមានបារមី

៥. តើ"របាំត្រុដិ"មានបំណងសំខាន់ដើម្បីអ្វី?

ក. រក្សាមរតកសិល្បៈពីបុរាណ ខ. រក្សាអារ្យធម៌ចាស់

គ. ទម្លាប់ឱ្យអ្នកស្រុកមានសប្បុរសធម៌ ឃ. ចម្លើយទាំងបីខាងលើ

៦. ហេតុអ្វីបច្ចុប្បន្ន គេយករបាំនេះមកលេងជាសាធារណៈដោយមិនគិតពីអត្ថន័យរបស់របាំ?

ក. ព្រោះយកថវិកាទៅធ្វើបុណ្យតាមភូមិ ខ. ព្រោះជួយបម្រើប្រយោជន៍ជាសាធារណៈ

គ. ព្រោះជួយចូលរួមកសាងឬជួសជុលព្រះវិហារ ឃ. ចម្លើយទាំងបីខាងលើ

៧. តើចំណុចសំខាន់នៃរបាំត្រុដិត្រង់ណាដែលបង្ហាញថាបណ្តុះទម្លាប់អ្នកស្រុកឱ្យមានសប្បុរសធម៌?

ក. ចូលរួមថវិកាពេលរបាំត្រុដិលេង ខ. ចូលរួមធ្វើបុណ្យ ដាក់ទាន

គ. ចូលរួមកសាងកន្លែងធ្វើបុណ្យទាន ឃ. ចូលរួមបច្ច័យតាមសទ្ធាជ្រះថ្លាក្នុងចិត្ត

៨. តើសព្វថ្ងៃពិធីកាត់ផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មីគេហៅអ្វី?

ក. គេហៅ"ត្រស្តិសង្ក្រាន្ត" ខ. គេហៅ"បុណ្យចូលឆ្នាំខ្មែរ"

គ. គេហៅ"មហាសង្ក្រាន្ត" ឃ. គេហៅ"វីរៈឡើងស័ក"

ខ. សំណួរត្រិះរិះ

១. តើរបាំត្រុដិមានដើមកំណើតនៅខេត្តណាខ្លះ? ជនជាតិណាជាអ្នកផ្តើមលេងរបាំនេះមុនគេ? ព្រោះអ្វី?

.....

.....

.....

.....

.....។

២. តើអ្នកគិតថា គួរថែរក្សា"របាំត្រុដិ"នេះដូចម្តេច ដើម្បីកុំឱ្យបាត់បង់?

.....

.....

.....

.....។

៣. ចូរប្អូនរាប់ឈ្មោះរបាំប្រជាប្រិយខ្មែរ ដែលគេនិយមលេងរហូតមកដល់សព្វថ្ងៃនេះឱ្យបានត្រឹមត្រូវ។ (ប្អូនអាចស្រាវជ្រាវក្នុងយូធូប)

.....

.....

.....

.....។

៤. តើប្អូនពេញចិត្តនឹងរបាំប្រជាប្រិយខ្មែរមួយណា? ព្រោះអ្វី? ដើម្បីឱ្យបានសម្រេចសេចក្តីស្រឡាញ់របស់ប្អូន តើប្អូនត្រូវធ្វើដូចម្តេច?

.....

.....

.....

..... ។

គ. សំណួរផ្គូផ្គង

ចូរប្អូនរកពាក្យផ្ទុយពីតារាង(ក) ទៅបំពេញក្នុងតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
១. បុរាណ	**ក. សម័យ**
២. ផ្តាច់	ខ.
៣. ជិត	គ.
៤. រក្សា	ឃ.
៥. ចូល	ង.
៦. ច្រើន	ច.
៧. ចាស់	ឆ.
៨. ទឹក	ជ.

ចូរប្អូនផ្គូផ្គងសូរដូចពីតារាង(ក) ទៅតារាង(ខ) ដោយប្រើសញ្ញាព្រួញឱ្យបានត្រឹមត្រូវ៖

ក	ខ
១.(ន.) សរសេរអោសយដ្ឋាន។ ——→	កា
២.(ន.) ត្រចៀក។	
៣.(ន.) ហេតុ ។	ការ
៤.(ន.) អំពើត្រូវធ្វើ។	
៥.(ន.) ប្រដាប់ដាក់ទឹក។	ការណ៍
៦.(គុ.) ឃាត់ឃាំង រារាំង។	
៧.(កិ.) រៀបអាពាហ៍ពិពាហ៍។	កាណ៍
៨. (កិ.) មូរសសៃសូត្រ មូរសសៃអំបោះ។	

ឃ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

១. ឧទា៖(គុ.) ដែលជាទីស្រឡាញ់របស់ប្រជា ដែលគួរឱ្យស្រឡាញ់ពេញចិត្ត។ ចម្លើយ៖<u>ប្រជាប្រិយ</u>

២. (គុ.) ដែលកើតមានមុន ដែលមានយូរហើយ។ ចម្លើយ៖.....

៣. (ន.) ការតាក់តែង ការប្រដាប់ដំណើរធ្វើឱ្យសម្រេច។ ចម្លើយ៖.....

៤. (កិ.) តាំងផ្តើម ផ្តួចផ្តើម ផ្គងជាមុន។ ចម្លើយ៖.....

៥. (ន.) ការពន្យល់សេចក្តីដោយមានគ្រឿងអាង។ ចម្លើយ៖.....

៦. (ន.) ខ្ទម ផ្ទះ លំនៅរបស់អ្នកបួស។ ចម្លើយ៖.....

៧. (ន.) របងធ្វើដោយឥដ្ឋ ដោយថ្មឬភ្លឺដែលលើកព័ទ្ធជុំវិញទីណាមួយដើម្បីឱ្យដក់ទឹក។ ចម្លើយ៖.....

៨. (ន.) ដំណើរនៅមានជីវិត ការរស់នៅ ការចិញ្ចឹមជីវិត។ ចម្លើយ៖.....

៩. (ន.) ការដែលធ្លាប់ លំអានដែលធ្លាប់តែមានមក។ ចម្លើយ៖.....

១០. (ន.) លម្អគួរឱ្យស្រឡាញ់ សួស្តី ស្រីសួស្តី មង្គល។ ចម្លើយ៖.....

១១. (ន.) គុណជាតិជាគ្រឿងជម្រះសន្តានចិត្តកុសល អំពើល្អ សេចក្តីសុខ។ ចម្លើយ៖.....

១២. (កិ.) ទៅពីត្រើយម្ខាងទៅត្រើយម្ខាង កាត់រំលង។ ចម្លើយ៖.....

១៣. (ន.) បុរសអ្នកសប់ គឺមនុស្សប្រុសក្តីស្រីក្តី អ្នកមិនធ្វើអំពើអាក្រក់។ ចម្លើយ៖.....

៣.៨. ការស្តាប់ៈ ច្បាប់ស្រី

ចូរប្អូនអានអត្ថបទ មុននឹងជ្រើសរើសសំណួរខាងក្រោមៈ

អត្ថបទៈ ច្បាប់ស្រី

[....] ១. ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត ។
២. ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងស៊ីស្លា ។
៣. ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រឡាញ់ ។
៤. កុំជួរចិតស្មូរកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន ។
៥. កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី ។
៦. ទោះនឹងនិយាយស្រដី ការកេរ្តឺជាស្រី កុំស្តីឡេះឡោះ ។
៧. ថាលេងដូចក្មេងញ៉ៃះញ៉ោះ ឃើញប្រុសកម្លោះ សសៀរចូលជិត ។
៨. សើចព្រៀងបញ្ជៀងបញ្ជិត ប្រុសព្រើលបានចិត្ត រាហ៊ានដោយសារ ។
៩. ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន ។
[....] ១០. ភ្លើងក្រៅកុំនាំទៅក្នុង ឱ្យឆេះបំផ្លុង រឹងផ្លុំបង្កាត់ ។
១២. ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឱ្យឆេះឯក្រៅ ។
១៣. អុចអាលបណ្តាលឱ្យក្តៅ ដាលដល់កូនចៅ អសោចអប្រិយ ។
១៤. ឱ្យនាងខំប្រឹងស្មារតី មើលភ្លើងទាំងបី រក្សាឱ្យគង់ ។
១៥. ភ្លើងនោះឱ្យគុណពុំលង់ នឹងឱ្យឧត្តុង្ត ឧត្តមកន្លង ។
១៦. ភ្លើងមួយឱ្យនាងរក្សា ពីគុណមាតា បិតាស្ងួនគ្រង ។
១៧. ស្រីមួយដំណើរទាត់ជាយ លាន់ព្មស្ទើរធ្លាយ ប្រឹថពីសន្ធឹក ។
១៨. សំពត់ដាច់ដាចមិននឹក ដើរព្មគគឹក ស្មើសូររន្ទះ ។
១៩. ញ៉ាញ៉ើដំណើររលះ ដាក់ជើងលើផ្ទះ គគ្រាំគគ្រេង ។
២០. កក្រើកផ្ទះទាំងបីល្វែង ដូចកលគេសែង របស់ចេញទៅ ។
២១. ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្លងហួសទៅ មិនចាប់ចេញទុក ។

២២. ពុំចេរចំណេរទៅមុខ ពុំចេះដាក់ទុក រាយរាល់តែល្វែង ។

២៣. ទ្រព្យនោះរលោះចេញឯង ចង្រៃទាស់ទែង ធ្វើឱ្យអន្តរាយ ។[....]

(ដកស្រង់ចេញពីសៀវភៅភាសាខ្មែរថ្នាក់ទី៧ បោះពុម្ពឆ្នាំ១៩៩៧)

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើអត្ថបទស្តាប់"ច្បាប់ស្រី"អ្នកនិពន្ធឈ្មោះអ្វី

ក. សម្តេចសង្ឃរាជជួនណាត **ខ. អ្នកព្រះភិរម្យភាសាអ៊ូ**

☑គ. បណ្ឌិតម៉ឺន មៃ **ឃ. ឧកញ៉ាសន្ធរវោហាម៉ុក**

១. តើអត្ថបទស្តាប់"ច្បាប់ស្រី"នេះ អ្នកនិពន្ធតែងឡើងជាបទអ្វី?

ក. កាកគតិ ខ. ពំនោល គ. បន្ទោលកាក ឃ. ភុជង្គលីលា

២. ក្នុង១វគ្គ មាន៣ឃ្លា។ ឃ្លាទី១ មាន៦ព្យាង្គ ឃ្លាទី២និងទី៣ មាន៤ព្យាង្គ។ តើជារង្វាស់កាព្យបទអ្វី?

ក. ភុជង្គលីលា ខ. ពំនោល គ. កាកគតិ ឃ. បន្ទោលកាក

៣. ហេតុអ្វីបានជាអ្នកកវីតែងច្បាប់ស្រីនេះឡើង?

ក. ព្រោះចង់អប់រំឥរិយាបថមនុស្សស្រី ខ. ព្រោះចង់ឱ្យមនុស្សស្រីអនុវត្ត

គ. ព្រោះចង់អប់រំពីភារកិច្ចមនុស្សស្រីត្រូវតែធ្វើ ឃ. ចម្លើយទាំងបីខាងលើ

៤. "ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត"។ តើវគ្គនេះមានន័យដូចម្តេច?

ក. ឥរិយាបថលើការនិយាយស្តី ខ. ឥរិយាបថលើការទទួលភ្ញៀវ

គ. ឥរិយាបថលើការប្រាស្រ័យទាក់ទង ឃ. ឥរិយាបថជាស្រីគ្រប់លក្ខណ៍

៥. "កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី"។ តើវគ្គនេះមានន័យដូចម្តេច?

ក. កិត្តិយសក្នុងគ្រួសារកើតពីកូនស្រី ខ. គ្រួសារទាំងមូលពឹងទៅលើកូនស្រី

គ. សេចក្តីសុខក្នុងគ្រួសារកើតឡើងពីកូនស្រី ឃ. កូនស្រីត្រូវចេះរៀបឥរិយាបថឱ្យសមរម្យ

៦. តើភ្នក់ភ្លើងទីមួយជាអ្នកណា ដែលកូនស្រីត្រូវរក្សា?

ក. ឪពុកម្តាយបង្កើត ខ. ឪពុកម្តាយក្មេក គ. ប្តីឬប្រពន្ធ ឃ. ខ្លួនឯងផ្ទាល់

៧. “សើចព្រៀងបញ្ឆៀងបញ្ឆិត ប្រុសព្រើលបានចិត្ត វាហ៊ានដោយសារ”។ តើវគ្គនេះមានន័យដូចម្តេច?

ក. កូនស្រីត្រូវរក្សាឥរិយាបថឱ្យសមសួន ខ. កូនស្រីមិនត្រូវឡេះឡោះជាមួយមនុស្សប្រុស

គ. កូនស្រីមិនត្រូវឱ្យបុរសមើលងាយឡើយ ឃ. កូនស្រីត្រូវចេះស្រឡាញ់ខ្លួនឱ្យបានច្រើន

៨. តើភ្នក់ភ្លើងទាំងបី ដែលអ្នកកវីឱ្យកូនស្រីរក្សាមាននរណាខ្លះ?

ក. ឪពុកម្តាយបង្កើត ខ. ឪពុកម្តាយក្មេក

គ. ប្តីប្រពន្ធ ឃ. ប្តីប្រពន្ធនិងឪពុកម្តាយទាំងសងខាង

៩. តើភ្នក់ភ្លើងទីពីរជាអ្នកណា ដែលកូនស្រីត្រូវរក្សា?

ក. ឪពុកម្តាយបង្កើត ខ. ឪពុកម្តាយក្មេក

គ. ប្តី ឬប្រពន្ធ ឃ. ខ្លួនឯងផ្ទាល់

១០. តើភ្នក់ភ្លើងទីបីជាអ្នកណា ដែលកូនស្រីត្រូវរក្សា?

ក. ឪពុកម្តាយបង្កើត ខ. ឪពុកម្តាយក្មេក

គ. ប្តី ឬប្រពន្ធ ឃ. ខ្លួនឯងផ្ទាល់

១១. ហេតុអ្វីបានជាកូនស្រីត្រូវរក្សាភ្នក់ភ្លើងទាំងបី?

ក. ព្រោះជាស្រីមេផ្ទះ ខ. ព្រោះជាស្រីគ្រប់លក្ខណ៍

គ. ព្រោះជាច្បាប់ស្រី ឃ. ព្រោះចង់ឱ្យសុភមង្គលក្នុងគ្រួសារ

ខ. សំណួរត្រិះរិះ

១. ចូរបង្ហាញគំនិតសំខាន់នៅក្នុងអត្ថបទកំណាព្យនេះឱ្យបានត្រឹមត្រូវ។

.....

.....

.....

.....

.....

.....

.....។

២. ចូរបង្ហាញពីតម្លៃអប់រំនៅក្នុងអត្ថបទនេះ។

.....

.....

.....

.....

.....។

៣. ចូរសង្ខេបអត្ថបទកំណាព្យនេះជាពាក្យរាយ។

ឧទាហរណ៍៖ កូនស្រីទាំងអស់មិនគួរកំណាញ់នឹងពាក្យសម្តីនិយាយជាមួយញាតិមិត្តជិតខាងនោះឡើយ។

.....

.....

.....

.....

.....

.....

.....។

៤. ចូរប្លូនប្រៀបធៀបអត្តចរិតស្ត្រីសម័យមុន និងសម័យបច្ចុប្បន្ន។

ស្ត្រីសម័យមុន	ស្ត្រីសម័យបច្ចុប្បន្ន
ឧទា៖ ស្ត្រីមិនបានរៀនសូត្រជ្រៅជ្រះដូចបុរស។	ឧទា៖ ស្ត្រីបានរៀនសូត្រមានចំណេះដឹងស្មើបុរស។

៥. ហេតុអ្វីបានជាស្ត្រីសម័យបច្ចុប្បន្នមិនសូវកាន់ច្បាប់ស្រី ?

.....

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

១. ឧទា៖ (ន.) **អ្នករួមខ្សែឈាមនឹងគ្នាខាងមាតាបិតា។ ចម្លើយ៖ ញាតិ**

២. (គុ.) ដែលមិនជាទីស្រឡាញ់ ដែលពុំគួរស្រឡាញ់។ ចម្លើយ៖.....

៣. (គុ.) ដែលមានសេចក្តីសុខសាន្ត។ ចម្លើយ៖.....

៤. (ន.) អាចារៈ សណ្តាប់ធ្នាប់ របៀប របប ឫកពា។ ចម្លើយ៖.....

៥. (កិ.) ញ៊ុកញ៉ក់ ញ៉ែងញ៉ង។ ចម្លើយ៖.....

៦. (ន.) សេចក្តីនឹកឃើញ ការរឭកបាន ការរឭកឃើញមិនភ្លេច។ ចម្លើយ៖.....

៧. (កិ.) រំលង រំលងហួសទៅហើយ។ ចម្លើយ៖.....

៨. (ន.) ការខូចបង់សៀត ដំណើរខូចប្រយោជន៍។ ចម្លើយ៖.....

៩. (កិ.) កំរើក រញ្ជួយ របើកឡើង។ ចម្លើយ៖.....

១០. (ន.) ឧបទ្រព គឺសភាពដែលបង្អាប់ស្រីសួស្តី ដែលបណ្តាលឱ្យមានទុក្ខ។ ចម្លើយ៖.....

ចូរប្អូនរកពាក្យដែលមានន័យដូចមកបំពេញក្នុងចន្លោះខាងក្រោម៖

ឧទាហរណ៍៖សច្ចា៖ សច្ចៈ សត្យ ទៀង ស្មោះ

១. ឱវាទ៖.....

២. ប្រតិបត្តិ៖.....

៣. កាតព្វកិច្ច៖.....

៤. អប់រំ៖.....

ឃ. សំណួរផ្គូផ្គង

ចូរប្អូនគូសសញ្ញាព្រួញពីតារាង(ក)ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវចំពោះពាក្យផ្គុំទាំងអស់ខាងក្រោមនេះ៖

ក	ខ
១. ចូលចិត្ត	ក. ស្អប់ស្អាត់
២. ជិត	ខ. ជាប់ ជិត
៣. ផ្អែម	គ. ទូលាយ
៤. ស្រឡាញ់	ឃ. ល្វីង ជូចត់
៥. កំណាញ់	ង. ត្រជាក់
៦. ក្រៅ	ច. ស្អប់ខ្ពើម
៧. ក្តៅ	ឆ. ក្នុង
៨. គុណ	ជ. ឆ្ងាយ
៩. ធ្លុះធ្លាយ	ឈ. ស្អប់
១០. កក្រើក	ញ. ទោស

៣.៩. តែងសេចក្តីៈ ការតែងកំណាព្យ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវៈ

ឧទាហរណ៍ៈ តើការតែងកំណាព្យគេត្រូវគិតទៅលើប៉ុន្មានចំណុច?

ក. ២ចំណុច ☑ខ. ៣ចំណុច គ. ៤ចំណុច ឃ. ៥ចំណុច

១. តើចំណុចទាំងអស់នោះគិតទៅលើអ្វីខ្លះ?

ក. សេចក្តីផ្តើម និងសេចក្តីបញ្ចប់ ខ. តួសេចក្តី និងសេចក្តីបញ្ចប់

គ. ផ្តើម តួ និងបញ្ចប់ ឃ. ផ្តើមសេចក្តីនិងតួសេចក្តី

២. "មួយវគ្គមាន៣ឃ្លា។ ឃ្លាទី១ និងទី៣មាន៦ព្យាង្គ ឃ្លាទី២ មាន៤ព្យាង្គ"។ តើជារង្វាស់កាព្យបទអ្វី?

ក. បទភុជង្គលីលា ខ. បទពំនោល គ. បទពាក្យ៤ ឃ. បទបន្ទោលកាក

៣. ដើម្បីតែងកំណាព្យបទពំនោលមួយបានល្អ ដំបូងយើងត្រូវគិតទៅលើអ្វី?

ក. ចំណាប់ចួន ខ. ប្រធានបទ គ. ខ្លឹមសារ ឃ. ចួន ផ្ងួន រណ្តំ

៤. តើចំណុចបន្ទាប់ ក្នុងការតែងកំណាព្យបទពំនោល យើងត្រូវគិតទៅលើអ្វី?

ក. សេចក្តីផ្តើម ខ. តួសេចក្តី គ. សេចក្តីបញ្ចប់ ឃ. ខ្លឹមសារកំណាព្យ

៥. តើចំណុចបន្ទាប់ទៀត ក្នុងការតែងកំណាព្យបទពំនោល យើងត្រូវគិតទៅលើអ្វី?

ក. សេចក្តីផ្តើម ខ. តួសេចក្តី គ. សេចក្តីបញ្ចប់ ឃ. ខ្លឹមសារកំណាព្យ

៦. តើចុងបញ្ចប់នៃការតែងកំណាព្យបទពំនោល យើងត្រូវគិតទៅលើអ្វី?

ក. សេចក្តីផ្តើម ខ. សំណូមពរ គ. សេចក្តីបញ្ចប់ ឃ. ខ្លឹមសារកំណាព្យ

៧. តើបរិយាកាសបទពំនោល គេប្រើសម្រាប់តែងបែបណាខ្លះ?

ក. បង្ហាញពីកំហឹងក្រៃក្រោធ ខ. បង្ហាញពីពាក្យអង្វរករដល់នរណាម្នាក់

គ. បង្ហាញពីភាពភ័យខ្លាចរបស់អ្នកទន់ខ្សោយ ឃ. ចម្លើយទាំងបីខាងលើ

៨. តើបទណាដែលមានលក្ខណៈប្រហាក់ប្រហែលនឹងបទពំនោល?

ក. បទពាក្យ៨ ខ. បទភុជង្គលីលា គ. បទព្រហ្មគីតិ ឃ. បទកាកគតិ

ខ. **សំណួរបំពេញចន្លោះ**

ចូរប្អូនជ្រើសរើសពាក្យនៅក្នុងប្រអប់ទៅបំពេញចន្លោះកំណាព្យខាងក្រោមឱ្យបានត្រឹមត្រូវ៖

ស្រះស្រី លាមក ឈ្វេង តើនឹង ក្រហាយ បើមិន ទឹកថ្លុក យាត្រា ព្រះអង្គ ស្តេចស្តាប់ ពិសោធ រូបល្អ ពុំរើស ប្រណម្យ ចិត្តចង់ ចិន្តា សូវស្លាប់ អសារ ហួសហៀវ ក្នុងនាម្តេចជឿ ឧទរា សិនវ៉ា ប្រាជ្ញា ពាក្យ រូសរឹង

-ស្មានហង្សតែងស្រង់**<u>ស្រះស្រី</u>** ហង្សអ្វីអប្រិយ មកធឹកឯ.....ល្អក់។

-.....ចិត្តក៏អាក្រក់ ស្អុយក្រៃ..... ក្រអូបតែក្លិន.....។

-ចិត្តចៅ.....ធីធារ ហូរ.....ហា .....ពុំរកព្រៃកណា។

-នែមឹងអញនាំ..... វិលវឹងនគរា .....រាត្រីនេះឯង។

-កាកី.....ទូលថ្លែង សូមទានស្តេច..... មេត្តាករុណា.....។

-.....ដោយពាក្យគេថា ដោយកល..... បញ្ឆុក.....ឱ្យបង់។

- បើវាកូវែន..... ប្រៀបថាព្រះ..... មានកែវក្នុងព្រះ.....។

(**ដកស្រង់ចេញពីរឿងកាកី ហរិក្សរាមា អង្គឌួង**)

គ. លំហាត់អនុវត្ត

ប្រធានៈ ចូរប្អូនតែងកំណាព្យបទពំនោលនិយាយពី"ការថែរក្សាសម្បត្តិវប្បធម៌ជាតិ ពិសេសប្រាសាទអង្គរវត្ត"ឱ្យបានត្រឹមត្រូវ ចំនួន១០វគ្គ។

សូមប្អូនមើលចំណាប់ចួនបទពំនោលខាងក្រោម ដើម្បីតែងកំណាព្យ។



ឧទាហរណ៍ៈ ប្រាសាទសិលាខ្មែរល្អ- ល្អះខ្លាំងពេកណាស់ គ្មានគួប្រដូចបានឡើយ។

ក្បូរក្បាច់រចនាល្អហើយ ទេសចរគ្មានស្បើយ ចូលមកទស្សនាមិនឈប់។



.....

.....

.....

មេរៀនទី៤៖ សេចក្តីថ្លែថ្នូរ

៤.១. វេយ្យាករណ៍៖ នាមករណ៍ ឬករណនាម

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ “ពាក្យដែលសម្តែងនូវឈ្មោះមនុស្ស សត្វ វត្ថុ រុក្ខជាតិ”។ តើជានិយមន័យរបស់ពាក្យណា?

☑ក. នាម ខ. គុណនាម គ. នាមករណ៍ ឃ. នាមការក៍

១. នាមមានប៉ុន្មានបែប?

ក. ៥បែប ខ. ៦បែប គ. ៧បែប ឃ. ៨បែប

២. នាមបង្ហាញនូវមនុស្ស សត្វ វត្ថុ រុក្ខជាតិមិនចំពោះគឺទូទៅ តើជានាមអ្វី?

ក. នាមសាធារណ៍ ខ. នាមអសាធាណ៍ គ. នាមករណ៍ ឃ. នាមការក៍

៣. នាមបង្ហាញនូវមនុស្ស សត្វ វត្ថុ រុក្ខជាតិចំពោះមិនទូទៅ តើជានាមអ្វី?

ក. នាមសាធារណ៍ ខ. នាមអសាធាណ៍ គ. នាមករណ៍ ឃ. នាមការក៍

៤. នាមសំដែងសភាព ឬសកម្មភាព តើជានាមអ្វី?

ក. នាមសាធារណ៍ ខ. នាមអសាធាណ៍ គ. នាមករណ៍ ឃ. នាមការក៍

៥. តើនាមករណ៍ ឬករណនាម មានកំណើតមកពីណា?

ក. គុណនាម ខ. កិរិយាសព្ទ

គ. ពាក្យបន្ថែមដើមនិងពាក្យបន្ថែមចុង ឃ. ចម្លើយទាំងបីខាងលើ

៦. ពាក្យ”សេចក្តីថ្លៃថ្នូរ កំពៀច សីលធម៌ ស្រឡាញ់” តើពាក្យណាខ្លះជានាមករណ៍ឬករណនាម?

ក. សេចក្តីថ្លៃថ្នូរ ស្រឡាញ់ ខ. កំពៀច សីលធម៌

គ. ស្រឡាញ់ កំពៀច ឃ. សេចក្តីថ្លៃថ្នូ សីលធម៌

៧. តើទម្រង់” សេចក្តី + ថ្លៃថ្នូរ ” មានកំណើតមកពីណា?

ក. ពាក្យបន្ថែមដើម ខ. ពាក្យបន្ថែមចុង គ. គុណនាម ឃ. កិរិយាសព្ទ

ខ. សំណួរត្រិះរិះ

១. តើពាក្យណាខ្លះជានាមករណ៍ ឬករណនាម ក្នុងចំណោមពាក្យខាងក្រោមនេះ។

អ្នកប្រមឹក **ការការពារ** កសិករ សេចក្តីព្យាយាម ភាពសុខសាន្ត និស្សិត ការសិក្សា ការគោរព អ្នកនិពន្ធ សេចក្តីស្មោះត្រង់ អ្នកក្រុង អ្នកស្រែ ភាពត្រឹមត្រូវ ការស្រឡាញ់ សន្តិភាព ភារកិច្ច ការតព្វកិច្ច ជនបរទេស។

<u>ចម្លើយ</u>

ឧទាហរណ៍៖ ការការពារ < ការ + ការពារ

.....

.....

.....

.....

.....។

២. ចូរសរសេរពាក្យខាងក្រោមឱ្យទៅជានាមករណ៍ ឬករណនាម។

ប្រព្រឹត្ត ខុស អធិប្បាយ អនុញ្ញាត កើន ចម្រើន ពិសោធ រាប់អាន មោទន សោភណ ក្បែមក្បាន្ត ផ្តាច់ឆ្នាំចាស់ សិក្សា អំណត់ តស៊ូ។

ឧទាហរណ៍៖ ការ + ប្រព្រឹត្ត > ការប្រព្រឹត្ត

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

ក. សំណួរផ្គូផ្គង

ចូរប្អូនប្រើសញ្ញាព្រួញដើម្បីផ្គូផ្គងពាក្យជានាមពីតារាង(ក)ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
➢ ដើមស្វាយ ⟶	• នាមសាធារណ៍
➢ សេចក្តីត្រេកអរ	
➢ ប៉ារីស	
➢ ការដឹកនាំ	
➢ គោ	• នាមអសាធារណ៍
➢ សន្តិភាព	
➢ សមុទ្រ	
➢ សេចក្តីឈ្នានីស	
➢ សៀមរាប	• នាមករណ៍
➢ ការប្រតិព័ទ្ធ	
➢ បាងកក	

៤.២. វេយ្យាករណ៍៖ ការប្រើប្រាស់រាជសព្ទ សង្ឃសព្ទ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ហេតុអ្វីបានជាយើងត្រូវប្រើប្រាស់ភាសាខុសៗគ្នា?

ក. ព្រោះមនុស្សមានឋានៈខុសគ្នា **ខ. ព្រោះមនុស្សមានភាសាច្រើនត្រូវប្រើ**

☑គ. ព្រោះត្រូវគោរពតាមឋានៈតួនាទី **ឃ. ចម្លើយទាំងបីខាងលើ**

១. តើពាក្យរាជសព្ទ គេប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ព្រះពុទ្ធ

២. តើពាក្យសង្ឃសព្ទ គេប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ព្រះពុទ្ធ

៣. តើពាក្យ"ព្រះកន្សែង" គេប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ព្រះពុទ្ធ

៤. តើពាក្យ"ទ្រង់ព្រះកន្សែង" បើគិតជាពាក្យសាមញ្ញមានន័យដូចម្តេច?

ក. យំ ខ. សើច គ. ឈឺ ឃ. ទំនួញ

៥. តើពាក្យ"ខឹងខ្លាំង" បើប្រើជាពាក្យរាជសព្ទមានន័យដូចម្តេច?

ក. ខ្ញាល់ ខ. ព្រះពិរោធ គ. ប្រឈួន ឃ. ពិរោធ

៦. តើពាក្យ"សឹង" ប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ព្រះពុទ្ធ

៧. តើពាក្យ"ព្រះឱស្ឋ"ប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ព្រះពុទ្ធ

៨. តើពាក្យ"ព្រះភក្ត្រ"ប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ចម្លើយខនិងគ

៩. តើពាក្យ"គង់" ប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ព្រះពុទ្ធ

១០. តើពាក្យ"ប្រទាន ថ្វាយ"ប្រើជាមួយអ្នកណា?

ក. ប្រជារាស្ត្រ ខ. ព្រះមហាក្សត្រ គ. ព្រះសង្ឃ ឃ. ព្រះពុទ្ធ

ខ. សំណួរបំពេញចន្លោះ

ពាក្យសាមញ្ញ	ពាក្យរាជសព្ទ	ពាក្យសង្ឃសព្ទ
សក់	.....**ព្រះកេសា**.....	.....**កេសា**.....
.....	ប្រឈួន	.....
.....	.....	ឆាន់
បត់ជើងធំ	.....	.....
.....	ទ្រង់ព្រះសណ្តាប់	.....
.....	.....	ព្រះហស្ត
ម្ហូបអាហារ	.....	.....
.....	យាង	.....
.....	.....	សុគត

ចូរប្អូនរកពាក្យរាជសព្ទមកបំពេញនៅចន្លោះនីមួយៗឱ្យបានត្រឹមត្រូវ៖

ប៉ារីស ថ្ងៃទី២០ ខែសីហា ២០២១

.**បុត្រ**.សូមក្រាបថ្វាយបង្គំ.....ជាទីនឹករឭកដ៏ជ្រាលជ្រៅ!

អស់រយៈពេលជាច្រើនខែមកហើយ ដែល.....បានមករស់នៅទីក្រុងប៉ារីសប្រទេសបារាំង ដើម្បីបន្តការសិក្សា។ ក្នុងរយៈពេលនេះ.....មានសេចក្តីសុខជា ធម្មតាទេ ប៉ុន្តែ.....មានសេចក្តីនឹករឭកទៅដល់.....ជាពន់ពេក។.....មិនដឹងថា តើ.....មានសុខទុក្ខនិងមាន.....នឹករឭកមក..... ដែរឬយ៉ាងណា?

ចូរប្អូនរកពាក្យសង្ឃសព្ទមកបំពេញនៅចន្លោះនីមួយៗឱ្យបានត្រឹមត្រូវ៖

ព្រះសង្ឃគ្រប់ **អង្គ** ដែល.....នៅចាំ..... ត្រូវគង់នៅតែក្នុងវត្តអារាម មិនអាច.....ទៅគង់នៅទីកន្លែងផ្សេងៗបានឡើយ។ នៅពេលមាន បុណ្យទានម្តងៗ ប្រជាជននាំគ្នាយក.....ទៅ.....ព្រះសង្ឃ។

៤.៣. អំណាន៖ រឿងក្មេងកំព្រានិងព្រះចៅផែនដី

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍ តើរឿង"ក្មេងកំព្រានិងព្រះចៅផែនដី"ដកស្រង់និងកែសម្រួលពីណា?

ក. ប្រជុំរឿងព្រេងខ្មែរភាគទី១ **☑ខ. គតិលោកភាគ២**

គ. គតិលោកភាគ៣ **ឃ. ប្រជុំរឿងព្រេងខ្មែរភាគ២**

១. តើរឿង"ក្មេងកំព្រានិងព្រះចៅផែនដី"ជារឿងបែបអ្វី?

ក. ព្រេងកថា ខ. ទេវកថា គ. និទានកថា ឃ. ប្រលោមកថា

២. តើអ្នកនិពន្ធផ្តើមរឿងដោយប្រើពាក្យអ្វី?

ក. ចំណេរយូរលង់ ខ. កាលពីព្រេងនាយ គ. កាលពីយូរលង់ ឃ. ថ្ងៃមួយ

៣. ហេតុអ្វីបានជាក្មេងកំព្រាមិនព្រមដើរសុំទានគេ?

ក. ព្រោះជាក្មេងឧស្សាហ៍ព្យាយាម ខ. ព្រោះជាក្មេងមានការតស៊ូក្នុងជីវិត

គ. ព្រោះជាក្មេងមានឆន្ទៈ ឃ. ព្រោះជាក្មេងមិនពឹងលើកម្លាំងអ្នកដទៃ

៤. តើព្រះអង្គបានជួបនឹងក្មេងកំព្រានៅកន្លែងណា?

ក. ផ្ទះបាយ ខ. កន្លែងលាងចាន គ. រោងពិសេស ឃ. កន្លែងចុងភៅ

៥. ហេតុអ្វីបានជាព្រះអង្គឆ្ងល់នឹងក្មេងកំព្រាមកធ្វើការនៅក្នុងវាំង?

ក. ព្រោះចង់ដឹងពីទឹកចិត្តរបស់ក្មេង ខ. ព្រោះចង់ដឹងពីប្រាក់ខែក្មេងទទួលបាន

គ. ព្រោះចង់ស្តាប់ការនិយាយរបស់ក្មេង ឃ. ព្រោះចង់មើលពីការងាររបស់ក្មេង

៦. ហេតុអ្វីបានជាកុមារកំព្រាទូលស្តេចថាខ្លួនមានមាសប្រាក់ស្មើនឹងស្តេចផែនដី?

ក. ព្រោះឆ្លើយតាមការយល់របស់ក្មេង ខ. ព្រោះឆ្លើយតាមភាពឆ្លាតវៃរបស់ក្មេង

គ. ព្រោះឆ្លើយដោយភាពស្មោះត្រង់ ឃ. ចម្លើយទាំងបីខាងលើ

៧. តើនៅសម័យនោះប្រាក់ខ្មែរគេប្រើដូចម្តេចខ្លះ?

ក. រៀល ខ. កាក់ គ. សេន ឃ. ចម្លើយខនិងគ

៨. ហេតុអ្វីបានជាព្រះមហាក្សត្រទ្រង់ចារឹកពាក្យក្មេងកំព្រានោះថា"ពាក្យអ្នកប្រាជ្ញ"?

ក. ព្រោះជាការពិតមិនបំភ្លើស ខ. ព្រោះគិតតាមពាក្យឱវាទព្រះពុទ្ធ

គ. ព្រោះវាមកទទេទៅវិញទទេ ឃ. ព្រោះមនុស្សរស់ត្រឹមមួយឆ្អែត

៩. តើចំណុចត្រង់ណានៃរឿង ដែលបង្ហាញពីសេចក្តីថ្លៃថ្នូរ?

ក. ការតស៊ូរបស់ក្មេងកំព្រា ខ. អត្តចរិតរបស់ព្រះមហាក្សត្រ

គ. ពាក្យសម្តីរបស់ក្មេងកំព្រា ឃ. ការឱ្យតម្លៃនៃការងារ

ខ. សំណួរត្រិះរិះ

១. តើអ្នកយល់ថា ពាក្យព្រះមហាក្សត្រមានព្រះបន្ទូលជាមួយក្មេងកំព្រា ក្រោយពីឮសម្តីក្មេងកំព្រាជាការមើលងាយដែរឬទេ? ព្រោះអ្វី? ចូរបកស្រាយឱ្យបានច្បាស់លាស់។

.....

.....

.....

.....

.....។

២. ចូរអ្នកវិភាគតួអង្គព្រះមហាក្សត្រ និងតួអង្គក្មេងកំព្រាឱ្យបានត្រឹមត្រូវ។(គុណសម្បត្តិ និងគុណវិបត្តិ)

.....

.....

.....

.....

.....

.....

.....

.....

.....

៣. ចូរស្រង់ពាក្យរាជសព្ទពីក្នុងអត្ថបទរឿង"ក្មេងកំព្រានិងព្រះចៅផែនដី"។

.....

.....

.....

.....

.....

.....។

៤. ចូរស្រង់នាមករណ៍ឬករណនាមពីក្នុងអត្ថបទរឿង"ក្មេងកំព្រានិងព្រះចៅផែនដី"ឱ្យអស់។

.....

.....

.....

.....

.....។

៥. ចូរបង្ហាញពីតួអង្គឯក និងតួអង្គរងក្នុងរឿង"ក្មេងកំព្រានិងព្រះចៅផែនដី"។

.....

.....

.....

.....។

៦. ចូរបកស្រាយពាក្យរបស់កុមារកំព្រាទូលថ្វាយព្រះមហាក្សត្រថា"សព្វថ្ងៃខ្ញុំមានស្មើគ្នានឹងស្តេចផែនដី"ឱ្យបានក្បោះក្បាយដោយមិនគិតពីការបកស្រាយនៅក្នុងរឿង។

ឧទាហរណ៍៖ មនុស្សគ្រប់រូបតែងមានសិទ្ធិស្មើៗគ្នា មិនថាអ្នកមានឬអ្នកក្រ។ ប្រសិនបើយើងគិតឱ្យបានល្អិតល្អន់មានន័យថាមនុស្សកើតមកគ្មានអ្វីជាប់ខ្លួន ទោះបីស្លាប់ទៅវិញក៏គ្មានអ្វីជាប់ខ្លួនដូចគ្នា។(ទស្សនព្រះពុទ្ធ)

.....

.....

.....

.....

.....

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

- **ឧទាហរណ៍៖(ន.) មនុស្ស សត្វដែលគ្មានម្តាយ ឪពុក។ ចម្លើយ៖ <u>កំព្រា</u>**
- (ន.) ម្ហូបអាហារ នំចំណី។ ចម្លើយ៖.....
- (ន.) អ្វីៗដែលចំណេញ ដែលបានមកលើសដើម។ ចម្លើយ៖.....
- (ន.) សេចក្តីឱហាត សេចក្តីខ្មីឃ្មាតឬសង្វាត ការខំប្រឹងមិនខ្ជិល។ ចម្លើយ៖.....
- (ន.) ប្រាក់សម្រាប់ចាយ តម្លៃចាយប្រើ ដើមទុន។ ចម្លើយ៖.....
- (ន.) ថ្លៃដែលជួល មនុស្សដែលជួលមកប្រើ។ ចម្លើយ៖.....
- (គុ.) ដែលល្បីល្បាញ ដែលមានកេរ្តិ៍ឈ្មោះល្អ ដែលលេចឮច្បាស់លាស់។ ចម្លើយ៖.....
- (ន.) ការរាប់ ការស្គង់ គ្នេរ ស្មាន សេចក្តីដែលគួររាប់គួរយកជាការពិត។ ចម្លើយ៖.....
- (ន.) បេះដូង ដួងចិត្ត ចិត្ត ទ្រូង។ ចម្លើយ៖.....
- (កិ.) សម្រាន្ត គេង ដេក។ ចម្លើយ៖.....
- (ន.) ការពន្យល់សេចក្តីដោយមានគ្រឿងអាង។ ចម្លើយ៖.....
- (កិ.) ចារ សរសេរ កត់។ ចម្លើយ៖.....
- (កិ.) អស់ឃ្លាន អស់ស្រែក បានចម្អែតហើយ។ ចម្លើយ៖.....

ឃ. សំណួរផ្គូផ្គង

ចូរប្អូនផ្គូផ្គងពាក្យន័យដូច ពីតារាង(ក) ទៅតារា(ខ) រួចសរសេរចម្លើយនៅតារាង(គ)ឱ្យបានត្រឹមត្រូវ៖

ក	ខ	គ
១.សិក្សា ហាត់ ហ្វឹក ។	ក.ប្រជាពលរដ្ឋ	១. ⟶ ជ
២. ស៊ូទ្រាំ សង្កត់ចិត្ត ទ្រាំ អត់ធន់ ។	ខ. បុរី	២. ⟶
៣.ស្វិតស្រពោន ស្រពាប់ស្រពោន សោកសង្រេង ។	គ. ប្រសើរ	៣. ⟶
៤. បដិបត្តិ គោរព ប្រព្រឹត្ត ក្រាបប្រណិប័តន៍ ។	ឃ. ក្រៀមក្រំ	៤. ⟶
៥. អឺងកង កងរំពង អឺងអាប់ ។	ង. ប្រតិបត្តិ	៥. ⟶
៦. រដ្ឋ នគរ ប្រទេស ក្រុង រដ្ឋមណ្ឌល។	ច. គគ្រឹកគគ្រេង	៦. ⟶
៧.ថ្លៃថ្លា បវរ វិសេសវិសាល អស្ចារ្យ ឧត្តុង្គឧត្តម ខ្ពង់ខ្ពស់។	ឆ. អត់ធ្មត់	៧. ⟶
៨. ប្រជាជន ប្រជារាស្ត្រ ប្រជានិករ ។	ជ. រៀន	៨. ⟶

៤.៤. ទេយ្យាករណ៍៖ នាមការកិរិយាការគុណនាម

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើនាមមានប៉ុន្មានយ៉ាង?

ក. ៥យ៉ាង ខ. ៦យ៉ាង គ. ៧យ៉ាង ☑ឃ. ៨យ៉ាង

១. នាមដែលសម្តែងនូវសភាពឬសកម្មភាព។ តើជានាមអ្វី?

ក. នាមសាធារណ៍ ខ. នាមអសាធារណ៍ គ. នាមករណ៍ ឃ. នាមការក៍

២. តើនាមសម្តែងអ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ។ តើជានាមអ្វី?

ក. នាមសាធារណ៍ ខ. នាមអសាធារណ៍ គ. នាមករណ៍ ឃ. នាមការក៍

៣. តើនាមការក៍ឬការកនាម មានកំណើតមកពីណា?

ក. នាម កិរិយា ខ. គុណនាម គ. ពាក្យបន្ថែមដើមនិងបន្ថែមចុង ឃ. ចម្លើយទាំងបី

៤. តើពាក្យបន្ថែមចុងមានពាក្យអ្វីខ្លះជានាមការក៍?

ក. ករ បុគល វិទូ នារី ខ. ការិនី ជន អ្នក ភាព គ. បុគ្គល កម្ម ឃ. កិច្ច ភាព ធម៌

៥. តើពាក្យ"អ្នកក្រុង" ជានាមការក៍ ឬការកនាមមានកំណើតមកពីណា?

ក. អ្នក+ក្រុង(ន) ខ. អ្នក+ក្រុង(គុ)

គ. អ្នក+ក្រុង(កិ) ឃ. អ្នក+ក្រុង(ពាក្យបន្ថែមចុង)

៦. តើពាក្យ"អ្នកក្រីក្រ" ជានាមការក៍ ឬការកនាមមានកំណើតមកពីណា?

ក. អ្នក+ក្រីក្រ(ន) ខ. អ្នក+ក្រីក្រ(គុ)

គ. អ្នក+ក្រីក្រ(កិ) ឃ. អ្នក+ក្រីក្រ(ពាក្យបន្ថែមចុង)

៧. តើពាក្យ"អ្នកភ្ជួរ" ជានាមការក៍ឬការកនាមមានកំណើតមកពីណា?

ក. អ្នក+ភ្ជួរ(គុ) ខ. អ្នក+ភ្ជួរ(ពាក្យបន្ថែមចុង)

គ. អ្នក+ភ្ជួរ(កិ) ឃ. អ្នក+ភ្ជួរ(ន)

៨. តើពាក្យ"អ្នកប្រមឹក អ្នកឧស្សាហ៍" ជានាមការក៍ ឬការកនាមមានកំណើតមកពីណា?

ក. អ្នក+កិរិយានិងគុណនាម ខ. អ្នក+គុណនាមនិងនាម

គ. អ្នក+កិរិយានិងនាម ឃ. អ្នក+កិរិយាឬពាក្យបន្ថែមចុង

៩. តើពាក្យ"អច្ឆរិយបុគ្គល"ជានាមការក៍ ឬការកនាមមានកំណើតមកពីណា?

ក. នាម ខ. គុណនាម គ. ពាក្យបន្ថែមចុង ឃ. កិរិយាសព្ទ

១០. តើ"ជនបរទេស" ជានាមការក៍ឬការកនាមមានកំណើតមកពីណា?

ក. ជន+បរទេស(គុ) ខ. ជន+បរទេស(ពាក្យបន្ថែមចុង)

គ. ជន+បរទេស(កិ) ឃ. ជន+បរទេស(ន)

១១. "អ្នកចម្ការ"ជានាមការក៍ឬការកនាមមានកំណើតមកពី.....<u>លើកលែងតែ៖</u>

ក. អ្នក+ចម្ការ(កិ) ខ. អ្នក+ចម្ការ(គុ)

គ. អ្នក+ចម្ការ(ន) ឃ. អ្នក+ចម្ការ(ពាក្យបន្ថែមដើម)

១២. តើ"អ្នកចម្រៀង" ជានាមអ្វី?

ក. នាមសាធារណ៍ឬសាធារណនាម ខ. នាមករណ៍ឬករណនាម

គ. នាមអសាធារណ៍ឬអសាធារណនាម ឃ. នាមការក៍ឬការកនាម

ខ. លំហាត់បន្ថែម

១. ចូរស្រង់ពាក្យនាមការក៍ឬការកនាមពីចំណោមពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ៖

កម្មការិនី ភាពជូរចត់ សេចក្តីប្រាថ្នា វីរបុរស ការឈឺចាប់ ជនអនាថា ស្ថាបត្យករ សន្តិភាព ទ្រមាក់ដំរី ភាពសុខសាន្ត ទស្សនវិទូ និស្សិត សេចក្តីព្រមព្រៀង ការសន្តោស អ្នកភ្នំ សេចក្តីស្មោះស ជនល្មើស អ្នកស្រែ អ្នកប្រមឹក ជនពាល ការធ្វើទាន។

ឧទាហរណ៍៖ កម្មការិនី(ពាក្យបន្ថែមចុង កម្ម+<u>ការិនី</u>)

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

២. ចូរតែងល្អះដោយប្រើប្រាស់នាមការក៍ឬការកនាមឱ្យបាន១០ល្អះ។

ឧទាហរណ៍៖ <u>ជនល្មើស</u>ណាដែលបង្កអាណាធិបតេយ្យនៅក្នុងប្រទេស ត្រូវទទួលទោសតាមផ្លូចច្បាប់។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

គ. សំណួរផ្គូផ្គង

ចូរអ្នកប្រើសញ្ញាព្រួញផ្គូផ្គងពាក្យនាមក្នុងតារាង(ក)ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
១. អ្នកស្រុកភ្នំ	ក.នាមសាធារណ៍ ឬសាធារណនាម
២. ប្រទេសកម្ពុជា	
៣. ភាពមានះ	
៤. ដើមធុរេន	ខ. នាមករណ៍ឬករណនាម
៥. ជនបរទេស	
៦. អ្នកធំ	
៧. គោ ក្របី សេះ មាន់ ទា	គ. នាមអសាធារណ៍ ឬអសាធារណនាម
៨. ខេត្តរតនគិរី	
៩. សេចក្តីក្លាហាន	
១០. អ្នកជនបទ	ឃ. នាមការក៍ ឬការកនាម
១១. ភាពអស្ចារ្យ	
១២. ខ្មាន់	

៤.៥. បំណិនៈ កាលអាកាស

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ដូចម្តេចដែលហៅថា"កាល"?

☑ក. ពេល ខ. វេលា គ. ព្រឹត្តិការណ៍ ឃ. កន្លែង

១. ដូចម្តេចដែលហៅថា"អាកាស"?

ក. ពេល ខ. វេលា គ. ព្រឹត្តិការណ៍ ឃ. កន្លែង

២. តើពាក្យ"ក្នុងរជ្ជកាលស្តេច..." ជាអ្វីនៃរឿង?

ក. អាកាស ខ. កាល គ. សម័យកាល ឃ. បុរាណកាល

៣. ដូចម្តេចដែលហៅថា"កាលអាកាស"?

ក. ជាពេលវេលានិងទីកន្លែងនៃដំណើររឿងកើតឡើង ខ. ជាពេលវេលាឬទីកន្លែងនៃព្រឹត្តិការណ៍

គ. ពេលវេលានិងទីកន្លែងនៃហេតុការណ៍ ឃ. ចម្លើយទាំងបីខាងលើ

៤. តើពាក្យ" នៅក្នុងរាជវាំង...." ជាអ្វីនៃរឿង?

ក. អាកាស ខ. កាល គ. សម័យកាល ឃ. បុរាណកាល

៥. តើកាលនៃរឿងនីមួយៗមាននៅពេលណាខ្លះ?

ក. ពេលយប់ ថ្ងៃ ល្ងាច ខ. ពីព្រេងនាយ ពីសម័យដើម

គ.លុះយូរលង់ណាស់មកហើយ ឃ. ចម្លើយទាំងបីខាងលើ

៦. តើអាកាសនៃរឿងនីមួយៗមាននៅកន្លែងណាខ្លះ?

ក. មាត់បឹង ត្រពាំង នៅផ្ទះ ខ. នៅវាំង ក្នុងព្រៃ នៅគ្រប់ទីកន្លែង

គ. មិនអាចកំណត់បាន ឃ. ចម្លើយកនិងខ

៧. ហេតុអ្វីបានជាយើងត្រូវរៀនអំពីកាលអាកាស?

ក. រឿងណាក៏មានពេលវាលានិងទីកន្លែងដែរ ខ. ដើម្បីឱ្យដឹងពីរបៀបតែងរឿង

គ. ជាវិធីក្នុងការតែងរឿង ឃ. ព្រោះជាកត្តាចាំបាច់បំផុត

ខ. លំហាត់ត្រិះរិះ

១. ចូរអានរឿងខាងក្រោម រួចរកកាលនិងអាកាសឱ្យបានត្រឹមត្រូវ៖

រឿង៖ ម៉ៅស្វិត

កាលពីដើម មានអ្នកមានម្នាក់ឈ្មោះ"ម៉ៅ" ជាមនុស្សកំណាញ់ក្រៅតម្រា។ អ្នកផងតែងហៅគាត់ថា" ម៉ៅស្វិត" ព្រោះគាត់រិះសព្វគ្រប់ មិនដែលហូបឆ្ងាញ់ មិនដែលស្លៀកពាក់ថ្មី មិនដែលចូលបុណ្យទានរហូតដល់គ្រួសារគាត់រស់នៅក្នុងសភាពត្បិតត្បៀត ទ្រឹស្តិស្សូរជានិច្ច។ អ្នកស្រុកនិយាយពីគាត់

-តាម៉ៅអើយ ! ទៅជុះកាន់ដំបងទៅជាមួយផង ទុកវាយរុយ។

ថ្ងៃមួយ តាម៉ៅស្វិតទៅទារបំណុលពីគេនៅត្រើយម្ខាង។ ដល់មាត់កំពង់ គាត់សួរទៅអ្នកចម្លង៖

-ឱ្យខ្ញុំដោយសារទៅផងអ្នក?

អ្នកចម្លងឆ្លើយតប៖

-គ្មានកន្លែងអង្គុយទេ។

-ខ្ញុំអង្គុយនៅបាតទូកក៏បានដែរ។

អ្នកចម្លងទូកខ្ជិលឆ្លើយតប គាត់ក៏ឡើងទៅអង្គុយនៅបាតទូក។ ដល់ពេលចេញដំណើរ អ្នកចម្លងរុញទូកចេញពីកំពង់ រួចលោតឡើងលើទូក។ ដោយទូកឃ្លោង គាត់ភ្លាត់ជើងរកកលដួល ក៏ជ្រលួសដៃច្រត់ក្បាលម៉ៅស្ងិត។ ម៉ៅស្ងិតឡើងមុខក្រហមរួចស្រែក៖

-ម៉េចបានជាឯងច្រត់លើក្បាលអញ?

អ្នកចម្លងឆ្លើយតប៖

-បាទ ! ថ្នាក់ឥតថ្លៃលើទូកវាតែប៉ុណ្ណឹង !

✍✍✍✍

<u>ចម្លើយ</u>

កាល៖.....

.....។

អាកាស៖ .....

.....

.....។

២. ហេតុអ្វីបានជារឿងនីមួយៗត្រូវតែមានកាលនិងអាកាស?ចូរបកស្រាយ។

.....

.....

.....

.....

.....

.....។

៣. តើពេលវេលានិងទីកន្លែងនៃរឿងមានសារៈសំខាន់ដែរឬទេ? ព្រោះអ្វី?

.....

.....

.....

.....

.....

.....។

ក. សំណួរផ្គូផ្គង

ចូរអ្នកប្រើសញ្ញាព្រួញដើម្បីផ្គូផ្គងពាក្យនៅក្នុងតារាង(ក)ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
• ក្រោយពីចាកចេញ • នៅក្នុងព្រៃដ៏ស្ងាត់ជ្រងំ • នៅតាមផ្លូវ • កាលពីដើមឡើយ • នៅឯព្រៃស្ងាត់ • នាកណ្តាលយប់ស្ងាត់ • បន្ទាប់ពីពេលនោះ • លុះថ្ងៃមួយ • នៅពាក់កណ្តាលផ្លូវ • វេលាម៉ោង១រំលងអាធ្រាត្រ	កាល អាកាស

៤.៦. អំណាន៖ រឿងកុំត្រាប់តាមបង

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើរឿង"កុំត្រាប់តាមបង"ជារឿងបែបអ្វី?

ក. ព្រេងកថា☑ ខ. ទេវកថា គ. និទានកថា ឃ. ល្បើកកថា

១. តើរឿង"កុំត្រាប់តាមបង"ដកស្រង់និងកែសម្រួលពីណា?

ក. ប្រជុំរឿងព្រេងនិទាន ខ. រឿងប្រជាប្រិយខ្មែរ

គ. រឿងនិទាន ក្រសួងអប់រំ ឃ. ចម្លើយកខនិងគ

២. តើចំណងជើង"កុំត្រាប់តាមបង"មានន័យដូចម្តេច?

ក. កុំធ្វើដូចបង ខ. កុំអនុវត្តតាមបង គ. កុំប្រព្រឹត្តដូចបង ឃ. កុំធ្វើខុសដូចបង

៣. តើបងប្អូនពីរនាក់ក្នុងរឿង"កុំត្រាប់តាមបង" ជាកូនអ្នកណា?

ក. កសិករ ខ. សេដ្ឋី គ. អ្នកមានទ្រព្យសុកស្តម្ភ ឃ. អ្នកក្រីក្រ

៤. តើតួអង្គពេជ្រក្នុងរឿង"កុំត្រាប់តាមបង"មានតួនាទីជាអ្វីនៅក្នុងសង្គម?

ក. អ្នកជំនួញ ខ. កម្មករ គ. គ្រូបង្រៀន ឃ. កសិករ

៥. តើតួអង្គធឿនក្នុងរឿង"កុំត្រាប់តាមបង"មានតួនាទីអ្វីនៅក្នុងសង្គម?

ក. គ្មានការងារធ្វើ ខ. កសិករ គ. កម្មករ ឃ. លក់ដូរ

៦. ហេតុអ្វីបានជាធឿនគ្មានការងារធ្វើដូចពេជ្រជាប្អូន?

ក. ព្រោះខ្ជិលធ្វើការងារ ខ. ព្រោះអាងទ្រព្យសម្បត្តិឪពុក

គ. ព្រោះតែការសេពគប់មិត្ត ឃ. ព្រោះគ្មានឆន្ទៈក្នុងចិត្ត

៧. ហេតុអ្វីបានជាធឿនត្រូវជាប់ឃុំឃាំង?

ក. ព្រោះសេពគប់មិត្តខុស ខ. ព្រោះប្រព្រឹត្តអំពើអបាយមុខ

គ. ព្រោះមិនព្រមស្តាប់សម្តីប្អូន ឃ. ព្រោះតែឈ្លក់នឹងទ្រព្យសម្បត្តិ

៨. តើអ្នកណាជាអ្នកសួរសុខទុក្ខធឿននៅមន្ទីរឃុំឃាំង?

ក. មិត្តភក្តិធឿន ខ. ប្រពន្ធធឿន គ. ពេជ្រជាប្អូន ឃ. គ្មានអ្នកណាទាំងអស់

៩. ក្រោយពីចេញពីមន្ទីរឃុំឃាំង តើធឿនទៅប្រកបការងារអ្វី?

ក. កសិករ ខ. កម្មករ គ. លក់ដូរ ឃ. គ្រូបង្រៀន

១០. តើចំណុចត្រង់ណាទាក់ទងនឹងចំណងជើង?

ក. ធឿនមិនឱ្យប្អូនយកគំរូតាមខ្លួន ខ. ធឿនភ្ញាក់រឭកលែងធ្វើខុស

គ. ធឿនមិនចង់ឱ្យប្អូនជាប់ឃុំឃាំង ឃ. ចម្លើយទាំងបីខាងលើ

១១. ចំណុចបង្ហាញពីសេចក្តីថ្លៃថ្នូរត្រង់.....<u>លើកលែងតែ</u>៖

ក. ឥរិយាបថនិងទឹកចិត្តរបស់ធឿន ខ. ឥរិយាបថរបស់មិត្តភក្តិធឿន

គ. ឥរិយាបថនិងទឹកចិត្តរបស់ពេជ្រ ឃ. ឥរិយាបថនិងទឹកចិត្តលោកសេដ្ឋី

១២. តើពេជ្រជាប្អូន ជាមនុស្សដូចម្តេច?

ក. ជាមនុស្សមានឥរិយាបថល្អ ខ. ជាមនុស្សមានសេចក្តីថ្លៃថ្នូរ

គ. ជាមនុស្សឥស៊ី ស្រឡាញ់បង ឃ. ជាមនុស្សមានកិត្តិយស

១៣. តើបញ្ចប់រឿងអ្នកនិពន្ធបញ្ចប់ដូចម្តេច?

ក. មានសង្ឃឹម ខ. គ្មានសង្ឃឹម គ. ចេះកែខ្លួន ឃ. មិនចេះកែខ្លួន

ខ. សំណួរត្រិះរិះ

១. តើរឿង"កុំត្រាប់តាមបង" អ្នកណាជាតួអង្គឯក? អ្នកណាជាតួអង្គរង? អ្នកណាជាតួអង្គបន្ទាប់បន្សំ? អ្នកណាជាតួអង្គរំលឹក?

.....

.....

.....

.....

.....

.....

.....។

២. តើសកម្មភាពតួអង្គធឿនក្នុងរឿង"កុំត្រាប់តាមបង" បានបង្ហាញនូវភាពថ្លៃថ្នូរដែរឬទេ? ចូរបកស្រាយ។

.....

.....

.....

.....

.....

.....

.....។

៣. ចូររកកាលអាកាសពីក្នុងរឿង"កុំត្រាប់តាមបង" ឱ្យបានត្រឹមត្រូវ។

ឧទាហរណ៍៖ កាល៖ កាលពីដើម....។ អាកាស៖ នៅផ្ទះសេដ្ឋី....។

.....

.....

.....

.....

..... ។

៤. ចូរស្រង់នាមករណ៍ឬករណនាម និងនាមការ៍ឬការកនាមពីក្នុងរឿង"កុំត្រាប់តាមបង"។

ឧទាហរណ៍៖ នាមករណ៍៖ ភារកិច្ច.....។ នាមការ៍៖ សេដ្ឋី.....។

.....

.....

.....

.....

.....។

៥. ចូរបង្ហាញតម្លៃអប់រំនៅក្នុងរឿង"កុំត្រាប់តាមបង"។

.....

.....

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

១. ឧទាហរណ៍៖(ន.) អ្នកមានទ្រព្យឧត្តម អ្នកមានទ្រព្យច្រើន។ ចម្លើយ៖ <u>សេដ្ឋី</u>

២. (ន.)ទ្រព្យដំណែលឬទ្រព្យសម្បត្តិរបស់បុគ្គលស្លាប់។ ចម្លើយ៖.....

៣.(ន.) មារយាទ កិរិយា អាការកិរិយា បែបបទ។ ចម្លើយ៖.....

៤. (ន.) សេចក្តីសម្រេច សេចក្តីសម្រេចផលឬផលសម្រេច។ ចម្លើយ៖.....

៥. (ន.) ការធ្វើតាម ការកាន់វត្តប្រតិបត្តិ។ ចម្លើយ៖.....

៦. (កិ.) អាស្រ័យនៅ រាប់រក រាប់រកយកជាគ្នា។ ចម្លើយ៖.....

៧.(កិ.) និយាយលើកជើង លើកសរសើរឱ្យឡើងទឹកចិត្តហាក់ដូចជាទឹកជោរ។ ចម្លើយ៖.....

៨.(កិ.) រីករាយសប្បាយហួសពេក។ ចម្លើយ៖.....

៩. (កិ.) ខាំងរក្សាមិនឱ្យទៅណាតាមអំពើចិត្ត។ ចម្លើយ៖.....

ឃ. សំណួរផ្គូផ្គង

ចូរប្អូនប្រើសញ្ញាព្រួញ ដើម្បីផ្គូផ្គងពាក្យសូរដូចពីតារាង(ក) ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
១.(កិ.)ចាប់រឹតដោយគំនាប ឬ ឃ្នាប ។	ក. កេរ្តិ៍
២.(កិ.)រឹតដោយតង្កៀប ។	ខ. ព្រាប
៣.(កិ.) ដែលកំពុងពេញរកកលហៀរ។	គ. គាប
៤.(កិ.)ធៀប ប្រដូច ប្រដូចដោយធៀបគ្នា។	ឃ. កេរ
៥.(ន.)ឈ្មោះបក្សីមួយប្រភេទរូបរាងស្រដៀងនឹងលលកតែសម្បុរ ផ្សេងគ្នា ។	ង. ព្រៀប
	ច. កៀប
៦.(ន.)សេចក្តីសរសើរ ការល្បីខ្ចរខ្ចាយ។	ឆ. ប្រៀប
៧.(ន.)ដំណែល ជាសម្បត្តិរបស់ដូនតា។	

៤.៧. អំណានៈ រឿងព្រះរាជកុមារបួនអង្គ ត្រូវជ្រើសយកមួយអង្គសោយរាជ្យ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើរឿង"ព្រះរាជកុមារ៤អង្គត្រូវជ្រើសយកមួយអង្គសោយរាជ្យ" ដកស្រង់និងកែសម្រួលពីណា?

ក. សៀវភៅស្រីហិតោបទេស **ខ. សៀវភៅភាសាខ្មែរថ្នាក់ទី៧**

គ. សៀវភៅរឿងព្រេងខ្មែរភាគ២ **☑ឃ. សៀវភៅរឿងព្រេងខ្មែរភាគ៣**

១. តើរឿងនេះស្ថិតនៅក្នុងប្រភេទរឿងបែបអ្វី?

ក. ព្រេងកថា ខ. ល្បើកកថា គ. និទានកថា ឃ. ទេវកថា

២. ហេតុអ្វីបានជាគេត្រូវរើសរាជកុមារមួយអង្គសោយរាជ្យ?

ក. ព្រោះជាការកំណត់របស់នគរ ខ. ព្រោះព្រះនគរគ្មានស្តេចសោយរាជ្យ

គ. ព្រោះត្រូវស្វែងរកអ្នកដឹកនាំនគរ ឃ. ព្រោះប្រជារាស្ត្រត្រូវការស្តេច

៣. តើពួករាជបុរោហិតធ្វើដូចម្តេចទើបអាចរើសរាជកុមារឡើងសោយរាជ្យសម្បត្តិបាន?

ក. មើលលើរូបរាងរបស់រាជកុមារ ខ. ដាក់ជាប្រស្នាឱ្យរាជកុមារ

គ. ជ្រើសរើសតាមបែបរាជវាំង គ. ជ្រើសរើសដោយប្រើបញ្ញា

៤. តើរាជកុមារទីប៉ុន្មាន ដែលត្រូវរាជបុរោហិតជ្រើសរើសឱ្យឡើងសោយរាជ្យ?

ក. ទី១ ខ. ទី២ គ. ទី៣ ឃ. ទី៤

៥. តើប្រស្នារបស់ពួកបុរោហិត សួរទៅរាជកុមារទាំងបួនមានន័យដូចម្តេច?

ក. ឱ្យជ្រើសរើសរាជទេពីម្នាក់មួយអង្គ ខ. ឱ្យបង្ហាញពីឆន្ទៈផ្ទាល់ខ្លួន

គ. ឱ្យបង្ហាញពីរបៀបសន្តោសអ្នកបម្រើ ឃ. ឱ្យបង្ហាញពីអារម្មណ៍ផ្ទាល់ខ្លួន

៦. ហេតុអ្វីបានជារាជកុមារអង្គទី៤ ត្រូវក្រុមរាជបុរោហិតជ្រើសរើសជាអង្គស្តេច?

ក. ព្រោះព្រះអង្គជាស្តេចមានព្រហ្មវិហារធម៌ ខ. ព្រោះព្រះអង្គមានចិត្តសន្តោស

គ. ព្រោះព្រះអង្គជាជម្រើសចុងក្រោយ ឃ. ព្រោះព្រះអង្គស្រឡាញ់ប្រជារាស្ត្រ

៧. តើព្រះរាជកុមារទី៤ ជ្រើសរើសទេពីទីប៉ុន្មាន?

ក. ទី១ ខ. ទី២ គ. ទី៣ ឃ. ទី៤

៨. តើរាជទេពីទី៤ ជាព្រះនាងមានព្រះទ័យដូចម្តេច?

ក. ចេះប្រដៅខ្ញុំកំដរនៅក្នុងរាជវាំង ខ. ចេះចំណាយទ្រព្យផ្គត់ផ្គង់សាមណៈពាហ្មណ៍

គ. ចេះឱ្យទានស្មុមយាចក ឃ. មានព្រះទ័យស្រឡាញ់ប្រជារាស្ត្រ

៩. តើការឡើងសោយរាជ្យរបស់ព្រះរាជកុមារទីបួនកើតឡើងពីអ្វី?

ក. ពីព្រេងវាសនារបស់មនុស្ស ខ. ពីនិស្ស័យពីកំណើត

គ. ពីការវិនិច្ឆ័យត្រឹមត្រូវរបស់បុរោហិត ឃ. ពីឆន្ទៈរបស់អ្នកជ្រើសរើស

១០. តើចំណុចត្រង់ណានៅក្នុងរឿងដែលបង្ហាញពីសេចក្តីថ្លៃថ្នូរ?

ក. ការជ្រើសរើសរាជកុមារ ខ. បង្ហាញពីទឹកព្រះទ័យរបស់រាជទេពី

គ. បង្ហាញពីទឹកព្រះទ័យរបស់រាជកុមារ ឃ. បង្ហាញពីប្រស្នារបស់បុរោហិត

១១. តើព្រាហ្មណ៍និងរាជបុរោហិត កាត់សេចក្តីឱ្យរាជកុមារទី៤ឡើងសោយរាជ្យតាមរយៈអ្វី?

ក. តាមក្បួនច្បាប់ក្នុងរាជវាំង ខ. តាមគំនិតរួមគ្នារវាងព្រាហ្មណ៍និងបុរោហិត

គ. តាមការវិនិច្ឆ័យត្រឹមត្រូវមួយ ឃ. តាមការស្រឡាញ់ពេញចិត្តលើរាជកុមារ

ខ. សំណួរត្រិះរិះ

១. ចូររកតួអង្គឯង តួអង្គរង តួអង្គរំឭកក្នុងរឿង"រាជកុមារ៤អង្គ ត្រូវជ្រើសមួយអង្គសោយរាជ្យ"។

.....

.....

.....។

២. ចូរស្រង់ពាក្យរាជសព្ទ ដែលមានប្រើនៅក្នុងអត្ថបទរឿង"រាជកុមារ៤អង្គ ត្រូវជ្រើសមួយអង្គសោយរាជ្យ"។

.....

.....។

៣. ចូរបង្ហាញតម្លៃអប់រំនៅក្នុងរឿង"រាជកុមារ៤អង្គ ត្រូវជ្រើសមួយអង្គសោយរាជ្យ"។

.....

.....

.....

.....។

៤. ហេតុអ្វីបានជានគរមួយត្រូវតែមានព្រះមហាក្សត្រសោយរាជ្យសម្បត្តិ កាលពីសម័យនោះ?

.....

.....

.....

.....

.....។

៥. តើការជ្រើសរើសរាជកុមារឱ្យឡើងសោយរាជ្យនៅក្នុងរឿងនេះត្រឹមត្រូវដែរឬទេ? ចូរបកស្រាយ។

.....

.....

.....

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

ឧទាហរណ៍៖ (ន.) **សិល្បសាលា សិល្បគ្រឹះ។ ចម្លើយ៖ <u>សិល្បសាស្ត្រ</u>**

១. (ន.) មនុស្សដែលកំណត់តាមលទ្ធិបុរាណពីព្រេងនាយ។ ចម្លើយ៖.....

២. (ន.) ព្រាហ្មណ៍អ្នកបំពេញប្រយោជន៍ដល់បុរី។ ចម្លើយ៖.....

៣. (ន.) ជនដែលមានប្រាជ្ញាឈ្មោះ បណ្ដា ជនអ្នកប្រព្រឹត្តល្អ។ ចម្លើយ៖.....

៤. (កិ.) បានឡើងជាក្សត្រិយ៍ទ្រង់រាជ្យ។ ចម្លើយ៖.....

៥. (ន.) រថ សម្រាប់ជិះរំហើយកម្សាន្តចិត្ត។ ចម្លើយ៖.....

៦. (ន.) ពាក្យឬសេចក្តីដែលមានអាថ៌កំបាំង លុះតែអ្នកប្រាជ្ញវាងវៃទើបអាចដឹង។ ចម្លើយ៖.....

ឃ. សំណួរត្រូវ ឬខុស

ចូរប្អូនពិនិត្យខឹមសារនៅក្នុងតារាង(ក)រួចសរសេរចម្លើយត្រូវឬខុសត្រង់តារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
ឧទាហរណ៍៖ ព្រះរាជកុមារបួនអង្គចេញទៅរៀនសិល្បសាស្ត្រ។ ១. ព្រះរាជកុមារទាំងបួនបាននាំគ្នាយកអគ្គមហេសីក្រោយពីរៀនចប់។ ២. មានព្រះមហាក្សត្រនគរមួយបានសោយទីវង្គត។ ៣. ព្រាហ្មណ៍បុរោហិតបានប្រើប្រស្នាក្នុងការជ្រើសរើសក្សត្រឡើងសោយរាជ្យសម្បត្តិ។ ៤. រាជកុមារទី១ ត្រូវបានជ្រើសរើសឱ្យឡើងសោយរាជ្យ។ ៥. រាជទេពីអង្គទីមួយមានរូបឆោមល្អប្រពៃ។ ៦. រាជកុមារទី៤ បានជ្រើសរើសរាជទេពីទី៤ ធ្វើជាអគ្គមហេសី។ ៧. ព្រាហ្មណ៍បុរោហិតសម្រេចជ្រើសរើសរាជកុមារទី៤ ឡើងសោយរាជ្យ។ ៨. រាជកុមារទី ២ខឹងនឹងពួកបុរោហិត។ ៩. រាជទេពីទី៣ ចេះផ្គត់ផ្គង់សារពើទ្រព្យជង រក្សាទុកមិនឱ្យខ្ជាត់ខ្ជាយ ។ ១០. រាជទេពីទី៤ ចេះវត្តប្រតិបត្តិ ហើយចេះប្រដាប់ភោជនាហារដ៏មានរសជាតិឆ្ងាញ់ពិសា។ ១១. រាជកុមារទី១ ជ្រើសរើសយករាជទេពីទី៤ធ្វើជាអគ្គមហេសី។	**ត្រូវ**

១. សំណួរផ្គូផ្គង

ចូរប្អូនគូសសញ្ញាព្រួញផ្គូផ្គងខ្លឹមសារសូរដូចពីតារាង(ក) ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
១. **ឧទាហរណ៍៖(កិ.) កាត់ជាចំណិតៗ។** ⟶	ក. ចិត
២.(គុ.) ប្រទះនឹងរសជាតិប្រៃ ហឺរ ជូរ។	ខ. ផ្សារ
៣.(ន.) វិញ្ញាណសម្រាប់គិត។	គ. ចិត្រ
៤. (កិ.)កើតទុក្ខសង្រេងដោយក្តីសោកស្តាយស្រណោះ ឬដោយសេចក្តីអាល័យ។	ឃ. ផ្សា
៥. (ន.)ចំនួនលេខស្មើនឹងប្រាំពីរដប់ដង។	ង. ចិត្ត
៦. (ន.)ទីប្រជុំលក់ទំនិញ របស់ផ្សេងៗ។	ច. ផ្សារ
៧. (គុ.) ដែលគេផ្ទិតផ្ងំរួចហើយ គេច្រើនប្រើភ្ជាប់ជាមួយនាម។	ឆ. ផ្សា
៨.(អា.និ.) ព្រោះ ហេតុតែ ដោយ ហេតុ តាមតែ តាមតែចំណង់ ព្រោះតែចំណង់។	ជ. ផ្សា
៩. (ន.)ភ្ជាប់ភ្ជិតដោយទឹកអន្សារ។	ឈ. ផ្សា
១០. (កិ.) ផ្សងតាមកម្ម ផ្សងព្រេង ទ្រាំទ្រ ទ្រាំអត់ កាន់សេចក្តីសន្តោសតាមមានតាមបាន។	ញ. ចិត
១១. (កិ ឬ គុ.) ឈឺចាប់ពើតរោលរាលឆៀបៗដោយរបួស រលាត់។	ដ. ផ្សា

៤.៨. ការស្តាប់៖ រឿងស្តេចព្រហ្មទត្តនិងស្តេចស្រមោចខ្មៅ

ចូរប្អូនអានអត្ថបទស្តាប់ មុននឹងធ្វើសំណួរខាងក្រោម។

<u>អត្ថបទ</u>

កាលពីព្រេងនាយ មានស្តេចមួយអង្គព្រះនាមព្រហ្មទត្ត ជាស្តេចប្រកបដោយមហិទ្ធិឫទ្ធិល្បីសុសសាយពេញពិភពលោក។ គ្រប់ជនទាំងអស់មាននគរនាគ ហង្ស គ្រុឌ និងបណ្តាស្តេចសត្វនានា សុំចងមិត្តភាពជាមួយព្រះអង្គ។

កាលនោះមានស្តេចស្រមោចខ្មៅ ព្រមទាំងបរិវារជាច្រើនសែននាក់បាននាំគ្នាសុំចងមិត្តភាពនឹងស្តេចព្រហ្មទត្តដែរ។ អាមាត្យក៏ទទួលពាក្យនេះ ទៅទូលស្តេចៗតបវិញថា៖"សត្វស្រមោចជាសត្វតូច ថោកទាបណាស់មិនគួរប៉ាប់អាននាំឱ្យអាប់ឱនកិត្តិយសយើង ជាស្តេចមហាចក្រឡើយ។ នែ៎អាមាត្យ ឯងទៅប្រាប់ស្តេចស្រមោចវិញថា យើងមិនទទួលចងមិត្តភាពជាមួយទេ។ យើងទទួលរាប់អានតែពួកសត្វធំៗ....."។

ពេលនោះទីប្រឹក្សាម្នាក់បានឱ្យយោបល់ថា៖បពិត្រព្រះរាជា ! ធម្មតាជាងឈើ ឬជាងទងសឹងមានគ្រឿងដែកតូចធំ សម្រាប់ធ្វើការ។ កាលណាធំ ត្រូវប្រើគ្រឿងធំ។ កាលណាតូច ត្រូវប្រើគ្រឿងតូច។ ដូច្នេះការចងមិត្តភាព

ជាមួយស្តេចស្រមោចមិនមែននាំឱ្យអាប់ឱនកិត្តិយសឬក៏ថោកទាបដល់ព្រះនគរយើងឡើយ ថ្ងៃណាមួយព្រះអង្គនឹងត្រូវការកម្លាំងសត្វតូចៗនេះ ជាចាំបាច់មិនខាន។ សូមព្រះអង្គគិតឱ្យបានល្អិតល្អន់ផងចុះមុននឹងសម្រេចក្រាបទូល”

ស្តេចព្រហ្មទត្តស្តាប់ហើយរិះគិតបន្តិច ក៏បញ្ជាទៅអាមាត្យទាំងទើសទាល់ថា៖”អើ អាមាត្យ ! ឯងទៅប្រាប់ស្តេចស្រមោចថាយើងយល់ព្រមហើយ ប៉ុន្តែឱ្យស្តេចស្រមោចទាំងបរិវារ វិលត្រឡប់ទៅលំនៅដ្ឋានវិញចុះមិនបាច់ឡើងមកជួបជាមួយយើងទេ”។

ចំណែរតមកនាកាលសម័យមួយ នៅពេលដែលស្តេចព្រហ្មទត្តកំពុងសម្រាកមានសត្វក្លឹសមួយ បានវារចូលទៅក្នុងវន្ទព្រះកាណ៌ព្រះអង្គ។ ស្តេចព្រហ្មទត្តយកកង្ហារឆ្កឹះឆ្កៀលគ្រប់មធ្យោបាយ តែសត្វក្លឹសពុំព្រមចេញមកវិញសោះ។ ដោយឈឺចាប់ក្នុងព្រះកាណ៌ខ្លាំងពេកស្តេចព្រហ្មទត្តក៏ចាត់ឱ្យអាមាត្យទៅហៅស្តេចជាមិត្តទាំងអស់មកជួយ។ គេខំរិះរកផ្សំថ្នាំយ៉ាងណាពូកែស័ក្តិសិទ្ធិគ្រប់យ៉ាងមកបន្តក់ដាក់ក្នុងត្រចៀក តែផ្ទុយទៅវិញសត្វក្លឹសកាន់តែរុលចូលជ្រៅឡើងៗ។ ពេលនោះហើយ ទីប្រឹក្សាបានប្រាប់ស្តេចថា៖”បពិត្រព្រះរាជា ! ពេលនេះហើយដែលព្រះអង្គត្រូវពឹងពាក់ដល់ស្តេចស្រមោច”។ ឮហើយស្តេចពោលទាំងខឹងថា៖”លោកចង់ថាដូចម្តេច ! មិត្តរបស់យើងជាច្រើនសុទ្ធសឹងជាសត្វមានឫទ្ធិអំណាចធំៗជួយយើងមិនកើតផង ចុះទម្រាំសត្វស្រមោចគ្មានចេះអ្វីសោះយ៉ាងនេះ....តើអាចជួយយើងយ៉ាងម៉េចកើតទៅ....! ?”។ លោកទីប្រឹក្សាឆ្លើយតបថា៖”បើតាមខ្ញុំយល់ស្តេចស្រមោចច្បាស់ជាអាចជួយព្រះអង្គបានក្នុងកាល:ទេស:នេះ។ សូមព្រះអង្គទុកភារ:នេះឱ្យខ្ញុំចាត់ការចុះ....!”។ ទីប្រឹក្សាពោលចប់ ក៏ដើរទៅរកស្តេចស្រមោចនិយាយប្រាប់អំពីអាការ:រោគរបស់ស្តេចព្រហ្មទត្តចប់សព្វគ្រប់។ ស្តេចស្រមោចក៏ទទួលខ្លួនយកអាសា។ ស្តេចស្រមោចបានចាត់ឱ្យសេនាប្រាំនាក់ ដែលមានខ្លួនឯងធ្លាល់ជាអ្នកដឹកនាំចូលទៅក្នុងត្រចៀកស្តេច ហើយខាំអូសក្លឹសនោះចេញមកយ៉ាងងាយស្រួល ក្នុងរយៈពេលដ៏ខ្លី។

គេនាំគ្នាសរសើរស្តេចស្រមោចគ្រប់ៗគ្នា។ ស្តេចព្រហ្មទត្តបាត់ឈឺត្រចៀក បានពោលថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅដល់ស្តេចស្រមោច ហើយក៏ឈប់មើលងាយមិត្តរបស់ខ្លួនចាប់តាំងពីពេលនោះមក។

(ដកស្រង់ពីសៀវភៅរឿងកម្សាន្តខ្លីៗភាគ៣សម្រាប់កុមារ)

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើរឿងនេះដកស្រង់ចេញពីណា ?

ក. ដកស្រង់ចេញពីសៀវភៅភាសាខ្មែរថ្នាក់ទី៧ **☑ខ. ដកស្រង់ចេញពីសៀវភៅរឿងកម្សាន្តខ្លី**

គ. ដកស្រង់ពីរឿងព្រេងនិទានបុរាណ **ឃ. ចម្លើយទាំងបីខាងលើ**

១. ស្តេចព្រហ្មទត្តជាស្តេចដែលចូលចិត្ត.....<u>លើកលែងតែ៖</u>

ក. អួតអាង ខ. ប្រើអំណាចផ្តាច់ការ គ. មានព្រហ្មវិហារធម៌ ឃ. រើសអើងហាន:

២. ហេតុអ្វីបានជាស្តេចឯទៀតរួមទាំងស្តេចសត្វផងសុំចងមិត្តជាមួយស្តេចព្រហ្មទត្ត?

ក. ព្រោះខ្លាចបារមីស្តេចព្រហ្មទត្ត ខ. ព្រោះចង់ពឹងពាក់ស្តេចព្រហ្មទត្ត

គ. ព្រោះចង់រក្សាមិត្តភាពជាមួយស្តេចព្រហ្មទត្ត ឃ. ព្រោះចង់សាមគ្គីជាមួយស្តេចព្រហ្មទត្ត

៣. តើស្តេចសត្វមួយណា ដែលស្តេចព្រហ្មទត្តមិនចង់ចងមិត្តភាពជាមួយ?

ក. សេចគ្រុឌ ខ. ស្តេចស្រមោចខ្មៅ គ. ស្តេចនាគ ឃ. ស្តេចហង្ស

៤. ហេតុអ្វីបានជាស្តេចព្រហ្មទត្តមិនចងមិត្តភាពជាមួយស្តេចស្រមោចខ្មៅ?

ក. ព្រោះគិតថាជាសត្វតូចតាច ខ. ព្រោះស្អប់សត្វស្រមោចខ្មៅ

គ. ព្រោះគិតថាស្រមោចខ្មៅគ្មានសមត្ថភាព ឃ. ព្រោះមើលស្រាលសមត្ថភាពស្រមោចខ្មៅ

៥. ហេតុអ្វីបានជាស្តេចព្រហ្មទត្តសុខចិត្តចងមិត្តភាពជាមួយស្តេចស្រមោចខ្មៅ?

ក. ដោយសារមានអ្នកផ្តល់យោបល់ ខ. ដោយសារស្តាប់តាមសម្តីទីប្រឹក្សា

គ. ដោយសារអាណិតស្តេចស្រមោចខ្មៅ ឃ. ដោយសារគ្មានជម្រើស

៦. តើស្តេចព្រហ្មទត្តមានបញ្ហាអ្វីកើតឡើងនៅក្នុងព្រះកាយព្រះអង្គ?

ក. សត្វក្លឹសចូលព្រះកាណ៌ ខ. ឈឺព្រះកាណ៌គ្មានមូលហេតុ

គ. ឈឺចុកចាប់ពេញព្រះកាយ ឃ. ចម្លើយក ខនិងគ

៧. តើអ្នកណាជាអ្នកជួយព្រះអង្គឱ្យលែងឈឺព្រះកាណ៌?

ក. ស្តេចហង្ស ខ. ស្តេចគ្រុឌ គ. ស្តេចស្រមោចខ្មៅ ឃ. ស្តេចនាគ

៨. ក្រោយពីស្តេចស្រមោចខ្មៅជួយព្រះអង្គឱ្យបាត់ឈឺព្រះកាណ៌ តើស្តេចព្រហ្មទត្តមានព្រះទ័យដូចម្តេច?

ក. មើលឃើញពីតម្លៃស្តេចស្រមោចខ្មៅ ខ. អរគុណដល់ស្តេចស្រមោចខ្មៅ

គ. ស្រឡាញ់ស្តេចស្រមោចខ្មៅ ឃ. រំភើបពីអំពើល្អរបស់ស្តេចស្រមោចខ្មៅ

៩. តើតួអង្គណាជាតួអង្គដែលមានសេចក្តីថ្លៃថ្នូរ?

ក. ស្តេចស្រមោចខ្មៅ ខ. ស្តេចហង្ស គ. ស្តេចព្រហ្មទត្ត ឃ. ស្តេចនាគ

១0. តើសុភាសិតណាដែលទាក់ទងនឹងដំណើរឿង?

ក. ចេះឯងឱ្យក្រែងចេះគេ ខ. សាមគ្គីជាកម្លាំង គ. តក់ៗពេញបំពង់ ឃ. សឹមៗកុំបំបោល

ខ. សំណួរត្រិះរិះ

១. តើការរាប់អានមនុស្សមើលតែពីសម្បកក្រៅជាការត្រឹមត្រូវដែរឬទេ ? ព្រោះអ្វី ?

.....

.....

.....

.....

.....។

២. ចូរវិភាគគុណសម្បត្តិ និងគុណវិបត្តិតួអង្គស្តេចព្រហ្មទត្ត ទីប្រឹក្សា និងស្តេចស្រមោចខ្មៅ។

.....

.....

.....

.....

.....

.....

.....

.....

.....។

៣. ចូរបង្ហាញពីតម្លៃអប់រំនៅក្នុងរឿង"ស្តេចព្រហ្មទត្តនិងស្តេចស្រមោចខ្មៅ"។

.....

.....

.....

.....។

៤. ហេតុអ្វីបានជាស្តេចស្រមោចខ្មៅនៅតែជួយស្តេចព្រហ្មទត្តពេលសត្វក្លឹសចូលត្រចៀក ?

.....

.....

.....

.....

.....។

៥. ចូបកស្រាយពីទស្សនៈ"កុំមើលអ្វីតែពីសម្បកក្រៅ"ឱ្យបានក្បោះក្បាយ ដោយមានអំណះអំណាងក្នុងរឿងភ្ជាប់ជាមួយផង។

ឧទាហរណ៍ៈ នៅក្នុងលោកយើងនេះ មិនថាមនុស្សឬសត្វ ស្អាត ល្អឬអាក្រក់សុទ្ធមានលក្ខណៈសម្បត្តិខុសៗគ្នា។ យើងមិនអាចមើលគេតែពីសម្បកក្រៅដោយមិនបានឃើញពីសកម្មភាពនិងស្វែងយល់ពីចិត្តគំនិតរបស់គេបានឡើយ។ ជាក់ស្តែងតួអង្គស្រមោចខ្មៅ ទោះបីជារូបរាងតូចសម្បុរមិនល្អក៏មិនត្រាកដថាជាសត្វគ្មានប្រយោជន៍ដែរ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៦. តើក្នុងរឿង"ស្តេចព្រហ្មទត្តនិងស្តេចស្រមោចខ្មៅ"តួអង្គជាតួអង្គឯក ? តួអង្គរង ? តួអង្គបន្ទាប់បន្សំ ? និងតួអង្គរំឭក ?

.....

.....

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

១. ឧទាហរណ៍៖ ឫទ្ធិធំ ឬឫទ្ធិខ្លាំងក្រៃលែង ឬឫទ្ធិសម្បើម។ ចម្លើយ៖ <u>មហិទ្ធិឫទ្ធិ</u>

២. (ន.) បុរី ក្រុង។ ចម្លើយ៖.....

៣. (ន.) អ្នកចោមរោមកំដរ អ្នកហែហមជាកិត្តិយស។ ចម្លើយ៖.....

៤. (គុ.) ដែលអាប់អន់ទន់ទាប ដែលខ្វះលម្អ។ ចម្លើយ៖.....

៥. (ន.) យសសក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង។ ចម្លើយ៖.....

៦. (ន.) អ្នកពិចារណា ដំណើរស្ទង់ការ ការល្បងមើលឱ្យឃើញពិត។ ចម្លើយ៖.....

៧. (ន.) ការសម្រេចដោយអំណាច។ ចម្លើយ៖.....

៤.៩. តែងសេចក្តី៖ សំណេរអត្ថបទដោយប្រើរាជសព្ទ

ក. សំណួរត្រិះរិះ

១. ដើម្បីសរសេរអត្ថបទសំណេរ តើអ្នកត្រូវគិតប៉ុន្មានចំណុច ? អ្វីខ្លះ ?

.....

.....

.....

.....។

២. តើអ្វីទៅជារាជសព្ទ ? ចូររកពាក្យរាជសព្ទដែលមានន័យដូច" គេង យំ កូន ឪពុកម្តាយ បន្ទប់គេង ឈឺ និយាយ ពេញចិត្ត ហូប ត្រចៀក"។

.....

.....

.....

.....

.....

.....

.....។

៣. ហេតុអ្វីបានជាយើងត្រូវចេះសរសេរសំណេរដោយប្រើរាជសព្ទ?

.....

.....

.....

.....

.....។

៤. នៅពេលអ្នកសរសេរសំណេរដោយប្រើរាជសព្ទមួយបានល្អ តើអ្នកត្រូវធ្វើដូចម្តេច? ព្រោះអ្វី?

.....

.....

.....

.....។

ខ. លំហាត់អនុវត្ត



ប្រធានៈ ចូរប្អូនសរសេរសំណេរកថាខណ្ឌមួយដោយប្រើរាជសព្ទនិយាយអំពី"ព្រះមហាក្សត្រទ្រង់យាងសម្ពោធនិងសាកសួរសុខទុក្ខសិស្សានុសិស្សអំពីការសិក្សា" ឱ្យបានក្បោះក្បាយ។

មុននឹងអ្នកសរសេរ សូមធ្វើតាមការណែនាំខាងក្រោម៖

-តើព្រះមហាក្សត្រទ្រង់យាងទៅសម្ពោធនៅកន្លែងណា? នៅពេលណា?

-តើអ្នកណាខ្លះជារៀបចំកម្មវិធីមុននឹងព្រះរាជាយាងមកដល់?

-នៅពេលព្រះរាជាយាងមកដល់ តើគណៈអធិបតី លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សត្រូវធ្វើបដិសណ្ឋារកិច្ចយ៉ាងដូចម្តេចខ្លះ?

-តើអ្នកចូលរួមទាំងអស់មានទឹកចិត្តដូចម្តេច?

-តើព្រះរាជាមានព្រះឱង្ការអ្វីខ្លះទៅកាន់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូនៅក្នុងថ្ងៃសម្ពោធ?

-តើមានតំណាងសិស្សានុសិស្សឡើងធ្វើចំណាប់អារម្មណ៍ដែរឬទេ?

-តើព្រះមហាក្សត្រទ្រង់ប្រទានអំណោយអ្វីខ្លះដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ?

-តើគណៈអធិបតីលោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សធ្វើអ្វីខ្លះ ពេលព្រះមហាក្សត្រទ្រង់យាងត្រឡប់ទៅព្រះរាជវាំងវិញ?

សេចក្តីអធិប្បាយ

.....

.....

.....

មេរៀនទី៥៖ ពលរដ្ឋល្អ

៥.១. អំណាន៖ យុវជនកម្ពុជា

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ អំណាន"យុវជនកម្ពុជា" ជាប្រភេទអត្ថបទ....<u>លើកលែងតែ៖</u>

ក. អត្ថបទបែបអប់រំ **ខ. អត្ថបទបទសាកល្បង**

គ. អត្ថបទពាក្យរាយ **☑ ឃ. អត្ថបទអក្សរសិល្ប៍**

១. តើយុវជន គេគិតចាប់ពីអាយុប៉ុន្មានទៅ?

ក. ១៦ឆ្នាំ ខ. ១៧ឆ្នាំ គ. ១៨ឆ្នាំ ឃ. ១៩ឆ្នាំ

២. ហេតុអ្វីបានជាអ្នកនិពន្ធសរសេរថា យុវជនជាកម្លាំងយ៉ាងសំខាន់ក្នុងការរួមចំណែកកសាងជាតិ?

ក. ព្រោះយុវជនមានកម្លាំងពេញលេញ ខ. ព្រោះយុវជនជាសសរទ្រូងរបស់ប្រទេសជាតិ

គ. ព្រោះយុវជនជាអ្នកបន្តវេនពីរៀមច្បង ឃ. ចម្លើយទាំងបីខាងលើ

៣. ក្នុងនាមយុវជនមួយរូប តើត្រូវមានអ្វីនៅក្នុងខ្លួន?

ក. ត្រូវមានការភ្ញាក់រឭក ខ. ត្រូវមានការតាំងចិត្តខ្ពស់

គ. ត្រូវមានឆន្ទៈនិងសុជីវធម៌ ឃ. ត្រូវមានសតិអារម្មណ៍ឱ្យប្រសើរ

៤. ដើម្បីធ្វើការងារមួយឱ្យទទួលបានជោគជ័យ តើយុវជនត្រូវតែមានអ្វីជាមួយអ្នកនៅជុំវិញខ្លួន?

ក. ត្រូវមានសាមគ្គីភាព មិត្តភាព ខ. ត្រូវមានខន្តី សន្តោសប្រណី

គ. ត្រូវមានស្មារតីទទួលខុសត្រូវ ឃ. ត្រូវមានព្រហ្មវិហារធម៌

៥. តើគេចាត់ទុកយុវជនជាអ្វីសម្រាប់ប្រទេសជាតិ?

ក. ជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ ខ. ជាទំពាំងស្នងឫស្សីរបស់ប្រទេសជាតិ

គ. ជាកម្លាំងចលករនៅក្នុងការអភិវឌ្ឍជាតិ ឃ. ជាមនុស្សមានសមត្ថភាពពេញលេញ

៦. តើយុវកម្មករ និយុវកសិករ ត្រូវមានភារកិច្ចអ្វីខ្លះចំពោះប្រទេសជាតិ?

ក. ខិតខំបញ្ចេញសមត្ថភាពរបស់ខ្លួន ខ. ត្រូវរៀសរៀបំពេញការងារ

គ. ត្រូវខិតខំបង្កើនផលិតផលគ្រប់យ៉ាង ឃ. ចម្លើយទាំងបីខាងលើ

៧. តើយុវសិស្ស យុវនិស្សិត ត្រូវមានកាតព្វកិច្ចអ្វីខ្លះចំពោះប្រទេសជាតិ?

ក. ត្រូវខិតខំរៀនសូត្រឱ្យបានខ្ពស់ ខ. ត្រូវចូលរួមបណ្តុះបណ្តាលអ្នកជំនាន់ក្រោយ

គ. ត្រូវចូលរួមអភិវឌ្ឍជាតិ ឃ. ត្រូវចូលរួមស្ម័គ្រចិត្តធ្វើការងារសង្គម

៨. តើយុវជនត្រូវធ្វើដូចម្តេចដើម្បីចូលរួមអភិវឌ្ឍជាតិឱ្យរីកចម្រើន?

ក. ត្រូវរួបរួមគ្នាទាំងផ្លូវកាយ ផ្លូវចិត្ត ខ. ត្រូវរៀនសូត្រពីរៀមច្បងឱ្យបានច្បាស់លាស់

គ. ត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យបានល្អ ឃ. ត្រូវចូលរួមការងារក្នុងសង្គម

៩. ប្រសិនបើយុវជនរួបរួមកម្លាំងគ្នា តើប្រទេសជាតិនឹងទទួលបានអ្វី?

ក. ប្រទេសជាតិនឹងរីកចម្រើនគ្រប់វិស័យ ខ. ប្រទេសជាតិនឹងមានអរិយធម៌ខ្ពង់ខ្ពស់

គ. ប្រទេសជាតិនឹងមានសុខសន្តិភាព ឃ. ប្រទេសជាតិប្រាកដជាសម្បូរបែរ

១០. តើចំណុចត្រង់ណានៅក្នុងអំណានដែលបញ្ជាក់ពីពលរដ្ឋល្អ?

ក. យុវជនបំពេញភារកិច្ចតាមតួនាទី ខ. យុវជនចូលរួមអភិវឌ្ឍប្រទេសជាតិ

គ. យុវជនជួយលើកស្ទួយប្រទេសជាតិ ឃ. យុវជនចេះសាមគ្គីគ្នាចូលរួមកសាងជាតិ

ខ. សំណួរត្រិះរិះ

១. តើយុវជនត្រូវមានការតាំងចិត្តនិងឥរិយាបថបែបណាខ្លះដើម្បីឱ្យក្លាយជាពលរដ្ឋល្អ?

.....

.....

.....

.....

.....

.....

.....។

២. តើអ្នកនិពន្ធមានសេចក្តីសង្ឃឹមយ៉ាងដូចម្តេចខ្លះចំពោះយុវជនយើងនាពេលអនាគត?

.....

.....

.....

.....

.....។

៣. ចូរបង្ហាញតម្លៃអប់រំនៅក្នុងអត្ថបទអំណាន"យុវជនកម្ពុជា"។

.....

.....

.....

.....

.....។

៤. ចូរបកស្រាយ"ទំពាំងល្អឫស្សីល្អ ទំពាំងស្អុយឫស្សីស្អុយ"ជាន័យធៀបដោយភ្ជាប់ឧទាហរណ៍ផង។

ឧទាហរណ៍៖ ទំពាំងប្រៀបដូចជាយុវជនដែលជាអ្នកបន្តវេនក្នុងការធ្វើការងារបម្រើប្រទេសជាតិ។ នៅពេលដែលទំពាំងស្អុយរលួយ ហាក់ដូចជាសង្គមដែលពោរពេញទៅដោយយុវជនពាលអាវ៉ាសែដែរ។ ជាក់ស្តែង នៅក្នុងសង្គមបច្ចុប្បន្ន យុវជនមួយចំនួនមិនគិតប្រឹងប្រែងរៀនសូត្រ អាងលើទ្រព្យសម្បត្តិឪពុកម្តាយ ដើរលេងពាលា សេពគ្រឿងញៀនជាដើម។នេះជាទំពាំងដែលស្អុយរលួយគួរជីកបោះចោល។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៥. ក្នុងនាមអ្នកជាយុវជន តើអ្នកត្រូវធ្វើដូចម្តេចដើម្បីឱ្យក្លាយជាទំពាំងល្អ?

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

១. **ឧទាហរណ៍៖** (ន). **វ័យកម្លោះ ក្រមុំ។ ចម្លើយ៖ <u>យុវវ័យ</u>**

២. (ន.) ញាណតោងរំឭកនឹកឃើញ។ ចម្លើយ៖.....

៣. (ន.) ភាពដែលអាចធ្វើបាន។ ចម្លើយ៖.....

៤. (ន.) ការស្រុះស្រួលគ្នា ការរួបរួមគ្នា។ ចម្លើយ៖.....

៥. (ន.) អ្នកធ្វើស្រែចម្ការ។ ចម្លើយ៖.....

៦. (គុ.) ឧត្តមលើសលែង ប្រសើរកន្លង។ ចម្លើយ៖.....

គ. សំណួរផ្គូផ្គង

ចូរប្អូនរកពាក្យផ្ទុយនឹងពាក្យក្នុងតារាង(ក) ដាក់ក្នុងតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
១. ឧទាហរណ៍៖ យុវជន	**យុវនារី**
២. ស្មោះត្រង់	
៣. មើលងាយ	
៤. រហ័ស	
៥. បញ្ជេញ	
៦. សម័យ	
៧. ហូរហៀរ	
៨. រឹងមាំ	
៩. ខិតខំ	
១០. យូរអង្វែង	

ឃ. សំណួរបំពេញចន្លោះ

ចូរប្អូនរកពាក្យដែលមានន័យដូចមកបំពេញនៅចន្លោះនីមួយៗឱ្យបានត្រឹមត្រូវ៖

ឧទាហរណ៍៖ ពិសិដ្ឋ :ឧត្តម ខ្ពង់ខ្ពស់ ប្រសើរ ពិសី ល្អ ថ្លៃថ្លា។

១. ត្រិះរិះ :.....

២. វិវាទ :.....

៣. ស្ថាបនា : .....

៤. ផ្ទះ :.....

៥. ឧទរ :.....

៦. ម្តាយ :.....

៧. ឪពុក :.....

៥.២. វេយ្យាករណ៍៖ សញ្ញាជើងក្អែក(ុ)

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ សញ្ញាជើងក្អែកមានរាង.....៖

ក. សញ្ញាលេខបូក ខ. សញ្ញាកាកបាទ គ. សញ្ញាលេខគុណ ☑ ឃ. ចម្លើយកនិងខ

១. តើសញ្ញាជើងក្អែក(+) គេប្រើប៉ុន្មានបែប ?

ក. ៣បែប ខ. ៤បែប គ. ៥បែប ឃ. ៦បែប

២. (ក+ិ > កិ) តើគេប្រើសញ្ញាជើងក្អែកដើម្បីអ្វី ?

ក. សម្រាប់តភ្ជាប់រវាងព្យញ្ជនៈនិងស្រៈ ខ. សម្រាប់សំណេរតភ្ជាប់រវាងព្យាង្គនិងព្យាង្គ

គ. សម្រាប់សំណេរជ្រៀតព្យាង្គ ឃ. សម្រាប់ទាញសំឡេងឱ្យឡើងខ្ពស់

៣. (នុះន៎ ! ផ្ទះរបស់ខ្ញុំ !) តើគេប្រើសញ្ញាជើងក្អែកដើម្បីអ្វី ?

ក. សម្រាប់តភ្ជាប់រវាងព្យញ្ជនៈនិងស្រៈ ខ. សម្រាប់សំណេរតភ្ជាប់រវាងព្យាង្គនិងព្យាង្គ

គ. សម្រាប់សំណេរជ្រៀតព្យាង្គ ឃ. សម្រាប់ទាញសំឡេងឱ្យឡើងខ្ពស់

៤. (បុគ្គល(បុក-គល់)(បា. សំ. បុទ្គល)ចិត្ត វិញ្ញាណ រាងកាយ ខ្លួនប្រាណ។)គេប្រើសញ្ញាជើងក្អែកដើម្បី៖

ក. សម្រាប់តភ្ជាប់រវាងព្យញ្ជនៈនិងស្រៈ ខ. សម្រាប់សំណេរតភ្ជាប់រវាងព្យាង្គនិងព្យាង្គ

គ. សម្រាប់សំណេរជ្រៀតព្យាង្គ ឃ. សម្រាប់ទាញសំឡេងឱ្យឡើងខ្ពស់

៥. “ប្រទេសកម្ពុជាយើងជាប្រទេស+សម្បូរទៅដោយសម្បត្តិធម្មជាតិដ៏ច្រើនអនេក។” តើគេប្រើសញ្ញាជើងក្អែកដើម្បីអ្វី?

ក. សម្រាប់តភ្ជាប់រវាងព្យញ្ជនៈនិងស្រៈ ខ. សម្រាប់សំណេរតភ្ជាប់រវាងព្យាង្គនិងព្យាង្គ

គ. សម្រាប់សំណេរជ្រៀតព្យាង្គ ឃ. សម្រាប់ទាញសំឡេងឱ្យឡើងខ្ពស់

៦. “[ក-] + កាយ >កកាយ “ តើគេប្រើសញ្ញាជើងក្អែកដើម្បីអ្វី?

ក. សម្រាប់តភ្ជាប់រវាងព្យញ្ជនៈនិងស្រៈ ខ. សម្រាប់សំណេរតភ្ជាប់រវាងផ្នត់ដើម

គ. សម្រាប់សំណេរជ្រៀតព្យាង្គ ឃ. សម្រាប់ទាញសំឡេងឱ្យឡើងខ្ពស់

៧. “អ្នក + ស្រែ > អ្នកស្រែ “ តើគេប្រើសញ្ញាជើងក្អែកដើម្បីអ្វី?

ក. សម្រាប់តភ្ជាប់រវាងពាក្យបន្ថែមដើម ខ. សម្រាប់សំណេរតភ្ជាប់រវាងផ្នត់ដើម

គ. សម្រាប់សំណេរជ្រៀតព្យាង្គ ឃ. សម្រាប់ទាញសំឡេងឱ្យឡើងខ្ពស់

៨. ហេតុអ្វីបានជាអ្នកត្រូវរៀនសញ្ញាជើងក្អែក(+)?

ក. ដើម្បីឱ្យដឹងពីរបៀបប្រើសញ្ញាជើងក្អែក ខ. ជួយក្នុងការសរសេរឱ្យត្រូវតាមក្បួនវេយ្យាករណ៍

គ. ជាផ្នែកមួយនៅលើមុខវិជ្ជាភាសាខ្មែរ ឃ. ចម្លើយទាំងបីខាងលើ

ខ. លំហាត់អនុវត្ត

១. ចូរអ្នកសរសេរជ្រៀតព្យញ្ជនៈ ព្យាង្គឬពាក្យដែលគេភ្លេចសរសេរ(បទ ស្រុក ខ្លួន កាយ ផ្លូវ ជា) នៅក្នុងឈ្នះខាងក្រោម៖

- នៅតាមជនបទស្រែចម្ការនិងនៅតាមរោងចក្រឧស្សាហកម្មនានា យុវកសិករនិងយុវកម្មករខិតខំបញ្ចេញសមត្ថភាពរបស់ខ្លួន យ៉ាងអស់ពីចិត្តពីថ្លើម។
- ការរួមសាមគ្គីគ្នាទាំងផ្លូវ ទាំងវាចាចិត្ត ដើម្បីលើកអរិយធម៌ជាតិឱ្យរុងរឿងគឺជាភារកិច្ចរបស់យុវជន។ យុវជនសេចក្តីសង្ឃឹមរបស់មាតុភូមិ។

២. ចូរអ្នកពិនិត្យមើលពាក្យណាមួយខាងក្រោម ដែលត្រូវប្រើសញ្ញាជើងក្អែក(+)៖

- អូ ! មែនហើយ យុវជនកម្ពុជាពិតជាធនធានមនុស្សដ៏សំខាន់ពិតប្រាកដមែន។
- អូនមើលនុះន ! បក្សាបក្សីកំពុងហើរច្រវាត់លើផ្ទៃមេឃពណ៌ខៀវស្រងាត់។
- តើសុជាតិមានពេលអាចទៅចូលរួមក្នុងកម្មវិធីបុណ្យខួបប្រាំពីរថ្ងៃដែរឬទេ ? ចាស !
- អុញនុះ ! តារាមកដល់ហើយ !

៣. ចូរអ្នកប្រើសញ្ញាជើងក្អែក(+)ដើម្បីតភ្ជាប់ពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ៖

- ពលទោ(ពល់-)ន.(បា. ពល ទោ) ទាហានថ្នាក់ក្រោមបង្គស់។
- ឱសានវាទ(-ន៉ះវាត)ន.(បា. <ឱសាន វាទ)ពាក្យសម្តីក្រោយបង្គស់។
- គជសីហ៍(គៈជៈសី)ន. (សំ. គជ សីហ ឬសិង្ហ, បា. គជ សីហ) ឈ្មោះសត្វមានរូបដូចសិង្ហ តែមានប្រមោយដូចដំរី មាននិយាយតែក្នុងរឿងផ្សេងៗពីបុរាណ។
- ពលិការឬពលីការ(ពៈ-)ន. (សំ. បា. ពលិ ការ) កិរិយាធ្វើនូវពលី ការធ្វើពលី : តាំងពលីការ ធ្វើពលិការ។
- ពលបាលទោ ន.(បា. ពល បាល ទោ) ឋានន្តរនាយទាហានរងនៅក្នុងចន្លោះពលបាលត្រីនិងពលបាលឯក(ពលបាលថ្នាក់ទី២)។
- [បង-] កើត > បង្កើត
- [-អ ៈម-] ច្រើន > ចម្រើន
- [ប-] បោស > បបោស
- [-អ ៈម/ន-] គិត >គំនិត

៥.៣. វេយ្យាករណ៍៖ កិរិយាសុទ្ធ កិរិយាហេតុ

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ ដូចម្តេចដែលហៅថាកិរិយា?

☑ក. ពាក្យសម្តែងនូវអំពើ ឬសកម្មភាព **ខ. ពាក្យបញ្ជាក់នូវអំពើ ឬសកម្មភាព**

គ. ពាក្យបញ្ជាក់លក្ខណៈឱ្យកិរិយា **ឃ. ពាក្យបញ្ជាក់លក្ខណៈឱ្យសកម្មភាព**

១. តើកិរិយាដែលសម្តែងអំពើរបស់ប្រធាន ដែលធ្វើឡើងដោយខ្លួនឯងផ្ទាល់ គេហៅកិរិយាអ្វី?

ក. កិរិយាសកម្ម ខ. កិរិយាសុទ្ធ គ. កិរិយាអកម្ម ឃ. កិរិយាហេតុ

២. តើកិរិយាសម្តែងនូវអំពើរបស់ប្រធាន ដែលធ្វើឡើងគ្រាន់តែជាហេតុដើមចមប៉ុណ្ណោះ តើជាកិរិយាអ្វី?

ក. កិរិយាសកម្ម ខ. កិរិយាសុទ្ធ គ. កិរិយាអកម្ម ឃ. កិរិយាហេតុ

៣. “ គ្រូកំពុងបង្រៀនសិស្ស។” តើពាក្យណាជាកិរិយាហេតុ?

ក. កំពុង ខ. បង្រៀន គ. គ្រូកំពុង ឃ. បង្រៀនសិស្ស

៤. “សុភាពធ្វើលំហាត់កិច្ចការផ្ទះ។” តើពាក្យណាជាកិរិយាសុទ្ធ?

ក. សុភាព ខ. កិច្ចការ គ. ធ្វើ ឃ. ធ្វើលំហាត់

៥. “បង្រៀន ផ្តេក ផ្សឹក បញ្ឈរ” ជាកិរិយាហេតុ តើមានលក្ខណៈសម្គាល់ត្រង់ណា?

ក. ត្រង់ជាពាក្យកម្លាយ ខ. ត្រង់ន័យរបស់ពាក្យនោះ

គ. ជាពាក្យកម្លាយមានន័យធ្វើឱ្យ ឃ. ត្រង់ពេលគេផ្សំជាមួយពាក្យដទៃទៀត

៦. “រៀន ញញឹម ឈរ” ជាកិរិយាសុទ្ធ តើមានលក្ខណៈសម្គាល់ត្រង់ណា?

ក. ជាកិរិយាបង្គោល ខ. ជាកិរិយាតម្រូវឱ្យប្រធានធ្វើដោយខ្លួនឯង

គ. ជាពាក្យកម្លាយមានន័យធ្វើឱ្យ ឃ. ត្រង់ពេលគេផ្សំជាមួយពាក្យដទៃទៀត

ខ. លំហាត់អនុវត្ត

១. ចូរជ្រើសរើសកិរិយាសុទ្ធនិងកិរិយាហេតុ ដាក់ក្នុងតារាងឱ្យបានត្រឹមត្រូវ៖

ព្រុស ស្ងួង បង្ហើប ប្រយុទ្ធ បន្សាប ពន្យឺត ដុត ស្រុះស្រួល បញ្ឈឺ ធ្វើ សើច បង្កើត បង្កើន។

កិរិយាសុទ្ធ	កិរិយាហេតុ
ឧទាហរណ៍៖ ព្រុស	បង្ហើប

២. ចូរអ្នកតែងល្អះដោយប្រើ៖

ក. កិរិយាសុទ្ធ៖ រលឹក សាយ សឹក យំ

.....

.....

.....

.....។

ខ. កិរិយាហេតុ៖ ផ្សឹក ផ្ទុក រំឭក បង្ខំ

.....

.....

.....

.....។

៣. ចូរស្រង់កិរិយាសុទ្ធនិងកិរិយាហេតុក្នុងអត្ថបទដកស្រង់ខាងក្រោមនេះ៖

[....] ឯក្បាលត្រីដោយមានឆ្អឹងធំក៏ធ្ងន់ចុះ ខ្លាត្រីក៏ពោល៖"អះអ៎ា ! ខាងនេះធ្ងន់ជាងត្រូវយកសាច់ចេញខ្លះទើបបាន"។ ថាហើយក៏លូកយកក្បាលត្រីចេញពីអ៊ុយ ហើយឱ្យខាំស៊ីត្រង់សាច់អមក ហើយដាក់ថ្លឹងទៀត។ ថ្លឹងម្តងនេះ ខាងក្បាលស្រាលបះឡើង ឯខាងកន្ទុយក៏ធ្ងន់ចុះ។ ខ្លាត្រីក៏ពោល៖"អះអ៎ា ! ខាងនេះចាស់ជាង ត្រូវយកសាច់ចេញខ្លះ"។ ថាហើយក៏លូកយកកន្ទុយចេញពីអ៊ុយ ហើយឱនខាំស៊ីសាច់ខាងគល់កន្ទុយនោះ ហើយដាក់ថ្លឹងទៀត។ លើកនេះថ្លឹងទៅខាងកន្ទុយស្រាលបះឡើង ខ្លាត្រីក៏លូកយកក្បាលមកខាំស៊ី ហើយដាក់ថ្លឹងតទៅទៀត។ ខ្លាត្រីថ្លឹងក្លែងមិនឱ្យស្មើ ហើយម្តងស៊ីខាងនេះ ម្តងស៊ីខាងនោះទាល់តែអស់សាច់រេចនៅតែឆ្អឹងទាំងសងខាងទើបថ្លឹងឯក្រោយឱ្យស្មើបាន ហើយក៏ដាក់ចុះចាកត្រាជូ ហៅភេទាំងពីរ៖"ចៅឯងទាំងពីរចូរមើលចុះយើងថ្លឹងចែកនេះត្រូវដោយយុត្តិធម៌ល្អហើយ តាមចិត្តចៅណាយកភាគខាងណាក៏យកទៅចុះ ភាគទាំងពីរនេះមិនលើសមិនខ្វះទេ"។[...]

កិរិយាសុទ្ធ៖

.....

.....។

កិរិយាហេតុ៖

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកកិរិយាសុទ្ធ មកបំពេញក្នុងចន្លោះល្អះខាងក្រោមឱ្យបានត្រឹមត្រូវ៖

ម៉ែឪ គឺជាអ្នកមានឧបការគុណមហាធំរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ តាំងពីកូនចាប់កំណើតក្នុងឧទរ ម៉ែឪតែងរិះរកគ្រប់មធ្យាបាយដើម្បីថែរក្សា។ ឪពុក...**ខិតខំ**...ធ្វើកិច្ចការសព្វសារពើ ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ។ ពេល ....ម៉ែតែងមានស្មារតីប្រុងប្រយ័ត្នជានិច្ច។ ម្តាយមិនហ៊ាន.....ចំណីអាហារតាមចិត្តចង់ទេ ព្រោះខ្លាចប៉ះពាល់ដល់ទារក ទារិកាក្នុងផ្ទៃ។ ពេលប្រសូត្រ ម៉ែសែន.....ឥតឧបមាលុះត្រាតែបុត្រប្រសូត្ររួចទើបបានស្បើយ។

៥.៤. អំណាន៖ រឿងគង់ហ៊ាន

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើរឿង"គង់ហ៊ាន" ដកស្រង់ចេញពីណា?

ក. ភាសាខ្មែរទី៧ **☑ខ. ប្រជុំរឿងព្រេងខ្មែរ** **គ. រឿងនិទាន** **ឃ. រឿងកម្សាន្តកុមារ**

១. តើតួអង្គប្រុសក្នុងរឿង"គង់ហ៊ាន" ដំបូងឈ្មោះអ្វី?

ក. គង់ហ៊ាន ខ. បុរសកំសត់ គ. គង់ ឃ. នាយគំ

២. តើបុរសគង់ទទួលបានឈ្មោះជាគង់ហ៊ាននៅពេលណា?

ក. ពេលវាយខ្លាស្លាប់ ខ. ពេលប្រយុទ្ធជាមួយសត្រូវ

គ. ពេលសម្លាប់ក្រពើ ឃ. ចម្លើយទាំងបីខាងលើ

៣. តើប្រពន្ធរបស់គង់ហ៊ានជាស្ត្រីដូចម្តេច?

ក. ស្ត្រីរឹងមាំ ខ. ស្ត្រីទន់ខ្សោយ គ. ស្ត្រីក្លាហាន ឃ. ស្ត្រីគោរពប្តី

៤. ហេតុអ្វីប្រពន្ធទាំងពីរមិនចេះឈ្លោះគ្នា?

ក. ព្រោះចេះអត់ឱនឱ្យគ្នាទៅវិញទៅមក ខ. ព្រោះជាស្ត្រីមានសាមគ្គីគ្នា

គ. ព្រោះគង់ហ៊ានចេះអប់រំណែនាំ ឃ. ព្រោះមាននិស្ស័យជាមួយគង់ហ៊ាន

៥. តើតួអង្គគង់ហ៊ានជាមនុស្សប្រុសដូចម្តេច?

ក. ប្រុសកំសាក ខ. ប្រុសកម្លិល គ. ប្រុសអាងស្ត្រី ឃ. ប្រុសក្លាហាន

៦. តើកេរ្តិ៍ឈ្មោះល្បីល្បាញរបស់គង់ហ៊ានបានឮទៅដល់អ្នកណា?

ក. ព្រះមហាក្សត្រ ខ. មន្ត្រីក្នុងវាំង គ. ប្រជាជនក្នុងភូមិ ឃ. ពួកសត្រូវ

៧. តើភាពល្បីល្បាញកេរ្តិ៍ឈ្មោះរបស់គង់ហ៊ានកើតឡើងដោយសារអ្វី?

ក. ដោយសារប្រពន្ធទាំងពីរ ខ. ដោយសារព្រេងសំណាង

គ. ដោយសារសម្ភាយបុណ្យ ឃ. ដោយសារភាពក្លាហាន

៨. តើសុភាសិតមួយណា ដែលទាក់ទងនឹងរឿង"គង់ហ៊ាន"?

ក. សឹមៗកុំបំបោល ខ. សំណាបយោងដីស្រីយោងប្រុស

គ. ងើយស្តុក ឱនដាក់គ្រាប់ ឃ. សាមគ្គីនាំមកនូវជោគជ័យ

៩. តើភរិយាដែលជួយយោងកិត្តិយសប្តី ជាភរិយាដូចម្តេច?

ក. ភរិយាពោរពេញដោយថាមពល ខ. ភរិយាដែលចេះគោរពស្វាមី

គ. ភរិយាគ្រប់លក្ខណ៍ ឃ. ភរិយាមានសមត្ថភាព

១០. តើរឿងនេះអ្នកនិពន្ធផ្តើមដោយប្រើពាក្យដូចម្តេច?

ក. កាលពីព្រេងនាយ ខ. កាលពីយូរលង់ណាស់មកហើយ

គ. មានរឿងមួយតំណាលថា ឃ. បុរសម្នាក់ឈ្មោះគង់

១១. អ្នកនិពន្ធបញ្ចប់រឿងដោយ.....<u>លើកលែងតែ៖</u>

ក. ឱ្យតួអង្គមានកិត្តិយស ខ. ឱ្យតួអង្គមានទ្រព្រសម្បត្តិ

គ. ឱ្យតួអង្គមានសំណាង ឃ. បញ្ចប់ឱ្យតួអង្គវេទនាព្រាត់ប្រាស់គ្នា

១២. តើចំណុចត្រង់ណានៅក្នុងរឿង"គង់ហ៊ាន"បង្ហាញពីពលរដ្ឋល្អ?

ក. កាតព្វកិច្ចរបស់គង់ហ៊ាន ខ. ការចេញច្បាំងជាមួយសត្រូវ

គ. ការសម្លាប់សត្វខ្លា ឃ. ការសម្លាប់ក្រពើ

១៣. គង់ហ៊ានមានកិត្តិយស ទ្រព្យសម្បត្តិដោយសារប្រពន្ធទាំងពីរ តើគង់ហ៊ានជាមនុស្សដូចម្តេច?

ក. ជាមនុស្សពោរពេញទៅដោយសំណាង ខ. ជាមនុស្សមានបុណ្យពីជាតិមុន

គ. ជាមនុស្សពោរពេញដោយសុភមង្គល ឃ. ជាមនុស្សដែលទេវតាតាមថែរក្សា

ខ. សំណួរត្រិះរិះ

១. ហេតុអ្វីបានជាប្រពន្ធទាំងពីរនាក់របស់គង់ហ៊ានតែងតែឱ្យកម្លាំងចិត្តដល់គង់ហ៊ាន? ចូរបកស្រាយ។

.....

.....

.....

.....

.....

.....

.....។

២. តើសត្វខ្លា និងក្រពើគេអាចចាត់ទុកជាមនុស្សបែបណា? ព្រោះអ្វី? តើមនុស្សប្រភេទនោះអាចរាប់អានជាមិត្តភក្តិបានដែរឬទេ? ចូរបង្ហាញពីហេតុនិងផល។

.....

.....

.....

.....

.....

.....

.....។

៣. ចូរវិភាគតួអង្គសំខាន់ៗក្នុងរឿង"គង់ហ៊ាន" ដោយលើកពីគុណសម្បត្តិ និងគុណវិបត្តិ។

.....

.....

.....

.....

.....

.....

.....

.....

.....។

៤. ចូរបកស្រាយន័យធៀបលើសុភាសិត"សំណាបយោងដីស្រីយោងប្រុស"ឱ្យបានក្បោះក្បាយ។

ឧទាហរណ៍៖ នៅលើកលោកនេះមនុស្សតែងមានគូស្រករដើម្បីបន្តពូជពង្សវង្សត្រកូល។ មនុស្សប្រុសរមែងជ្រើសរើសមនុស្សស្រីណាដែលមានភាពឆ្លាត ឈ្លាសវៃអាចជួយលើកិត្តិយសគ្រួសារបាន។

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៥. ចូរបង្ហាញពីតម្លៃអប់រំនៅក្នុងរឿង"គង់ហ៊ាន"។

.....

.....

.....

.....។

៦. ចូររកកិរិយាសុទ្ធនិងកិរិយាហេតុក្នុងរឿង"គង់ហ៊ាន"។

កិរិយាសុទ្ធ ៖

.....

.....

.....។

កិរិយាហេតុ ៖

.....

.....

.....

.....។

៧. ចូររកកាលអាកាសនៅក្នុងរឿង"គង់ហ៊ាន"។

កាល៖

.....

.....

.....។

អាកាស៖

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកមេពាក្យមកបំពេញត្រង់ចម្លើយនីមួយៗឱ្យបានត្រឹមត្រូវ៖

១. ឧទាហរណ៍៖ (គុ.) **ដែលកាចមោះមុតឥតញញើត។ ចម្លើយ៖ <u>សាហាវ</u>**

២. (កិ.) កម្រើកទទាក់ កម្រើករន្ទាន់។ ចម្លើយ៖.....

៣. (កិ.) ផ្គួបគ្នាឱ្យមាំ បន្ថែមរួមគ្នា ចោមជួយគ្នា។ ចម្លើយ៖.....

៤. (ន.) មនុស្សសត្វដែលមិនភ្លៀវភ្លាក្នុងកាម គឺមនុស្សសត្វដែលខ្លាចស្រីខ្លាចញី។ ចម្លើយ៖.....

៥. (កិ.វិ.) រវៀសរវៃ រូតរះ រួសរាន់ ប្រញាប់ប្រញាល់។ ចម្លើយ៖.....

៦. (កិ.) ប្រណាំងយកជ័យជម្នះ ដោយគ្រឿងសាស្ត្រាវុធ។ ចម្លើយ៖.....

៧. (កិ.) ព្រួយចិត្តខ្លាំង ដេកកើតទុក្ខក្រៀមក្រំពោះបាក់សន្លៃ។ ចម្លើយ៖.....

៨. (កិ.វិ.) ដេរដាសពាសពេញ កុះករដូចគេតម្រៀប។ ចម្លើយ៖.....

៩. (កិ.វិ.) ធ្វើឱ្យរញ្ជួយ។ ចម្លើយ៖.....

១០. (គុ.) ច្រើន បរិបូណ៌ សម្បូណ៌ ដេរដាស។ ចម្លើយ៖.....

ចូរប្អូនរកពាក្យផ្ទុយមកបំពេញត្រង់ចន្លោះខាងក្រោម ឱ្យបានត្រឹមត្រូវ៖

១. ឧទាហរណ៍៖ រឹងប៉ឹង ≠ ទន់ជ្រាយ

២. ពេញលេញ ≠ .....

៣. ជ្រៅជ្រះ ≠ .....

៤. ឈ្លាសវៃ ≠ .....

៥. ផ្អែមល្ហែម ≠ .....

៦. គ្រោះថ្នាក់ ≠ .....

៧. ល្បិចកល ≠ .....

៨. ខ្នះខ្នែង ≠ .....

៩. រួបរួម ≠ .....

១០. ស្ម័គ្រ ≠ .....

១១. ល្មើស ≠ .....

១២. ថ្លៃថ្នូរ ≠ .....

១៣. សន្តិភាព ≠ .....

១៤. ជោគជ័យ ≠ .....

ឃ. សំណួរផ្គូផ្គង

ចូរប្អូនប្រើសញ្ញាព្រួញ ដើម្បីផ្គូផ្គងខ្លឹមសារន័យដូចនៅតារាង(ក)ទៅតារាង(ខ)ឱ្យបានត្រឹមត្រូវ៖

ក	ខ
១. ឧទាហរណ៍៖ ប្រទេស នគរ មាតុប្រទេស ទឹកដីកំណើត។	ក. ផែនដី
២. សសរកន្លោង សសរស្តម្ភ។	ខ. ជំនឿ
៣. សទ្ធា លទ្ធិ។	គ. ស្ថាបនិក
៤. ពសុធា ប្រឹថពី ធរណី។	ឃ. វិវាទ
៥. ទំនាស់ ជម្លោះ។	ង. ប្រសូត្រ
៦. កសាង សាងសង់។	**ច. មាតុភូមិ**
៧. អ្នកតាក់តែង អ្នកសង់ អ្នកចាត់ការសាងសង់។	ឆ. ពីរ
៨. កើត សម្រាល ឆ្លងទន្លេ។	ជ. ព្រះជន្ម
៩. ទ្វេ គូ មួយគូ។	ឈ. សសរទ្រូង
១០. អាយុ ជន្មាយុ។	ញ. ស្ថាបនា

៥.៥. ការស្តាប់៖ រឿងខ្ញុំខុសហើយ

ចូរប្អូនអានអត្ថបទខាងក្រោម មុននឹងឆ្លើយនឹងសំណួរ។

អត្ថបទ រឿងខ្ញុំខុសហើយ

ព្រឹកថ្ងៃអាទិត្យមួយ សុភាពអផ្សុកបានសុំម្តាយទៅដើរកម្សាន្តនៅសួនសាធារណៈ។ នៅពេលចុះពីស៊ីក្លូ នាងក្រឡេកឃើញមិត្តរួមថ្នាក់ពីរនាក់បម្រុងចេញពីជើងម៉ាសួនច្បារ។ ដោយចង់បានគ្នាជជែកលេងនាងក៏ស្ទុះជ្រែកគេជ្រែកឯងស្រែកប្រកូកហៅកោកៗ ធ្វើឱ្យមនុស្សបែរមើលមកនាងគ្រប់គ្នា។ សុភាពនិយាយខ្លាំងៗ សើចក្អាកក្អាយដោយមិនបានមើលអ្នកជិតខាងឡើយ។ មិត្តនាងម្នាក់បានកេះនាង ហើយពោលខ្សឹបៗ៖"នែ៎ភាពមើលន៎ ! គេមើលឯងគ្រប់គ្នា និយាយតិចល្មមតែពីរនាក់គ្នាយើងទៅបានហើយ។ ពេលនេះទើបសុភាពចាប់អារម្មណ៍ មើលគេឯងជិតខាង។ នាងយកដៃខ្ទប់មាត់ នឹកខ្មាសហើយស្តាយកំហុសដែលខ្លួនធ្វើកន្លងមក។ នាងនិយាយត្រអៀនត្រអែ៖ " អឺ ! អឺ ! ខ្ញុំវល់តែអរដោយឃើញពួកឯងក៏ភ្លេចខ្លួន"។ "មែនហើយ (មិត្តម្នាក់ទៀតនិយាយ) ពេលឯងស្ទុះមកអម្បាញ់មិញបានទាំងពាក្យលោកយាយម្នាក់នោះទៀតផង។ គាត់អាចវាយតម្លៃថាយើងជាកូនក្មេងឥតពូជផងក៏មិនដឹង"។ " ធ្វើម៉េចទៅ ! (សុភាពចាប់ដៃមិត្តទាំងពីរ និងមានទឹកមុខគួរឱ្យអាណិត) ចុះបើខ្ញុំទៅសុំទោសគាត់យ៉ាងម៉េចដែរ?"។ "ល្អហើយទៅភ្លាមទៅ គាត់ប្រាកដជាឈប់ខឹងនឹងឯង"។

(ដកស្រង់ពីសៀវភៅភាសាខ្មែរថ្នាក់ទី៧ របស់ក្រសួងអប់រំឆ្នាំ២០០១)

ក. សំណួរជ្រើសរើស

ចូរប្អូនគូសសញ្ញា(√)លើចម្លើយណាមួយដែលប្អូនគិតថាជាចម្លើយត្រឹមត្រូវ៖

ឧទាហរណ៍៖ តើរឿង"ខ្ញុំខុសហើយ" ស្ថិតក្នុងប្រភេទរឿងបែបអ្វី?

☑ក. និទានកថា ខ. ព្រេងកថា គ. ទេវកថា ឃ. ល្បើកកថា

១. តើរឿងនេះដកស្រង់ចេញពីណា?

ក. សៀវភៅភាសាខ្មែរថ្នាក់ទី៧ ខ. សៀវភៅប្រជុំរឿងព្រេងខ្មែរ

គ. សៀវភៅកម្សាន្តរបស់កុមារ ឃ. សៀវភៅស្រីហិតោបទេស

២. ហេតុអ្វីបានជាសុភាពទៅកម្សាន្តនៅសួនសាធារណៈ?

ក. ព្រោះខ្ជិលរៀនសូត្រ ខ. ព្រោះអផ្សុកក្នុងការនៅផ្ទះ

គ. ព្រោះចង់ជួបមិត្តភក្តិ ឃ. ព្រោះចង់ដើរកម្សាន្តអារម្មណ៍

៣. នៅពេលដែលសុភាពទៅដល់សួនសាធារណៈ តើសុភាពបានជួបនឹងអ្នកណា?

ក. បងប្អូន ខ. លោកយាយ គ. មិត្តភក្តិ ឃ. ម្តាយមីង

៤. ហេតុអ្វីបានជាសុភាពស្រែកប្រកូកហៅមិត្តភក្តិរបស់ខ្លួន?

ក. ព្រោះត្រេកអរនឹងបានជួបមិត្ត ខ. ព្រោះប្រញាប់ជួបមិត្ត

គ. ព្រោះឃើញមិត្តចង់ចាកចេញពីសួន ឃ. ព្រោះជាអត្តចរិតរបស់សុភាព

៥. នៅពេលសុភាពរត់ទៅរកមិត្តរបស់នាង តើមានរឿងអ្វីកើតឡើង?

ក. នាងពារលោកយាយម្នាក់ ខ. នាងរត់ប៉ះក្មេងម្នាក់ដួល

គ. នាងរំខានអ្នកនៅក្នុងសួនទាំងអស់ ឃ. នាងត្រូវមិត្តនាងបន្ទោស

៦. មិត្តនាងបានប្រាប់នាង.....<u>លើកលែងតែ</u>៖

ក. កុំឱ្យនិយាយខ្លាំងពេករំខានអ្នកជុំវិញ ខ. កុំឱ្យធ្វើអ្វីដែលប៉ះពាល់អារម្មណ៍អ្នកដទៃ

គ. ឱ្យទៅសុំទោសលោកយាយដែលនាងពារ ឃ. បន្ទោសនាងដោយសម្តីខ្លាំងៗ

៧. តើពេលដែលឮមិត្តភក្តិប្រាប់ពីកំហុសរបស់ខ្លួន តើសុភាពមានអារម្មណ៍ដូចម្តេច?

ក. មានអារម្មណ៍ខ្មាសអៀននឹងអំពើរបស់ខ្លួន ខ. មានអារម្មណ៍ថាខ្លួនមិនខុស

គ. មានទឹកមុខត្រអៀនត្រអែ ឃ. ចម្លើយទាំងបីខាងលើ

៨. តើនាងសុភាពបានធ្វើអ្វីនៅបញ្ចប់រឿង"ខ្ញុំខុសហើយ"?

ក. បានទៅសូមទោសលោកយាយ ខ. ត្រឡប់ទៅផ្ទះវិញព្រោះខ្មាសអៀន

គ. មិនខ្វល់នឹងសម្តីមិត្តភក្តិ ឃ. នៅស្ងៀមគ្មានវាចា

៩. តើពលរដ្ឋល្អនៅក្នុងរឿង"ខ្ញុំខុសហើយ"នៅត្រង់ណា?

ក. សុភាពចេះទទួលកំហុសរបស់ខ្លួន ខ. សុភាពជាប្រជាពលរដ្ឋម្នាក់

គ. មិត្តភក្តិរបស់សុភាពជាពលរដ្ឋល្អ ឃ. ចម្លើយកនិងគ

១០. តើអ្នកនិពន្ធបានបញ្ចប់រឿង"ខ្ញុំខុសហើយ"បែបណា?

ក. បញ្ចប់ដោយមានសង្ឃឹម ខ. បញ្ចប់ដោយឱ្យតួអង្គចេះទទួលកំហុស

គ. បញ្ចប់ដោយអស់សង្ឃឹម ឃ. បញ្ចប់ដោយឱ្យតួអង្គខ្មាសអៀន

១១. មនុស្សដែលដឹងកំហុស ចេះទទួលកំហុស តើជាមនុស្សដូចម្តេច?

ក. ជាមនុស្សមានតម្លៃនៅក្នុងសង្គម ខ. ជាមនុស្សដែលមានព្រហ្មវិហារធម៌

គ. ជាមនុស្សមានសីលធម៌ល្អ ឃ. ជាមនុស្សមានឧត្តមគតិ

ខ. សំណួរត្រិះរិះ

១. តើក្នុងរឿង"ខ្ញុំខុសហើយ"មានតួអង្គប៉ុន្មាននាក់? តួអង្គណាជាតួអង្គឯក? តួអង្គរង? តួអង្គបន្ទាប់បន្សំ?

.....

.....

.....

.....។

២. ហេតុអ្វីបានជាម្តាយសុភាពសុខចិត្តឱ្យកូនស្រីមកដើរកម្សាន្តនៅសួនសាធារណៈតែម្នាក់ឯង?

.....

.....

.....

.....

.....។

៣. ចូររកគំនិតសំខាន់នៅក្នុងរឿងនេះ ដែលអ្នកនិពន្ធចង់បង្ហាញដល់អ្នកស្តាប់ឬអ្នកអាន?

.....

.....

.....

.....។

៤. នៅពេលយើងមានកំហុស តើយើងត្រូវធ្វើដូចម្តេច? ចូរលើកឧទាហរណ៍មកបញ្ជាក់ផង។

.....

.....

.....

.....

.....

.....។

គ. សំណួរបំពេញចន្លោះ

ចូរប្អូនរកន័យរបស់មេពាក្យខាងក្រោមមកបំពេញត្រង់ចន្លោះនីមួយៗឱ្យបានត្រឹមត្រូវ៖

ឧទាហរណ៍៖ អផ្សុក (កិ.) មិនសប្បាយចិត្ត ព្រួយចិត្ត ខ្វល់ចិត្ត ធុញទ្រាន់នៅមិនសុខ។

១. កម្សាន្ត.....

២. សួនសាធារណៈ.....

៣. ខ្សឹប.....

៤. អារម្មណ៍.....

៥. ស៊ីក្លូ.....

៦. ត្រអៀនត្រអែ.....

៧. កំហុស.....

៨. ពូជ.....

៩. ប្រាកដ.....

១០. រវល់.....

ចូររកពាក្យផ្ទុយមកបំពេញនៅចន្លោះនីមួយៗឱ្យបានត្រឹមត្រូវ៖

ឧទាហរណ៍៖ ជជែក ≠ ស្ងៀមស្ងាត់

១. ខ្លាំង ≠ .....

២. ខ្សឹប ≠ .....

៣. ចាប់ ≠ .....

៤. ជិត ≠ .....

៥. ភ្លេច ≠ .....

៦. ព្រឹក ≠ .....

៧. ចេញ ≠ .....

៨. រវល់ ≠ .....

៥.៦. តែងសេចក្តីៈ បំពេញទម្រង់បែបបទប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ

ក. សំណួរត្រិះរិះ

១. ហេតុអ្វីបានជាយើងត្រូវរៀនពីរបៀបបំពេញទម្រង់បែបបទ ? ចូរបកស្រាយ។

.....

.....

.....

.....

..... ។

២. តើប្អូនត្រូវធ្វើដូចម្តេចក្នុងឆ្នាំសិក្សានីមួយៗ មុននឹងបានចូលរៀន ? ព្រោះអ្វី ?

.....

.....

.....

.....

<u>គំរូរបៀបបំពេញសំណុំបែបបទ</u>

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អត្តសញ្ញាណប័ណ្ណសិស្ស

លេខ : ...១៩/ ៧B....

វិទ្យាល័យ ព្រះស៊ីសុវត្ថិ

ឆ្នាំសិក្សា : ២០២២ - ២០២៣

ភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២២

នាយកវិទ្យាល័យ

រូបថត ថតថ្មី

៣ × ៤

ពណ៌ ឬសខ្មៅ

គោត្តនាម នាម : ..តាន់ សុជាតា...

ភេទ :...ស្រី.... សញ្ជាតិ ....ខ្មែរ.....

ថ្ងៃ ខែ ឆ្នាំកំណើត :..១០ មិថុនា ២០០៩

ទីកន្លែងកំណើត : សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ជាសិស្សថ្នាក់ទី : ៧B អត្តលេខ : ២២៤៣៦

ឪពុកឈ្មោះ : ...ជា តាន់....

មុខរបរ : ...នគរបាល.....

ម្តាយឈ្មោះ : ....នួន សុជាតិ.....

មុខរបរ : .....មេផ្ទះ.....

ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ..៣E0..ផ្លូវលេខ..៤៩0.....

សង្កាត់ : ...ផ្សារថ្មីទី២... ខណ្ឌ : ....ដូនពេញ.....

ហត្ថលេខាសាមីខ្លួន

១. ព័ត៌មានផ្ទាល់ខ្លួន

ចូរប្អូនបំពេញព័ត៌មានផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ៖

ព្រះរាជាណាចក្រកម្ពុជា

សាលារាជធានីភ្នំពេញ ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជននិងកីឡារាជធានីភ្នំពេញ

វិទ្យាល័យ.....

លេខ.....

<u>ព័ត៌មានផ្ទាល់ខ្លួនសិស្ស</u>

រូបថត ៤×៦

១.ឈ្មោះសិស្ស.....ភេទ.....ជាតិ.....សញ្ជាតិ.....

២. កើតនៅថ្ងៃទី.....ខែ.....ឆ្នាំ.....

៣. នៅឃុំ/ សង្កាត់.....ខណ្ឌ/ស្រុក.....ខេត្ត/ក្រុង.....

៤. ឪពុកឈ្មោះ :.....មុខរបរ.....ក្រសួង.....

៥. ម្តាយឈ្មោះ :.....មុខរបរ.....ក្រសួង.....

៦. អាណាព្យាបាលឈ្មោះ :.....ជា.....ក្រសួង.....

៧. អាសយដ្ឋានបច្ចុប្បន្ន :ផ្ទះលេខ.....ជាន់ទី.....ក្រុមទី.....សង្កាត់.....

ខណ្ឌ.....ទូរស័ព្ទ.....

៨. ជាប់សញ្ញាបត្រ មធ្យមសិក្សាបឋមភូមិ សម័ប្រឡង : ថ្ងៃទី.....ខែ.....ឆ្នាំ.....

មណ្ឌលប្រឡង.....លេខបន្ទប់.....លេខតុ.....និទ្ទេស.....

៩. ផ្ទេរការសិក្សាមកពីសាលាបឋមសិក្សា អនុវិទ្យាល័យ-វិទ្យាល័យ.....ឃុំ/សង្កាត់.....

ខណ្ឌ/ស្រុក.....ខេត្ត/ក្រុង.....ចូលរៀនថ្នាក់ទី.....ឆ្នាំសិក្សា២០២.....២០២...

១០. កាលបរិច្ឆេទផ្ទេរការសិក្សាមកពីសាលាបឋមសិក្សា អនុវិទ្យាល័យ-វិទ្យាល័យ.....ថ្ងៃទី....ខែ.....ឆ្នាំ...

សំណុំលិខិតជូនភ្ជាប់		**ឆ្នាំសិក្សា**	**ថ្នាក់ទី**	**ឈ្មោះគ្រូបន្ទុក**
១. ពាក្យសុំចូលរៀន	១ច្បាប់	២០២....២០២.....	ថ្នាក់ទី.....	លោក.....
២. សៀវភៅសិក្ខាគារិក	១ក្បាល	២០២....២០២.....	ថ្នាក់ទី.....	លោក.....

៣. រូបថត៤ × ៦ស.ម ២សន្លឹក ២០២.....២០២.... ថ្នាក់ទី..... លោក.....

- លុបកន្លែងដែលគ្មានប្រយោជន៍
- ស្នើបំពេញគ្រប់ចន្លោះមុនយកមកដាក់

កំណត់សម្គាល់លើអាកប្បកិរិយាពិសេសរបស់សិស្ស បញ្ជាក់ដោយបន្ទុកថ្នាក់

ហត្ថលេខា

១.....

២.....

៣.....

៤.....

***

២. ពាក្យសុំចូលរៀន

ចូរប្អូនបំពេញពាក្យសុំចូលរៀនឱ្យបានត្រឹមត្រូវ៖

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងអប់រំយុវជន និងកីឡា ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជននិងកីឡារាជធានីភ្នំពេញ

វិទ្យាល័យព្រះស៊ីសុវត្ថិ

សាលារៀនដំណាក់ថ្មី(NGS)

ពាក្យសុំចូលរៀនថ្នាក់ទី.....

ឆ្នាំសិក្សា ២០២.....-**២០២**.....

នាងខ្ញុំ/ខ្ញុំបាទឈ្មោះ.....ភេទ.....ជាតិ.....ជាសិស្សថ្នាក់ទី.....
នៃសាលាបឋមសិក្សា/អនុវិទ្យាល័យ/វិទ្យាល័យ.....ឆ្នាំសិក្សា ២០២.....-២០២.....

- កើតថ្ងៃទី..... ខែ.....ឆ្នាំ.....នៅសង្កាត់/ឃុំ.....ស្រុក/ខណ្ឌ.....ខេត្ត/ក្រុង.....
- ឪពុកឈ្មោះ.....មុខរបរ.....
- ម្តាយឈ្មោះ.....មុខរបរ.....
- អ្នកអាណាព្យាបាលឈ្មោះ.....មុខរបរ.....
- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ.....ផ្លូវ.....ក្រុមទី.....ភូមិ/មណ្ឌល.....សង្កាត់.....
  ខណ្ឌ.....

សូមគោរពជូន

លោកនាយកវិទ្យាល័យព្រះស៊ីសុវត្ថិ

សូមលោកនាយក/នាយករង/នាយិការងទទួលបន្ទុកកម្មវិធីសាលារៀនជំនាន់ថ្មី(NGS)មេត្តាចុះឈ្មោះខ្ញុំបាទ/នាងខ្ញុំ

សាជាថ្មីនៅថ្នាក់ទី.....ក្នុងឆ្នាំសិក្សា ២០២.....-២០២.....នៅកម្មវិធីសាលារៀនជំនាន់ថ្មី(NGS)

នៃវិទ្យាល័យព្រះស៊ីសុវត្ថិដោយអនុគ្រោះ។

សូមជូនភ្ជាប់មកជាមួយ

១. សៀវភៅសិក្ខាគារិក.....០១ក្បាល (សម្រាប់សិស្សថ្មី)

២. លិខិតបញ្ជាក់សំបុត្រកំណើត(ថតចម្លង).....០១សន្លឹក (សម្រាប់សិស្សថ្មី)

៣. លិខិតផ្ទេរការសិក្សា.....០១ច្បាប់ (សម្រាប់សិស្សថ្មី)

៤. បង្កាន់ដៃបង់វិភាគទានស្ម័គ្រចិត្តដើម្បីនិរន្តរភាពសាលារៀនជំនាន់ថ្មីឆ្នាំសិក្សា២០២.....-២០២.....

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាថានឹងគោរពបទបញ្ជាផ្ទៃក្នុងសាលាឱ្យបានគ្រប់ជ្រុងជ្រោយដាច់ខាត។ បើខ្ញុំបាទ/នាងខ្ញុំប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយខ្ញុំសូមទទួលកំហុសតាមច្បាប់ជាធរមាន។

សូមលោកនាយក/នាយករង/នាយិការង មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី.....ខែ.....ឆ្នាំ២០២.....

បានឃើញនិងឯកភាព ស្នាមមេដៃស្តាំសិស្ស

មាតាបិតា អាណាព្យាបាល

សិស្សឈ្មោះ.....

រាជធានីភ្នំពេញថ្ងៃទី.....ខែ.....ឆ្នាំ២០២.....

ហត្ថលេខាមាតាបិតាអ្នកអាណាព្យាបាល ឈ្មោះ.....

សូមអរគុណ !